ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ផែនការយុទ្ធសាស្ត្រ
# ស្តីពី
# ការកសាង និង ការអភិវឌ្ឍសមត្ថភាព
# ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤

អភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស

ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ខែ ឧសភា ឆ្នាំ ២០២១

# មាតិកា


បុព្វកថា........................................................................................................ i

អារម្ភកថា.......................................................................................................iii

មូលបទសង្ខេប .................................................................................................v

ជំពូក ១ : សេចក្ដីផ្ដើម........................................................................................ ១

១.១. សាវតា............................................................................................... ១

១.២. វង្វាយតម្លៃការកសាង និង ការអភិវឌ្ឍសមត្ថភាព............................................. ២

១.៣. ការវិភាគការងារ និង តម្រូវការបណ្ដុះបណ្ដាល និង វិក្រឹតការ................................ ៥

១.៤. កត្តាកំណត់ជោគជ័យនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព.................................. ១១

១.៥. បញ្ហាប្រឈម និង ដំណោះស្រាយនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព..................... ១៣

១.៦. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព............................ ១៤

ជំពូក ២ : ក្របខណ្ឌយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ..................................................១៧

២.១. ចក្ខុវិស័យ ........................................................................................១៧

២.២. បេសកកម្ម .......................................................................................១៧

២.៣. គោលបំណង.......................................................................................១៧

២.៤. គោលដៅ...........................................................................................១៧

២.៥. វិសាលភាព និង ក្របខណ្ឌពេលវេលា..........................................................១៨

២.៦. ក្របខណ្ឌយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព .........................................១៨

ជំពូក ៣ : ផែនការសកម្មភាពនៃយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ..................................២៦

៣.១. ផែនការសកម្មភាព...............................................................................២៦

៣.២. ការវិភាគ និង ការគ្រប់គ្រងហានិភ័យ .......................................................... ៣១

ជំពូក ៤ : តួអង្គអនុវត្ត យន្តការ និង ប្រភពធនធានហិរញ្ញវត្ថុ.............................................. ៣៤

៤.១. តួអង្គអនុវត្ត...................................................................................... ៣៤

៤.២. យន្តការអនុវត្ត.................................................................................... ៣៨

៤.៣. ប្រភពធនធានហិរញ្ញវត្ថុ.......................................................................... ៣៨

ជំពូក ៥ : ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ .......................................................... ៤១

៥.១. យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ.................................................. ៤១

៥.២. វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ .............................................. ៤១

៥.៣. ប្រព័ន្ធរបាយការណ៍សមិទ្ធកម្ម..................................................................... ៤៤

ជំពូក ៦ : សេចក្ដីសន្និដ្ឋាន................................................................................. ៤៥

បញ្ជីឧបសម្ព័ន្ធ

# បុព្វកថា

ក្នុងរយៈពេលជាង ៤០ ឆ្នាំមកនេះ ដោយការតស៊ូជម្នះគ្រប់ឧបសគ្គ ក្រោកឈរឡើងវិញ កម្ពុជាបានទទួលជោគជ័យគួរជាទីមោទនៈ លើគ្រប់វិស័យ ក្នុងការស្តារ និង ការអភិវឌ្ឍប្រទេសជាតិ ហើយកសាងបានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋទំនើប និង សមិទ្ធផលគ្រឹះជាច្រើន ដែលគាំទ្រកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និង កំពុងឈានឆ្ពោះទៅបន្តជំរុញសម្ទុះល្បឿនសេដ្ឋកិច្ចរឹងមាំ ធន់នឹងវិបត្តិ លើមូលដ្ឋានសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សាធារណៈ និង សុខដុមភាពសង្គម ។ តាមរយៈនេះ ភាពក្រីក្ររបស់ប្រជាជន ត្រូវបានកាត់បន្ថយជាបន្តបន្ទាប់រហូតដល់ក្រោម ១០% មុនវិបត្តិនៃការរាតត្បាតពីជំងឺកូវីដ-១៩ ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើង នូវសូចនាករសង្គម-សេដ្ឋកិច្ច ពិសេស ក្នុងវិស័យអប់រំ និង សុខាភិបាល ដែលអាចសម្រេចបានស្ទើរទាំងស្រុងនូវគោលដៅអភិវឌ្ឍសហសវត្សរ៍ ។

សមិទ្ធផលទាំងនេះ បង្កើតឡើងនូវក្តីសង្ឃឹមថ្មី និង ការរំពឹងទុកកាន់តែខ្ពស់ដល់ប្រជាជនកម្ពុជាគ្រប់ៗរូប សម្រាប់ពេលអនាគត ។ ក្នុងសុទិដ្ឋិនិយម លើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ គួរជាទីមោទនៈ, កម្ពុជាចាំបាច់ត្រូវបន្តខិតខំទ្វេឡើងថែមទៀត ដើម្បីកសាងប្រទេសឱ្យកាន់តែរីកចម្រើន ក្នុងបរិការណ៍នៃការវិវត្តថ្មីៗលើសកលលោក នាសតវត្សទី ២១ ដែលរចនាដោយការប្រែប្រួលដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន លើមូលដ្ឋានបដិវត្តឧស្សាហកម្មទី ៤ និង ការប្រកួតប្រជែងកាន់តែស្មុគស្មាញលើគ្រប់វិស័យទាំងក្នុងទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និង សង្គម-វប្បធម៌ ។ ក្នុងន័យនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់ជាច្រើនដង អំពីបំណងប្រាថ្នាក្នុងការកសាងកម្ពុជាឱ្យទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ដោយកសាងជាជំហានៗនូវសង្គមកម្ពុជាមួយ ដែលមានសុខសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម, មានការគោរពខ្ជាប់ខ្ជួនគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ សិទ្ធិ និង សេចក្តីថ្លៃថ្នូរបស់មនុស្ស, មានការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌, មានកោសិកាផ្សារភ្ជាប់គ្នា និង មានប្រជាជនមានចំណេះដឹងខ្ពស់ វប្បធម៌ជ្រៅជ្រះ ជីវភាពសមរម្យ និង រស់នៅសុខដុមរមនា ទាំងក្នុងសង្គមជាតិ និង នៅក្នុងក្រុមគ្រួសារ ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល បានដាក់ចេញ **"យុទ្ធសាស្ត្រចតុកោណ"** ដំណាក់កាលទី ៤ ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** និង ផ្តល់អាទិភាពទី ១ ដល់ការអភិវឌ្ឍធនធានមនុស្ស តាមគន្លងបាវចនា **"មនុស្ស ផ្លូវ ទឹក ភ្លើង"** សម្រាប់បន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។ ក្នុងនោះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាឆ្អឹងខ្នងដ៏សំខាន់នៃកម្មវិធីកែទម្រង់គន្លឹះៗ និង សម្រេចបានវឌ្ឍនភាពល្អប្រសើរ សម្រាប់ដំណាក់កាលទី ៣ ក្នុងគោលដៅផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាព បន្ទាប់ពីទទួលជោគជ័យ ដ៏ត្រចះត្រចង់ ក្នុងការកសាង **"ភាពជឿទុកចិត្តនៃថវិកា** និង **គណនេយ្យភាពហិរញ្ញវត្ថុ"** ក្នុងដំណាក់កាលទី ១ និង ទី ២ ។ បច្ចុប្បន្ន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតក្នុងដំណាក់កាល ៣ បូក ២ សំដៅ **"បង្កើនការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** និង **"បញ្ចប់ការរៀបចំឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម"** នៅដំណាក់កាលទី ៤ ខាងមុខ ព្រមជាមួយនឹងការផ្ទេរសិទ្ធិអំណាច ភាពជាម្ចាស់ និង ការទទួលខុសត្រូវកាន់តែច្រើនទៅដល់ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ជាការពិត ការសម្រេចជោគជ័យ និង វឌ្ឍនភាពល្អប្រសើរ ក្នុងការអនុវត្តការកែទម្រង់ខាងលើ គឺមានការចូលរួមចំណែកដ៏សំខាន់ នៃការកសាង និង ការអភិវឌ្ឍធនធានមនុស្ស ជាពិសេស ការបណ្ដុះបណ្ដាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការលើជំនាញពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានផ្ដល់អាទិភាព និង បានអនុវត្តយ៉ាងសកម្ម ចាប់តាំងពីដំណាក់កាលដំបូង នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងឆ្នាំ ២០០៤ ។ ក្នុងទិសដៅខាងមុខ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដាក់ចេញនូវ ***«ផែនការយុទ្ធសាស្ត្រស្ដីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤»*** ក្នុងគោលបំណងផ្ដល់ជូនសិក្ខាកាមនូវ សមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយ គុណភាព នវានុវត្តន៍ និង មនសិការ សំដៅចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង ការលើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ នៃការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ។

ខ្ញុំសូមអរគុណ និងវាយតម្លៃខ្ពស់ចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សហការី ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការដឹកនាំ និង ការរៀបចំឯកសារ ដ៏មានសារសំខាន់នេះ និង សូមវាយតម្លៃខ្ពស់ ដល់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ ព្រមទាំងដៃគូអភិវឌ្ឍ ដែលបានផ្ដល់កិច្ចសហការ និង ធាតុចូលដ៏មានតម្លៃ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ រហូតទទួលបានជោគជ័យជាស្ថាពរ ។

ខ្ញុំសូមប្រសិទ្ធពរឱ្យ *សុឆន្ទៈ ការចូលរួម ភាពជាម្ចាស់ ការទទួលខុសត្រូវ និង កិច្ចសហប្រតិបត្តិការ* ល្អរវាងគ្រប់ភាគីពាក់ព័ន្ធ កើតកើន និង រីកដុះដាលកាន់តែរឹងមាំថែមទៀត ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ឱ្យសម្រេចបានជោគជ័យជាផ្លែផ្កាដូចការរំពឹងទុក សម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។

ថ្ងៃ ៨កើត ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

លើមូលដ្ឋានគ្រឹះ **"សន្តិភាព"** ដែលជាសមិទ្ធផលនៃនយោបាយ **"ឈ្នះ-ឈ្នះ"** កម្ពុជាបានទទួលជោគជ័យត្រចះត្រចង់ជាបន្តបន្ទាប់ ក្នុងការស្តារ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ដណ្តើមបានមកវិញនូវមោទនភាពជាតិទាំងនៅក្នុងតំបន់ និង លើសកលលោក ។ ក្នុងនោះ ធនធានមនុស្ស បានដើរតួនាទីសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈម និង ការប្រែក្លាយការគំរាមទៅជាឱកាស ដើម្បីចាប់យកអត្ថប្រយោជន៍ ឆ្លើយតបនឹងតម្រូវការនៃការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ចរឹងមាំ ប្រកបដោយចីរភាព និង បរិយាបន្ន ក្នុងបរិបទសកលូបនីយកម្ម និង ការប្រែប្រួលដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និង បដិវត្តឧស្សាហកម្មទី ៤ ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ**"យុទ្ធសាស្ត្រចតុកោណ"** ដំណាក់កាលទី ៤ ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** និង បានផ្តល់អាទិភាពទី ១ ដល់ការអភិវឌ្ឍធនធានមនុស្ស សម្រាប់ការបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។ ជាមួយនោះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានដាក់ឱ្យអនុវត្តដំបូងក្នុងឆ្នាំ ២០០៤ ត្រូវបានចាត់ទុកជាឆ្អឹងខ្នងដ៏សំខាន់នៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល និង សម្រេចបានជោគជ័យ ក្នុងការកសាង **"ភាពជឿទុកចិត្តនៃថវិកា** និង **គណនេយ្យភាពហិរញ្ញវត្ថុ"** នៅដំណាក់កាលទី ១ និង ទី ២ ហើយកំពុងមានវឌ្ឍនភាពល្អប្រសើរសម្រាប់ដំណាក់កាលទី ៣ ក្នុងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ បច្ចុប្បន្ន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតក្នុងដំណាក់កាល ៣ បូក ២ ក្នុងគោលដៅបង្កើនការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង បញ្ចប់ការរៀបចំឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម នៅក្នុងដំណាក់កាលទី ៤ ខាងមុខ ព្រមជាមួយនឹងការផ្ទេរសិទ្ធិអំណាច ភាពជាម្ចាស់ និង ការទទួលខុសត្រូវកាន់តែច្រើនឡើងទៅដល់ក្រសួងស្ថាប័ន និង មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រការនេះ តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ថែមទៀត លើការពង្រឹងពង្រីកសមត្ថភាព និង ជំនាញវិជ្ជាជីវៈ ជូនមន្ត្រីរាជការ ជាពិសេស ក្រុមមន្ត្រីទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុ ក្រុមមន្ត្រីទទួលបន្ទុកកិច្ចលទ្ធកម្ម ក្រុមការងារថវិកា រដ្ឋទេយ្យករចំណូល រដ្ឋទេយ្យករបុរេប្រទាន និង ភ្នាក់ងារបើកផ្តល់ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ក្នុងការរៀបចំ និង អនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ។ ទន្ទឹមនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវដាក់ចេញនូវ ***«ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤»*** សំដៅជំរុញធន្ទះចូលរួម ភាពជាម្ចាស់ ការទទួលខុសត្រូវ និង កិច្ចសហប្រតិបត្តិការ ក្នុងគោលដៅពង្រឹងពង្រីកសមត្ថភាពជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ ជូនមន្ត្រីរាជការគោលដៅសម្រាប់ចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង លើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ នៃការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ។

ឆ្លើយតបតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាល និង បរិការណ៍ថ្មី និង គោរពតាមការសម្រេច និង ការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំធ្វើបច្ចុប្បន្នកម្មឡើងវិញ ដោយផ្អែកលើលទ្ធផលនៃការសិក្សា ស្រាវជ្រាវ វិភាគ និង ពិនិត្យវាយតម្លៃបាយការណ៍

អនុវត្តកន្លងមក ព័ត៌មាន ទិន្នន័យពីការសម្ភាស សិក្ខាសាលាពិគ្រោះយោបល់ និង កិច្ចប្រជុំត្រួតពិនិត្យជាច្រើនលើក ជាមួយនឹង តំណាងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និង តួអង្គពាក់ព័ន្ធ រួមទាំងដៃគូជាតិ-អន្តរជាតិ ។ ផែនការយុទ្ធសាស្ត្រនេះ ផ្តោតអាទិភាពលើ ការអភិវឌ្ឍសមត្ថភាពជំនាញ និង កោសល្យឯកទេស លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការពង្រឹងពង្រីក វិធីសាស្ត្របណ្តុះបណ្តាល និង វិក្រឹតការ តាមអភិក្រមៈ *(១). កសាងវិធានជាលិខិតបទដ្ឋានគតិយុត្តគាំទ្រការបណ្តុះ ឆន្ទៈចូលរួមកសាង និង អភិវឌ្ឍសមត្ថភាព, (២). បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស, (៣). ពង្រឹង កិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គគាំទ្រការងារកសាង និង ការអភិវឌ្ឍសមត្ថភាព, (៤). ពង្រឹងពង្រីកការស្រាវជ្រាវ និង អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ, និង (៥). ពង្រឹង ការវាយតម្លៃតម្រូវការ និង ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃ និង វិធីសាស្ត្របណ្តុះបណ្តាល និង វិក្រឹតការ។*

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាពនេះ គឺជាត្រីវិស័យសម្រាប់តម្រង់ ទិសការរៀបចំ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ ដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ ជ្រុងជ្រោយ សំដៅអភិវឌ្ឍសមត្ថភាពជំនាញ និង កោសល្យឯកទេសវិជ្ជាជីវៈ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង លើកកម្ពស់ការយល់ដឹង និង ចំណេះដឹង ជូនមន្ត្រីរាជការគោលដៅ សម្រាប់ចូលរួមចំណែកក្នុងការអនុវត្តការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ឱ្យសម្រេចបានជោគជ័យ តាម ការគ្រោងទុក ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

ក្នុងនាមក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សហការី, ខ្ញុំសូមសម្តែងនូវ គារវកិច្ចដ៏ខ្ពង់ខ្ពស់ជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលតែងយកចិត្តទុកដាក់ គាំទ្រ និង ផ្តល់ការណែនាំ ប្រកបដោយចក្ខុវិស័យប្រាកដនិយម ដល់ការងារកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាជោគជ័យក្នុង ការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ។ ខ្ញុំក៏សូមអរគុណចំពោះ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និង តួអង្គពាក់ព័ន្ធ រួមទាំងដៃគូជាតិ-អន្តរជាតិ ដែលបានចូលរួមសហការ និង ផ្តល់ធាតុចូលដ៏មានតម្លៃ សម្រាប់ ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ដ៏មានសារសំខាន់នេះ រហូតទទួលបាន ជោគជ័យជាស្ថាពរ ។

*ថ្ងៃ* ចន្ទ ៧កើត *ខែ*បុស្ស *ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី*២៤ *ខែ* មករា *ឆ្នាំ ២០២២*

**រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារ**

**កសាងសមត្ថភាពក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

# មូលបទសង្ខេប

ការលើកកម្ពស់កម្រិតជីវភាព និង ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ គឺជាគោលដៅចុងក្រោយដ៏សំខាន់មួយ នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងនោះ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីសំខាន់មួយនៃកម្មវិធីកែទម្រង់គន្លឹះសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅឈានទៅសម្រេចគោលដៅខាងលើនេះ ។ ទន្ទឹមនេះ ការកសាង និង ការអភិវឌ្ឍសមត្ថភាព គឺជាកត្តាគន្លឹះសម្រាប់ដោះស្រាយគ្រប់បញ្ហា និង រួមចំណែកដ៏សំខាន់ដល់ការសម្រេចជោគជ័យ នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីកែទម្រង់នេះ មានបួនដំណាក់កាល ចាប់ផ្តើមនៅឆ្នាំ ២០០៤ ឈានឡើងជាជំហានៗ ជាមួយនឹងការសម្រេចជោគជ័យ ក្នុងការកសាងបាននូវ ភាពជឿទុកចិត្តនៃថវិកា ក្នុងដំណាក់កាលទី ១ និង គណនេយ្យភាពហិរញ្ញវត្ថុ ក្នុងដំណាក់កាលទី ២ ។ បច្ចុប្បន្ន កម្មវិធីកែទម្រង់នេះ កំពុងស្ថិតក្នុងដំណាក់កាល ៣ បូក ២ ក្នុងគោលដៅពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង ត្រៀមខ្លួនឆ្ពោះទៅពង្រឹងគណនេយ្យភាពចំពោះសមិទ្ធកម្ម ក្នុងដំណាក់កាលទី ៤ នៅពេលខាងមុខ ។

ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងត្រូវបានចូលរួមអនុវត្តយ៉ាងសកម្មពី គ្រប់ក្រសួង ស្ថាប័ន និង មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ រួមនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ។ ក្នុងនោះ ការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចូលរួមចំណែកដ៏សំខាន់ដល់ការសម្រេចជោគជ័យកន្លងមក និង កំពុងត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ។ ទន្ទឹមនេះ ការផ្ទេរសិទ្ធអំណាច ភាពជាម្ចាស់ និង ការទទួលខុសត្រូវ កាន់តែច្រើនឡើង ដល់ក្រសួង ស្ថាប័ន និង មន្ទីរអង្គភាពជំនាញក្រោមឱវាទ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និង ការអនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ធ្វើឱ្យគ្រប់ក្រសួង ស្ថាប័ន ចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ថែមទៀត លើការពង្រឹងពង្រីកសមត្ថភាព និង ជំនាញវិជ្ជាជីវៈ ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ។ លើសពីនេះ តម្រូវការកសាង និង អភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់កម្ពុជា កាន់តែចាំបាច់ថែមទៀត ក្នុងគោលដៅបង្កើនភាពធន់មាំក្នុងការឆ្លើយតបចំពោះវិបត្តិ ភាពប្រកួតប្រជែង ជវភាព និង សក្តានុពលភាពសេដ្ឋកិច្ច ក្នុងបរិការណ៍សកលូបនីយកម្ម និង ការរីកចម្រើននៃបច្ចេកវិទ្យាដែលជំរុញដោយបដិវត្តន៍ឧស្សាហកម្មទី ៤ នេះ ។

លើមូលដ្ឋាននេះ ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ត្រូវបានរៀបចំឡើងដោយបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស ដូចដែលរាជរដ្ឋាភិបាលបានចាត់ទុកជាការងារអាទិភាពក្នុង «**យុទ្ធសាស្ត្រចតុកោណ**» នៅគ្រប់ដំណាក់កាល ពិសេសបានក្លាយជាអាទិភាពទី ១ នៅដំណាក់កាលទី ៣ និង ទី ៤ ។ ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណង អភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញតួនាទី ភារកិច្ច ប្រកបដោយសុឆន្ទៈ ស្មារតីទទួលខុសត្រូវ និង ភាពម្ចាស់ការ ។ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាននិងកំពុងដើរតួនាទីយ៉ាងសកម្ម លើការងារបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សមត្ថភាព

និង ជំនាញវិជ្ជាជីវៈ ផ្អែកតាមកម្រិតគុណវុឌ្ឍិ និង ក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមចំណែកគាំទ្រ និង អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ។

ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ របស់គ្រប់ក្រសួង ស្ថាប័ន និង មន្ទីរអង្គភាពជំនាញក្រោមឱវាទ, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈរដ្ឋបាល, និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានតែងតាំង ប្រគល់ភារកិច្ច ក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គាំទ្រ និង អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងស្មារតីនេះ ប្រព័ន្ធកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ជាពិសេស កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ (Certificate Program) ផ្សារភ្ជាប់មុខតំណែងលើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំនិងអនុវត្ត ឆ្លើយតបតម្រូវការចាំបាច់ស្របតាមកម្រិតគុណវុឌ្ឍិ និង ក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន ៥ កម្រិត គឺ: *(១). សមត្ថភាពយល់ដឹងទូទៅ, (២). សមត្ថភាពឯកទេសមូលដ្ឋាន, (៣). សមត្ថភាពឯកទេសជំនាញ, (៤). សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់, និង (៥). សមត្ថភាពឯកទេសកម្រិតជំនាញការ* ។ ក្នុងនោះ វិធានការបន្ទាន់ចំពោះមុខ, វិធានការរយៈមធ្យម និង រយៈពេលវែង ព្រមទាំងទិសដៅអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រ ត្រូវបានកំណត់ ឆ្លើយតបទៅនឹងតម្រូវការជាជំហានៗនៃការអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជា យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និង យុទ្ធសាស្ត្រកៀរគរចំណូល ជាដើម ។

ដើម្បីធានាប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការអនុវត្ត, ផែនការយុទ្ធសាស្ត្រនេះ បានកំណត់ក្របខណ្ឌយុទ្ធសាស្ត្រអាទិភាព និង ផែនការសកម្មភាពគាំទ្រសំខាន់ៗ ដូចខាងក្រោម ÷

**- យុទ្ធសាស្ត្រទី ១. ការបណ្តុះធនធានលើការកសាង និង ការអភិវឌ្ឍសមត្ថភាព:** គ្របដណ្តប់លើការបណ្តុះធនធានមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ក្នុងការលើកកម្ពស់សមត្ថភាព ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

**- យុទ្ធសាស្ត្រទី ២. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស:** គ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើមុខងារកសាងនិងអភិវឌ្ឍសមត្ថភាព ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ និង ការធ្វើទំនើបកម្មកម្មវិធីសិក្សា ឯកសារ និង វិធីសាស្ត្របណ្តុះបណ្តាល និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង និង បណ្ណាល័យ សម្រាប់គាំទ្រការងារកសាង និង អភិវឌ្ឍសមត្ថភាព ។

**- យុទ្ធសាស្ត្រទី ៣. ការពង្រឹងកិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គគាំទ្រការកសាង និង ការអភិវឌ្ឍសមត្ថភាព:** គ្របដណ្តប់លើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនៃតួអង្គពាក់ព័ន្ធ សម្រាប់ការចូលរួម និង ការគាំទ្រ ទាំងខាងស្មារតី ហិរញ្ញវត្ថុ និង បច្ចេកទេស ដើម្បីធ្វើឱ្យការកសាង និង ការអភិវឌ្ឍសមត្ថភាព លើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព្រឹត្តទៅបានរលូន គ្រប់គ្រាន់ និង ទាន់ពេល ប្រកបដោយប្រសិទ្ធភាព ។

**- យុទ្ធសាស្ត្រទី ៤. ការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ:** គ្របដណ្តប់លើការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ដោយត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់តួអង្គ និង ដៃគូពាក់ព័ន្ធ ក្នុងគោលដៅជំរុញ និង លើកកម្ពស់ការផ្តល់សេវាបណ្តុះបណ្តាល ប្រកបដោយគុណភាព និង ប្រសិទ្ធភាព ។

**- យុទ្ធសាស្ត្រទី ៥. ការពង្រឹងការវាយតម្លៃតម្រូវការ ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃ និង វិធីសាស្ត្របណ្តុះបណ្តាល :** គ្របដណ្តប់លើការពង្រឹងសមត្ថភាព និង ការអនុវត្តក្របខណ្ឌតាមដានត្រួតពិនិត្យ និង ការវាយតម្លៃក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយផ្តោតលើការរៀបចំឱ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យ និង វាយតម្លៃ, ការពង្រឹងយន្តការក្រុមការងារ និង ការរៀបចំលក្ខខណ្ឌយោងប្រតិបត្តិ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្ត ។

ក្នុងទិដ្ឋភាពបច្ចេកទេស ផែនការយុទ្ធសាស្ត្រនេះ បានរំលេចច្បាស់ពីស្ថាប័នតួអង្គពាក់ព័ន្ធសំខាន់ៗ រួមមានក្រុមការងារកសាងសមត្ថភាពនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និង លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ដៃគូអភិវឌ្ឍ, និង ដៃគូសហប្រតិបត្តិការ ដែលត្រូវចូលរួមអនុវត្ត ។ ទន្ទឹមនេះ ប្រភពធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺបានមកពី ថវិការដ្ឋ ក្នុងក្របខណ្ឌថវិកាកម្មវិធី និង អង្គភាពថវិកា, ថវិកាដៃគូអភិវឌ្ឍ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាដៃគូសហប្រតិបត្តិការ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដោយអនុលោមតាមការសម្រេច និង ការណែនាំជាគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង តាមលក្ខខណ្ឌនៃគម្រោងកម្មវិធីកិច្ចសហប្រតិបត្តិការនីមួយៗ និង ថវិកាបដិភាគពីស្ថាប័នទទួល សេវាកម្មបណ្តុះបណ្តាល ។

ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ នឹងដើរតួយ៉ាងសំខាន់ក្នុងការធានាថា ផែនការយុទ្ធសាស្ត្រត្រូវអនុវត្តដោយជោគជ័យ និង ទទួលបានសមិទ្ធកម្មតាមការគ្រោងទុក ។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ នឹងត្រូវតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ តាមយន្តការក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតួអង្គដឹកនាំ និង ណែនាំកម្រិតយុទ្ធសាស្ត្រ ស្របតាមគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុលោមតាមរបៀបវារៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល និង សម្របសម្រួលការអនុវត្តដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានការចូលរួមសហការពីអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលទ្ធផល និង ឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្ររបស់ខ្លួនលើការងារកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននីមួយៗ ។

ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ គឺជាត្រីវិស័យតម្រង់ទិសលើការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ ទាំងចំណេះដឹង ជំនាញ អាកប្បកិរិយា និង ឥរិយាបថបំពេញការងារ និង កសាងមូលធនមនុស្ស ប្រកបដោយការទទួលខុសត្រូវ, ភាពម្ចាស់ការ និង មានការចូលរួមដោយបុរេសកម្ម និង សកម្ម ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមនឹងកិច្ចសហការ និង

ការគាំទ្រទាំងខាងស្មារតី ហិរញ្ញវត្ថុ និង បច្ចេកទេសពីដៃគូអភិវឌ្ឍ សំដៅរួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ឱ្យសម្រេចជោគជ័យ ប្រកបដោយ ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។

ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ គឺជាឯកសាររស់ ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ស្របទៅនឹងតម្រូវការ និង បរិការណ៍ជាក់ស្តែង ដើម្បីតម្រង់ទិស និង បង្កើតលក្ខណៈអនុគ្រោះសម្រាប់ឈានទៅសម្រេចបានគោលដៅ និង ចក្ខុវិស័យដែលបានកំណត់ ។

**ការកសាង និង ការអភិវឌ្ឍសមត្ថភាព** គឺជាកត្តាគន្លឹះសម្រាប់ដោះស្រាយគ្រប់បញ្ហា និង រួមចំណែកដ៏សំខាន់ដល់ការសម្រេចជោគជ័យ នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា សំដៅចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ ។

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. សាវតា

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកជារបៀបវារៈអាទិភាពគន្លឹះមួយនៃការអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ**» គ្រប់ដំណាក់កាល និង បានក្លាយជាអាទិភាពទី ១ នៅក្នុងដំណាក់កាលទី ៣ និង ទី ៤ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការ និង ការទទួលខុសត្រូវខ្ពស់ សម្រាប់ចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ[១] ។ ក្នុងន័យនេះ ជាមួយនឹងការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំបូងនៅឆ្នាំ ២០០៤ សំដៅផ្លាស់ប្តូរប្រព័ន្ធថវិកាពីថវិកាផ្អែកលើធាតុចូល និង មជ្ឈការ ឆ្ពោះទៅថវិកាផ្អែកលើសមិទ្ធកម្ម និង វិមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ជាកត្តាចាំបាច់ដែលក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមយកចិត្តទុកដាក់ និង អនុវត្ត ប្រកបដោយបុរេសកម្ម និង មានការទទួលខុសត្រូវខ្ពស់ ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មាន ៤ ដំណាក់កាល ឈានឡើងជាជំហានៗ ជាមួយនឹងគោលបំណងជាក់លាក់ក្នុងដំណាក់កាលនីមួយៗ ពោលគឺ កសាងភាពជឿទុកចិត្តនៃថវិកា នៅដំណាក់កាលទី ១, កសាងគណនេយ្យភាពហិរញ្ញវត្ថុ នៅដំណាក់កាលទី ២ ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ នៅដំណាក់កាលទី ៣ និង គណនេយ្យភាពចំពោះសមិទ្ធកម្ម នៅដំណាក់កាលទី ៤ ។ បច្ចុប្បន្ន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅក្នុងដំណាក់កាលទី ៣ ដែលជាចំណុចរបត់ដ៏សំខាន់ និង ស្មុគស្មាញ ដោយភាពជាម្ចាស់សិទ្ធិអំណាច និង ការទទួលខុសត្រូវភាគច្រើនលើការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានផ្ទេរទៅកាន់ក្រសួង ស្ថាប័ន និង អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ ប្រការនេះ តម្រូវឱ្យគ្រប់ក្រសួងស្ថាប័ន ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ លើការពង្រឹងសមត្ថភាព និង ជំនាញវិជ្ជាជីវៈ ជូនមន្ត្រីរាជការ ជាពិសេស ក្រុមមន្ត្រីទទួលបន្ទុកគ្រប់គ្រងហិរញ្ញវត្ថុ ក្រុមមន្ត្រីទទួលបន្ទុកកិច្ចលទ្ធកម្ម ក្រុមការងារថវិកា រដ្ឋទេយ្យករ និង ភ្នាក់ងារបើកផ្តល់ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ក្នុងការរៀបចំ និង អនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានសម្រេចពន្យារពីរឆ្នាំ ក្នុងការអនុវត្តដំណាក់កាលទី ៣ និង ចាត់ទុកជាដំណាក់កាល ៣ បូក ២ ដើម្បីបញ្ចប់ការងារសេសសល់ និង រៀបចំឱ្យបានរួចរាល់នូវកិច្ចការចាំបាច់ សម្រាប់ជាមូលដ្ឋានគ្រឹះរឹងមាំ និង ប្រកបដោយការជឿទុកចិត្ត ក្នុងការឈានទៅចាប់ផ្តើមអនុវត្តដំណាក់កាលទី ៤ នៅពេលខាងមុខ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានយកចិត្តទុកដាក់ជានិច្ច លើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សំដៅរួមចំណែកគាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ការកសាងសមត្ថភាព គ្របដណ្តប់លើការកសាងក្របខណ្ឌការងារ ការកែប្រែវប្បធម៌ធ្វើការងារ ការកសាងគោលនយោបាយ

---

*[១] «**យុទ្ធសាស្ត្រចតុកោណ**» ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពៈ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០, ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលកម្ពុជា, រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ ២០១៨ ។*

ប្រព័ន្ធ និង នីតិវិធីនៅក្នុងអង្គភាព សំដៅលើកកម្ពស់ឆន្ទៈ សមត្ថភាព ជំនាញ និង ជំរុញលើកទឹកចិត្ត ការចូលរួម និង ការត្រៀមលក្ខណសម្បត្តិជាប់ជានិច្ច ដើម្បីឈានទៅសម្រេចលទ្ធផលចុងក្រោយរបស់អង្គភាពការងារ ។

ជារួម ការកសាង និង ការអភិវឌ្ឍសមត្ថភាព គឺជាកូនសោដ៏មានប្រសិទ្ធភាព សម្រាប់ដោះស្រាយគ្រប់បញ្ហា និង រួមចំណែកដ៏សំខាន់ដល់ការសម្រេចជោគជ័យ ក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល សំដៅចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ ។ ការកសាង និង ការអភិវឌ្ឍសមត្ថភាព នឹងនាំមកនូវមូលធនមនុស្សប្រកបដោយជវភាព ដែលកាត់បន្ថយគម្លាតតម្រូវការ និង ការផ្គត់ផ្គង់ជំនាញ បច្ចេកទេស និង វិជ្ជាជីវៈ, បង្កើនភាពបត់បែនចំពោះការផ្លាស់ប្តូរតម្រូវការជំនាញផ្នែករឹង, បំពាក់ជំនាញផ្នែកទន់សម្រាប់សម្រួលការងារអន្តរមុខងារឬស្ថាប័ន, និង បណ្តុះឆន្ទៈ មនសិការវិជ្ជាជីវៈ សំដៅបង្កើនការច្នៃប្រឌិត នវានុវត្តន៍ ផលិតភាព និង ប្រសិទ្ធភាព ដល់អង្គភាពការងារ ។

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មទៅជា **"ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤"** ដើម្បីឆ្លើយតបគ្រប់ជ្រុងជ្រោយ និង មានសង្គតិភាព ទាំងពេលវេលា ជំនាញវិជ្ជាជីវៈ និង ធនធាន លើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សម្រាប់ចូលរួមគាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ឱ្យសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

## ១.២. វាយតម្លៃការកសាង និង ការអភិវឌ្ឍសមត្ថភាព

ផ្អែកតាមលទ្ធផលវាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៣-២០២០ កន្លងមកបញ្ជាក់ថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលជោគជ័យត្រចះត្រចង់ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ដោយសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម ÷

**(១).** សមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់ការឆ្លើយតបតម្រូវការចាំបាច់ និង បន្ទាន់ក្នុងការរៀបចំ និង ការអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង អង្គភាពថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរ អង្គភាពនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ត្រូវបានបង្កើនជាបន្តបន្ទាប់,

**(២).** ការកំណត់សិក្ខាកាមគោលដៅបានត្រឹមត្រូវ ពោលគឺ ជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុ កំពុងបំពេញមុខងារពាក់ព័ន្ធ ស្របនឹងលក្ខខណ្ឌនៃវគ្គសិក្សា ឆ្លើយតបតម្រូវការពង្រឹងពង្រីកចំណេះដឹង និង ជំនាញវិជ្ជាជីវៈ សម្រាប់អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,

**(៣).** ការអភិវឌ្ឍ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាលបានប្រព្រឹត្តទៅដោយជោគជ័យ ពិសេស វគ្គជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង សម្រាប់ធានាប្រសិទ្ធភាព សង្គតិភាព និង ការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និង

**(៤).** ការទទួលបានកិច្ចសហការ និង ការចូលរួមពីក្រសួងស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ក្នុងការស្រាវជ្រាវ ការវាយតម្លៃតម្រូវការ និង ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការបណ្តុះបណ្តាល ដើម្បីរៀបចំផែនការកម្មវិធីលម្អិត ឯកសារ និង វិធីសាស្ត្របណ្តុះបណ្តាល បានត្រឹមត្រូវ និង ទាន់ពេល ។

លទ្ធផលខាងលើនេះ គឺជាធាតុចូលដ៏សំខាន់សម្រាប់តម្រង់ទិសការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ក្នុងដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ លើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស សម្រាប់ការកំណត់គោលបំណង និង គោលដៅ ដោយយកបញ្ហាប្រឈម និង តម្រូវការបណ្តុះបណ្តាលថ្មី ជាមូលដ្ឋានដាក់ចេញនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព និង វិធានការអនុវត្ត ស្របតាមគោលបំណងគោលនយោបាយរួម នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅពេលខាងមុខ ។

### ១.២.១. ការកសាង និង ការអភិវឌ្ឍជំនាញបច្ចេកទេសរយៈពេលមធ្យមកម្រិតវិញ្ញាបនបត្រ

ក្នុងគោលដៅកសាងប្រព័ន្ធបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ សំដៅធានាការបណ្តុះបណ្តាលប្រកបដោយគុណភាព ប្រសិទ្ធភាព និង មានលក្ខណវិជ្ជាជីវៈ សម្រាប់គាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី ៣, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង សម្រាប់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ ២០១៨ ។ កម្មវិធីបណ្តុះបណ្តាលនេះ បានកំណត់យន្តការមុតមាំលើលក្ខខណ្ឌសមត្ថភាពស្ថាប័ន សិក្ខាកាមគោលដៅ គ្រូបង្គោល មុខវិជ្ជាសិក្សា វិធីសាស្ត្រ ចំនួនម៉ោងសិក្សា វិន័យសិក្សា ការវាយតម្លៃ ការប្រឡង និង លទ្ធផលសិក្សា ។ កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានអនុវត្ត និង អភិវឌ្ឍជាបន្តបន្ទាប់ ឆ្លើយតបតម្រូវការពង្រឹងពង្រីកសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ក្នុងនោះ សិក្ខាកាមគោលដៅ ដែលជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ កំពុងបំពេញមុខងារជា ក្រុមមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ, ក្រុមមន្ត្រីទទួលបន្ទុកកិច្ចលទ្ធកម្ម, ក្រុមការងារថវិកា, គណនេយ្យករ, រដ្ឋទេយ្យករ និង ភ្នាក់ងារបើកផ្តល់ របស់ក្រសួងស្ថាប័ន មន្ទីរអង្គភាពជំនាញក្រោមឱវាទ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលការបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន: ការរៀបចំ និង ការអនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកា, ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ, ការរៀបចំកត់ត្រាចលនាឥណទាន, ការរៀបចំផែនការ និង ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង ជំនាញក្នុងការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាដើម ។ បន្ថែមពីលើវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សិក្ខាសាលាបណ្តុះបណ្តាល និង វគ្គសិក្សាអាហារូបករណ៍បរទេស, កន្លងមកនេះ ការអនុវត្តកម្មវិធីបណ្តុះបណ្តាលខាងលើ ត្រូវបានប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ក្រុមការងារកសាងសមត្ថភាព និង គ្រប់គ្រងសម្របសម្រួលដោយ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយនឹងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ ដូចមានសង្ខេបនៅក្នុងតារាង **ឧបសម្ព័ន្ធ ៧** ។

លទ្ធផលខាងលើនេះ ឆ្លុះពីការរួមចំណែកដ៏សំខាន់ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតដោះស្រាយបានរាល់ការងារចាំបាច់ចំពោះមុខ និង បន្ទាន់ និង ការរៀបចំសម្រាប់ការអនុវត្តនៅពេលខាងមុខ ស្របតាមការផ្លាស់ប្តូរ

ជាជំហានៗនៃដំណាក់កាលនីមួយៗ ។ ក្នុងនោះ ឥរិយាបថការងាររបស់មន្ត្រីរាជការមានការផ្លាស់ប្តូរ, ការងាររត់ក្នុងគន្លងភាពត្រឹមត្រូវតាមនីតិវិធីកំណត់ ហើយសម្រេចលទ្ធផលបានទាន់ពេលវេលា និង មានផលិតភាពកើនឡើងជាលំដាប់ ។ ការណ៍នេះឆ្លុះបញ្ចាំងតាមរយៈលទ្ធផលវាយតម្លៃប្រសិទ្ធភាពនៃការប្រើចំណេះដឹងពីការបណ្តុះបណ្តាលកន្លងមករបស់មន្ត្រីរាជការអតីតសិក្ខាកាម ដែលបានបង្កើនប្រសិទ្ធភាពនៃការបំពេញការងារជូនអង្គភាព ឆ្នាំ ២០១៨ និង ២០១៩ ក្នុងកម្រិតពី ៦៤,៥៧% ទៅ ៨១,១០% ។ ការវាយតម្លៃប្រសិទ្ធភាពការបណ្តុះបណ្តាល និង វិក្រឹតការនេះបានផ្តោតលើអតីតសិក្ខាកាមទទួលការបណ្តុះបណ្តាលកន្លងមក ។ ការវាយតម្លៃឆ្នាំ ២០១៨ ផ្តោតលើអតីតសិក្ខាកាមទទួលបានការបណ្តុះបណ្តាលនៅឆ្នាំ ២០១៦ និង ២០១៧ និង ការវាយតម្លៃឆ្នាំ ២០១៩ ផ្តោតលើអតីតសិក្ខាកាមនៅឆ្នាំ ២០១៨ ។ ការវាយតម្លៃទាំងនេះ បានប្រព្រឹត្តទៅតាមរយៈការសម្ភាសផ្ទាល់ជាមួយអតីតសិក្ខាកាម សហសេវិកអតីតសិក្ខាកាម និង ថ្នាក់ដឹកនាំរបស់សិក្ខាកាម ។

ការបណ្តុះបណ្តាលកន្លងមក ត្រូវបានរៀបចំឆ្លើយតបតម្រូវការបន្ទាន់របស់ក្រសួងស្ថាប័ន ក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង អង្គភាពថវិកា សំដៅអភិវឌ្ឍសមត្ថភាពជំនាញហិរញ្ញវត្ថុ ចាំបាច់សម្រាប់អនុវត្តការងារចំពោះមុខឱ្យបានទាន់ពេល ។ ចាប់ពីឆ្នាំ ២០១៨ មក ការបណ្តុះបណ្តាលត្រូវបានបង្កើនការពង្រឹងគុណភាព និង ប្រសិទ្ធភាព សម្រាប់អនុវត្តមុខងាររបស់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដោយចាប់ផ្តើមអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ក្រោមកិច្ចគាំទ្រពីសហគមន៍អឺរ៉ុប ជាមួយសូចនាករគោលដៅ ៨៥០នាក់ និង កំណើន ១០% ក្នុងមួយឆ្នាំ ។ លើមូលដ្ឋាននោះ លទ្ធផលវាយតម្លៃបញ្ជាក់ថា ឥរិយាបថការងារចាប់ផ្តើមផ្លាស់ប្តូរក្នុងទិសប្រសើរឡើង, ការងាររត់ក្នុងគន្លងភាពត្រឹមត្រូវ, ការអនុវត្តការងារតាមនីតិវិធីកំណត់បានទាន់ពេល និង មានផលិតភាពជាងមុន ។ សមិទ្ធកម្មនេះបញ្ជាក់ថា កម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពកន្លងមក បានឆ្លើយតបតម្រូវការចាំបាច់ និង ពិតជាបានរួមចំណែកជួយលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលសំដៅចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។

### ១.២.២. ការពង្រឹង និង ពង្រីកកិច្ចសហការ

ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ លើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការត្រូវបានអនុវត្តយ៉ាងសកម្ម និង រស់រវើក ។ ជាអាទិ៍ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសហការជាមួយ វិទ្យាស្ថានហិរញ្ញវត្ថុ និង អភិវឌ្ឍអាស៊ី-ប៉ាស៊ីភិច (AFDI) និង វិទ្យាស្ថានជាតិគណនេយ្យ ទីក្រុងសៀងហៃ ប្រទេសចិន, សកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង (NTU), សាលារដ្ឋបាលសាធារណៈ (CSC) និង មូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសិង្ហបុរី និង ការិយាល័យអភិវឌ្ឍសមត្ថភាពនៃមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ (CDOT), Unicef និង EU ជាដើម លើការងារបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ជូនមន្ត្រីរាជការនៃក្រសួងស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ សំដៅផ្លាស់ប្តូរបទពិសោធ និង ឧត្តមានុវត្ត ដើម្បីបង្កើនចំណេះដឹង និង ការយល់ដឹងលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយសាធារណៈ ។

ការសម្រេចបានសមិទ្ធផលខាងលើ កើតចេញពីការដឹកនាំ និង ការគាំទ្ររបស់ថ្នាក់ដឹកនាំ រួមនឹងកិច្ចសហការ និង ការចូលរួមពីដៃគូពាក់ព័ន្ធ ពិសេស ស្ថាប័នតួអង្គគន្លឹះទាំងបី នៅក្នុងចលនការប្រព័ន្ធតួអង្គកសាង និង អភិវឌ្ឍសមត្ថភាព ពោលគឺ: *(១). ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាល និង វិក្រឹតការ, (២). ស្ថាប័នទទួលសេវាបណ្តុះបណ្តាល*

*និង វិក្រឹតការ, និង (៣). ស្ថាប័នគាំទ្រដំណើរការបណ្តុះបណ្តាល និង វិក្រឹតការ* ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ។ ជារួម លទ្ធផលល្អប្រសើរក្នុងការបង្កើតប្រព័ន្ធបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ឆ្លើយតបតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ ជូនមន្ត្រីរាជការជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង និង អង្គភាពថវិកា គឺជាសមិទ្ធផលគន្លឹះដែលមានការរួមចំណែកពីការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ-អន្តរជាតិ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ សំដៅបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង ការលើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ ។

## ១.៣. ការវិភាគការងារ និង តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ

លទ្ធផលវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី ៣ ខាងលើ បង្ហាញថា ការបណ្តុះបណ្តាលមន្ត្រីរាជការជំនាញហិរញ្ញវត្ថុនៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និង អនុវត្តប្រកបដោយផ្លែផ្កា ដូចមានក្នុង **ក្រាហ្វិក ១** ខាងក្រោមនេះ ។ ការបណ្តុះបណ្តាលបានកើនឡើងជារៀងរាល់ឆ្នាំ ការពង្រឹងបន្ថែមនៃគុណភាពបណ្តុះបណ្តាល ក៏បានប្រព្រឹត្តទៅដោយជោគជ័យចាប់ពីឆ្នាំ ២០១៨ ដោយមានការគាំទ្រពីសហគមន៍អឺរ៉ុប ក្នុងការរៀបចំ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ រយៈពេលមធ្យម ផ្សារភ្ជាប់មុខងារភារកិច្ចមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ។ នៅឆ្នាំ ២០១៩ មានសិក្ខាកាមគោលដៅ ៦២០៨ នាក់ បានទទួលការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ។ នៅក្នុងនោះ វគ្គជំនាញបច្ចេកទេសរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ មានសិក្ខាកាម ១០៥៩នាក់ បានប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យ ។ ទន្ទឹមនេះ ការផ្ទុះឡើង និង ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់ដំណើរការបណ្តុះបណ្តាល ទាំងកម្មវិធីក្នុងស្រុក និង ក្រៅប្រទេស ធ្វើឱ្យលទ្ធផលអនុវត្តក្នុងអំឡុងឆ្នាំ ២០២០-២០២១ កន្លងទៅ បានធ្លាក់ចុះ ។ ប្រឈមមុខនឹងវិបត្តិនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានខិតខំដំណោះស្រាយ ដោយបុរេសកម្ម និង បានប្រែក្លាយការគំរាមនៃជំងឺកូវីដ-១៩ នេះ ជាឱកាសថ្មីក្នុងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព តាមរយៈការប្រើឧបករណ៍ និង ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ។ លទ្ធផលនេះ ឆ្លុះពីការយកចិត្តទុកដាក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុ សម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ។




| | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|
| សរុប | 3992 | 4709 | 4918 | 6208 | 1621 |
| វគ្គបណ្តុះបណ្តាលរយៈពេលខ្លី | 3992 | 4704 | 4060 | 5112 | 1320 |
| វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម | | | 850 | 1059 | 301 |
| វគ្គបណ្តុះបណ្តាលរយៈពេលវែង | | 5 | 8 | 37 | |

ជាមួយនេះ ការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដំណាក់កាលទី ៣ បានជួបបញ្ហាប្រឈមមួយចំនួន លើការគាំទ្រខាងស្មារតី បច្ចេកទេស និង ហិរញ្ញវត្ថុ ដែលមិនទាន់ឆ្លើយតបពេញលេញ តាមតម្រូវការអនុវត្តយន្តការប្រព័ន្ធតួអង្គតែមួយនៅឡើយ ។ ការណ៍នេះធ្វើឱ្យការបណ្តុះបណ្តាលកន្លងមក មិនទាន់ឆ្លើយតបពេញលេញ និង ទាន់ពេល តាមតម្រូវការនៅឡើយ ។ ក្នុងន័យនេះ របាយការណ៍ចុងក្រោយ ក្នុងឆ្នាំ ២០១៩ ស្តីពីការវាយតម្លៃការកសាង និង ការអភិវឌ្ឍសមត្ថភាព លើមុខវិជ្ជាជំនាញថវិកាកម្មវិធី និង ផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោមជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ របស់អង្គការUnicef បានលើកឡើងថា ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដំណាក់កាលទី ៣ មិនទាន់អនុវត្តពេញលេញគ្រប់ជ្រុងជ្រោយ ព្រោះថា ការបណ្តុះបណ្តាលជាក់ស្តែង បានផ្តោតការដោះស្រាយបញ្ហាបន្ទាន់របស់ក្រសួងស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។ វគ្គបណ្តុះបណ្តាលភាគច្រើនធ្វើឡើងក្នុងទម្រង់សិក្ខាសាលារយៈពេលខ្លី ។ លទ្ធផលវាយតម្លៃនេះបានអនុវត្តចំពោះការបណ្តុះបណ្តាលមុនឆ្នាំ ២០១៨ តែប៉ុណ្ណោះ ។ ដូចបានបញ្ជាក់មកខាងលើ, នៅឆ្នាំ២០១៨ កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ត្រូវបានរៀបចំ និង អនុវត្ត ក្រោមការគាំទ្រពីសហគមន៍អឺរ៉ុប និង មានសិក្ខាកាម ៦៥៧ នាក់ បានប្រឡងបញ្ចប់ការសិក្សា ដោយជោគជ័យ ក្នុងចំណោមសិក្ខាកាមគោលដៅ ៨៥០ នាក់ ដែលត្រូវបានជ្រើសរើសចូលរៀនដំបូង តាមកិច្ចព្រមព្រៀងសូចនាករគន្លឹះ របស់រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍ ។ របាយការណ៍នេះ បានស្នើឱ្យមានការបន្តកែលម្អឯកសារបណ្តុះបណ្តាល, ការរៀបចំវគ្គបំប៉នសមត្ថភាពគ្រូបង្គោល, ការរៀបចំបង្កើតករណីសិក្សាបន្ថែម ផ្សារភ្ជាប់ការអនុវត្ត ឬ ឧត្តមានុវត្ត, វិធីសាស្ត្របណ្តុះបណ្តាល ត្រូវផ្សារភ្ជាប់នឹងថ្នាលសិក្សាឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាទំនើប ។

ជារួម, របាយការណ៍វាយតម្លៃនេះ បានមើលឃើញពីសារសំខាន់នៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ សម្រាប់ការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចាំបាច់ត្រូវបន្តពង្រឹង និង ពង្រីកការអនុវត្ត និង ទទួលបាននូវកិច្ចសហការគាំទ្រ និង ការយកចិត្តទុកដាក់ថែមទៀត ទាំងផ្នែកស្មារតី បច្ចេកទេស សម្ភារ និង ហិរញ្ញវត្ថុ ។ កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនេះ កំពុងត្រូវបានអនុវត្តរហូតមកដល់បច្ចុប្បន្ន ។ សម្រាប់ទិសដៅខាងមុខ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំពុងបង្កើនការសិក្សាស្រាវជ្រាវ ការវិភាគ និង ការវាយតម្លៃថែមទៀត ដើម្បីកំណត់អាទិភាពតម្រូវការបណ្តុះបណ្តាល និង កែលម្អកម្មវិធី ឯកសារ និង វិធីសាស្ត្របណ្តុះបណ្តាល ដោយពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន មន្ទីរអង្គភាពពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និង ដៃគូអភិវឌ្ឍ សំដៅធានាគុណភាព និង ភាពប្រទាក់ក្រឡាគ្នា គ្រប់ជ្រុងជ្រោយ រវាងផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ជាមួយផែនការយុទ្ធសាស្ត្រដទៃទៀតរបស់រាជរដ្ឋាភិបាល ក្នុងក្របខណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

ម្យ៉ាងវិញទៀត យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកំណត់ទិសដៅ និងគោលដៅប្រាកដនិយម ពោលគឺកម្ពុជាជ្រើសយកប្រព័ន្ធ **"ថវិកាព័ត៌មានសមិទ្ធកម្ម"** ជាទិសដៅជាក់លាក់សម្រាប់ដំណាក់កាលទី ៤ ។ ក្នុងទិសដៅនេះ របាយការណ៍វាយតម្លៃចំណាយសាធារណៈ និង គណនេយ្យភាពហិរញ្ញវត្ថុ ថ្នាក់ជាតិឆ្នាំ ២០២០ (PEFA) បានបញ្ជាក់ថា ការពង្រឹងសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ គឺជាតម្រូវការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍ និង ការអនុវត្ត

ដោយត្រូវធ្វើបច្ចុប្បន្នកម្មកម្មវិធី ឯកសារ បច្ចេកទេស និង វិធីសាស្ត្របណ្តុះបណ្តាល ប្រកបដោយគុណភាព ឆ្លើយតបតម្រូវការអាទិភាពរបស់ក្រសួងស្ថាប័ននៅគ្រប់កម្រិត ក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ស្របនឹងបរិការណ៍គ្របដណ្តប់ និង ដំណាក់កាលផ្លាស់ប្តូរឈានឡើង នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ត្រូវបានរាជរដ្ឋាភិបាលសម្រេចពន្យារពេលអនុវត្ត ២ ឆ្នាំ ទៅជាដំណាក់កាល ៣ បូក ២ សំដៅបង្កើនការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង បញ្ចប់ការរៀបចំខ្លួនឱ្យបានរួចរាល់ ប្រកដោយភាពជឿទុកចិត្ត សម្រាប់ការចាប់ផ្តើមអនុវត្តដំណាក់កាលទី ៤ នៅពេលខាងមុខ ។ ក្នុងន័យនេះ ផ្អែកតាមផែនការសកម្មភាពរួម (CAP3+2) បានឆ្លុះឱ្យឃើញពីតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍសមត្ថភាពជំនាញសំខាន់ៗ ដូចជា: *"ការពង្រឹងមុខងារសវនកម្ម, គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្ម ទាំងសវនកម្មផ្ទៃក្រៅ និង សវនកម្មផ្ទៃក្នុង និង គោលការណ៍ណែនាំស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា, ក្របខណ្ឌព័ត៌មានសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការរៀបចំ និង អនុវត្តថវិកាសមិទ្ធកម្ម, ថវិការយៈពេលមធ្យម (Medium-term budgeting), ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម, ក្របខណ្ឌទស្សនាទានៈតាមដាន និង ត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, ប្រព័ន្ធលទ្ធកម្មសាធារណៈ និង ការគ្រប់គ្រងវិនិយោគសាធារណៈ, ការពង្រឹងបន្ថែមលើការអនុវត្តនីតិវិធីចំណាយ និង ចំណូល, យន្តការ និង នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការពង្រឹងអភិបាលកិច្ចល្អ, ភាពជាអ្នកដឹកនាំ, ការគ្រប់គ្រងការផ្លាស់ប្តូរ, និង ការពង្រឹងឆន្ទៈ ភាពជាម្ចាស់ និង ការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន"* ដើម្បីឈានទៅសម្រេចគោលបំណង និងគោលដៅចុងក្រោយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ។

ក្នុងស្មារតីនេះ ការកសាង និង ការអភិវឌ្ឍសមត្ថភាព គឺជាដំណើរការរយៈពេលវែង និង ត្រូវបន្តឥតឈប់ឈរពិសេស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងប្រឈមនឹងបញ្ហាកង្វះសមត្ថភាពមន្ត្រីជំនាញហិរញ្ញវត្ថុ ក្នុងខណៈដែលសិទ្ធិអំណាច មុខងារ និង ការទទួលខុសត្រូវលើការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុ ត្រូវបានបង្កើនជាបន្តបន្ទាប់ ។ មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈភាគច្រើន ខ្វះចំណេះដឹងជំនាញ ខ្លះបានទទួលការបណ្តុះបណ្តាលតិចតួច ខ្លះមិនទាន់បានទទួលការបណ្តុះបណ្តាលតែម្តង លើជំនាញពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ និង មានការផ្លាស់ប្តូរញឹកញាប់ដោយហេតុផលផ្សេងៗ ជាពិសេស នៅរដ្ឋបាលក្រុងស្រុក ។ ទោះបីជាមានការពង្រឹងសមត្ថភាពគ្រូបង្គោល ដែលមានការគាំទ្រពីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក៏ដោយ ក៏សមត្ថភាពមន្ត្រីជំនាញហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់សមស្របនឹងការទទួលខុសត្រូវនៅឡើយ ។

ផ្អែកតាមអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និង ធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង អនុក្រឹត្យលេខ ៦ អនក្រ.បក ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៨ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានធ្វើទំនើបកម្មការពង្រឹងប្រព័ន្ធថវិកា ដោយដាក់ឱ្យរាជធានីខេត្ត រៀបចំផែនការយុទ្ធសាស្ត្រថវិកា និង អនុវត្តថវិកាកម្មវិធី និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរតនាគាររាជធានីខេត្ត និង ដាក់ចេញនីតិវិធីពាក់ព័ន្ធ ដូចជា ច្បាប់ បទប្បញ្ញត្តិ អនុក្រឹត្យ គោលការណ៍ណែនាំ និងនីតិវិធីគ្រប់គ្រងថវិកា, គណនេយ្យសាធារណៈ និង កិច្ចលទ្ធកម្មសាធារណៈ ជាដើម ដែលទាមទារឱ្យមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវទទួលការបណ្តុះបណ្តាលបង្កើនសមត្ថភាពជំនាញប្រកបដោយវិជ្ជាជីវៈ ។

ទន្ទឹមនេះ ផ្អែកតាមការសិក្សា ការវិភាគ និង ការវាយតម្លៃអំពីតម្រូវការជំនាញ សម្រាប់អនុវត្តយុទ្ធសាស្រ្តស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ឆ្នាំ ២០១៩-២០២៥ បានបញ្ជាក់ថា កង្វះប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ គឺជាបញ្ហាប្រឈមមូលដ្ឋាន ក្នុងការពង្រឹងប្រសិទ្ធភាព នៃការរៀបចំផែនការ និង ការត្រួតពិនិត្យវាយតម្លៃការអនុវត្តគម្រោងវិនិយោគសាធារណៈ ។ លើសពីនេះ សមត្ថភាពធនធានមនុស្ស ដើម្បីសិក្សាសមិទ្ធិលទ្ធភាព, ពិនិត្យវាយតម្លៃឯកសារសមិទ្ធិលទ្ធភាព, ពិនិត្យបញ្ជីប៉ាន់តម្លៃ និង ប្លង់បច្ចេកទេសគ្រប់ជ្រុងជ្រោយនៃគម្រោងវិនិយោគសាធារណៈ នៅតាមក្រសួងស្ថាប័ន នៅមានកម្រិត ។ មន្ត្រីរាជការជំនាញពាក់ព័ន្ធការគ្រប់គ្រងវិនិយោគសាធារណៈនៅក្រសួងស្ថាប័ន សម្រាប់ដំណាក់កាលនីមួយៗនៃវដ្តជីវិតគម្រោង ពុំទាន់ឆ្លើយតបទំហំការងារបច្ចុប្បន្ន និង អនាគតនៅឡើយ ទាំងចំនួន និង សមត្ថភាពជំនាញ ដោយសារផលវិបាកនៃការរក្សាទុកមន្ត្រីរាជការមានស្រាប់ និង ប្រព័ន្ធលើកទឹកចិត្តបច្ចុប្បន្ន មិនទាន់ប្រកួតប្រជែងគ្រប់គ្រាន់ សម្រាប់ទាក់ទាញធនធានមនុស្សថ្មីៗមានសមត្ថភាព និង មានឆន្ទៈវិជ្ជាជីវៈខ្ពស់ ។ ប្រការនេះធ្វើឱ្យក្រសួងស្ថាប័ន ត្រូវបង្កើនការកសាង និង ការអភិវឌ្ឍសមត្ថភាពថែមទៀតជូនមន្ត្រីរាជការ ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ។ ក្នុងន័យនេះ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំផែនការសកម្មភាពកសាង និង អភិវឌ្ឍសមត្ថភាព ដោយបានកំណត់ច្បាស់លាស់ វិធានការយុទ្ធសាស្រ្ត បន្ទាន់ចំពោះមុខ និង សម្រាប់រយៈពេលមធ្យម និង រយៈពេលវែង សំដៅចូលរួមចំណែកពង្រឹងពង្រីកសមត្ថភាពជំនាញជូនមន្ត្រីរាជការ សម្រាប់អនុវត្តយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

ក្នុងស្មារតីនេះ ក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២១, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ ឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំវិធានជាក់លាក់មួយ សម្រាប់កម្មវិធីបណ្តុះបណ្តាលផ្សារភ្ជាប់វិញ្ញាបនបត្រ (Certificate program) និង បានណែនាំឱ្យគ្រប់ក្រសួងស្ថាប័ន យកចិត្តទុកដាក់លើការកសាង និង ការអភិវឌ្ឍសមត្ថភាព លើជំនាញហិរញ្ញវត្ថុសាធារណៈ ពិសេសសម្រាប់មន្ត្រីអនុវត្តថវិកា ដោយបានលើកទឹកចិត្តឱ្យគ្រប់ក្រសួងស្ថាប័ន ប្រើមន្ត្រីរាជការដែលបានទទួលការបណ្តុះបណ្តាល និង មានវិញ្ញាបនបត្រពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យអនុវត្តមុខងារ ភារកិច្ច ផ្សារភ្ជាប់នឹងជំនាញឯកទេសដែលទទួលបាន ។

ផ្អែកតាមទិន្នន័យលទ្ធផលនៃការសិក្សា វិភាគ វាយតម្លៃសម្រាប់ឆ្នាំ ២០១៩-២០២១ ដូចមានក្នុង **ក្រាហ្វិក ២,** តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការរបស់ក្រសួងស្ថាប័ន បានកើនឡើងក្នុងរង្វង់ប្រមាណ ១០% ក្នុងមួយឆ្នាំ ។ ប៉ុន្តែដោយសារការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ធនធានមានកម្រិត, គម្រោងផែនការបណ្តុះបណ្តាល និង វិក្រឹតការប្រចាំឆ្នាំ ដែលទទួលការគាំទ្រ ដើម្បីអនុវត្តគឺបានត្រឹម ៥០% ប៉ុណ្ណោះ ធៀបនឹងតម្រូវការប្រចាំឆ្នាំ ។ ហេតុដូច្នេះ តម្រូវការជាច្រើន ត្រូវពន្យារទៅឆ្នាំបន្ទាប់ ។ ជាក់ស្តែង ក្នុងឆ្នាំ ២០២០ តម្រូវការបណ្តុះបណ្តាលរបស់ក្រសួងស្ថាប័នមាន ៤៣៣៦

ក្រាហ្វិក ២: តម្រូវការបណ្តុះបណ្តាល និងវិក្រឹតការក្រសួង ស្ថាប័ន



| | 2019 | 2020 | 2021 |
|---|---|---|---|
| សរុប | 4269 | 4336 | 4693 |
| វគ្គបណ្តុះបណ្តាលរយៈពេលខ្លី | 3131 | 2811 | 3023 |
| វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម | 960 | 1311 | 1341 |
| វគ្គបណ្តុះបណ្តាលរយៈពេលវែង | 178 | 214 | 329 |

នាក់ ។ ផែនការបណ្តុះបណ្តាលឆ្លើយតបបានត្រឹមតែ ២០៤៥ នាក់ប៉ុណ្ណោះ ស្មើនឹង ៤៧% ហើយការអនុវត្តជាក់ស្តែង សម្រេចបានត្រឹម១៦២១នាក់ស្មើនឹង៣៧.៥%នៃតម្រូវការប្រចាំឆ្នាំដោយសារថវិកាគាំទ្រមានកម្រិតនិងការទទួលរងផលប៉ះពាល់ពីការឆ្លងរាលដាលនៃវិបត្តិជំងឺកូវីដ-១៩ ។

ចំពោះការបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រដែលបានបញ្ជាក់ខាងលើ, ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២០, មានសិក្ខាកាម ១៦៩៦ នាក់ប៉ុណ្ណោះ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ។

តារាង ១: តម្រូវការមុខវិជ្ជាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ក្រសួងស្ថាប័ន

| ល.រ | មុខវិជ្ជា | ២០១៩ | ២០២០ | ២០២១ | មធ្យម |
|---|---|---|---|---|---|
| ១ | ថវិកាកម្មវិធីនិងអង្គភាពថវិកា | ៥៩៦ | ៦៤០ | ៥៦៣ | ៦០០ |
| ២ | លទ្ធកម្មសាធារណៈ | ៣៩៧ | ៣៥៨ | ៤០៨ | ៣៨៨ |
| ៣ | គណនេយ្យសាធារណៈ | ៤២៨ | ៣៥៣ | ៤៦៥ | ៤១៥ |
| ៤ | ការគ្រប់គ្រងបញ្ជីសារពើពន្ធទ្រព្យសម្បត្តិរដ្ឋ | ៣៣៣ | ៣៨៣ | ៤១៧ | ៣៧៨ |
| ៥ | សវនកម្មផ្ទៃក្នុង | ៤២១ | ២៨៦ | ៣៧៥ | ៣៦១ |
| ៦ | កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៣១៨ | ៤១៧ | ៤៤៣ | ៣៩៣ |

លទ្ធផលនេះបញ្ជាក់ថា ការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទើបសម្រេចបាន១៨.៣២% (១៨.៣២% = ១៦៩៦÷[៩២៦ X ១០]) ធៀបនឹងសិក្ខាកាមគោលដៅនៃអង្គភាពថវិកាសរុប ៩២៦ នៅទូទាំងប្រទេស ក្នុងឆ្នាំ ២០២១ យោងតាមទិន្នន័យពីអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ការប៉ាន់ស្មានផ្អែកតាមស្មារតីប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ។ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស កន្លងមក អនុវត្តបានតែចំពោះសិក្ខាកាមពីក្រសួងស្ថាប័នប៉ុណ្ណោះ ។ ចំណែកសិក្ខាកាមគោលដៅ ពីគ្រឹះស្ថានរដ្ឋបាលសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ពុំទាន់ទទួលសេវានេះទេ ។ ចំពោះមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ នៅរាជធានី ខេត្ត, ក្នុងឆ្នាំ ២០២០ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសិក្សា វិភាគ និង វាយតម្លៃលទ្ធភាពរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសជូនដល់កន្លែង ដើម្បីចំណេញពេល និង សន្សំថវិកាជាតិ ប៉ុន្តែ ការបណ្តុះបណ្តាលជាក់ស្តែង មិនទាន់អាចអនុវត្តបាននៅឡើយ ដោយសារផលប៉ះពាល់ពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

ផ្អែកតាមការវាយតម្លៃក្នុងឆ្នាំ ២០២១ បង្ហាញថា តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានទិន្នន័យគួរឱ្យកត់សម្គាល់គឺ: (១). តម្រូវការបណ្តុះបណ្តាលរយៈពេលខ្លី ២៧៩៦ នាក់, (២). តម្រូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ១២៦៧ នាក់ និង(៣). តម្រូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលវែង កម្រិតសញ្ញាបត្រ ៦៥ នាក់ ។ តាមការវិភាគទិន្នន័យទាំងនោះ បង្ហាញថា និន្នាការតម្រូវការមុខវិជ្ជាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានកម្រិតខ្ពស់ ពិសេស មុខវិជ្ជាថវិកាកម្មវិធី និង អង្គភាពថវិកា, គណនេយ្យសាធារណៈ, លទ្ធកម្មសាធារណៈ និង ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ មុខវិជ្ជាស្តីពីការស្វែងយល់ពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏មានតម្រូវការកើនឡើងគួរឱ្យកត់សម្គាល់ ដូចមាននៅក្នុង **ក្រាហ្វិក ៣** ខាងលើ ។ ទន្ទឹមនេះ តាមរបាយការណ៍លទ្ធផលធ្វើសម្ភាសផ្ទៀងផ្ទាត់ទិន្នន័យតម្រូវការ និង ប្រសិទ្ធភាពការបណ្តុះបណ្តាល នៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត និង មន្ទីរជំនាញមួយចំនួន នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប និង ឧត្តរមានជ័យ បង្ហាញថា ការទទួលបានសេវាបណ្តុះបណ្តាល

និង វិក្រឹតការកន្លងមកនៅមានកម្រិត សម្រាប់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ។ ការវាយតម្លៃនេះរកឃើញចំនួនមន្ត្រីទទួលបន្ទុក និង គាំទ្រ ពុំទាន់ឆ្លើយតបទំហំការងារជាក់ស្តែង, សមត្ថភាពមន្ត្រីក្រោមឱវាទ ជាពិសេស មន្ទីរជំនាញ នៅមានកម្រិត, ការផ្លាស់ប្តូរមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈកើតមានញឹកញាប់ធ្វើឱ្យប៉ះពាល់ការអនុវត្តការងារ និង ទាមទារការបណ្តុះបណ្តាលមន្ត្រីថ្មីបន្តទៀត ។ លើសពីនោះ




ទិសដៅអនាគត មន្ទីរជំនាញទាំងអស់ នឹងត្រូវអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ ២០២៤ តទៅ ។ ការណ៍នេះនាំឱ្យតម្រូវការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ គឺជាមូលដ្ឋានចាំបាច់ ដើម្បីទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេសFMIS ពេលប្រព័ន្ធនោះត្រូវបានបំពាក់រួចរាល់ ។ ជារួម មានតែមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រតនាគារខេត្តប៉ុណ្ណោះ ដែលអាចប្រើប្រព័ន្ធ FMIS ចំណែកមន្ទីរជំនាញនៅមានបញ្ហាប្រឈមខ្ពស់ ព្រោះខ្វះធនធានមនុស្ស សម្ភារបរិក្ខារ និង សមត្ថភាពអ៊ីនធើណិតគាំទ្រដែលទុកចិត្តបាន ។

ផ្អែកតាមការសិក្សា ការវិភាគ និង ការវាយតម្លៃទាំងអស់ខាងលើបញ្ជាក់ថា ការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុរបស់ក្រសួងស្ថាប័ន និង រដ្ឋបាលក្រោមជាតិ ដើម្បីឆ្លើយតបតម្រូវការនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ គឺត្រូវផ្តោតទៅលើមុខជំនាញពាក់ព័ន្ធនឹង *«ក្របខណ្ឌព័ត៌មានសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម, ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម, ក្របខណ្ឌទស្សនទាននៃការតាមដាន និង ការត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, ប្រព័ន្ធលទ្ធកម្មសាធារណៈ, ការពង្រឹងមុខងារសវនកម្ម, គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្ម ទាំងសវនកម្មផ្ទៃក្រៅ និង សវនកម្មផ្ទៃក្នុង និង គោលការណ៍ណែនាំស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា, ការគ្រប់គ្រងវិនិយោគសាធារណៈ និង ការពង្រឹងបន្ថែមលើការអនុវត្តនីតិវិធីចំណាយ និង ចំណូល, យន្តការ និង នីតិវិធីអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការពង្រឹងអភិបាលកិច្ចល្អ, ភាពជាអ្នកដឹកនាំ, ការគ្រប់គ្រងការផ្លាស់ប្តូរ និង ការបណ្តុះឆន្ទៈ ភាពជាម្ចាស់ និង ការទទួលខុសត្រូវ របស់ក្រសួងស្ថាប័នចំពោះការកែទម្រង់»* ។ ក្នុងនោះ មុខវិជ្ជាសំខាន់ៗ ដូចជា: ថវិកាកម្មវិធី និង អង្គភាពថវិកា, ថវិកាព័ត៌មានសមិទ្ធកម្ម, លទ្ធកម្មសាធារណៈ, គណនេយ្យសាធារណៈ, សវនកម្ម, ការយល់ដឹងពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, ការគ្រប់គ្រង និង ការវិភាគទិន្នន័យ, ការគ្រប់គ្រងសាច់ប្រាក់, ការគ្រប់គ្រងហានិភ័យ, ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ និង ប្រព័ន្ធព័ត៌មានវិទ្យា ដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ជាដើម ចាំបាច់ត្រូវបញ្ចូលក្នុងផែនការបណ្តុះបណ្តាល និង អនុវត្តឱ្យមានប្រសិទ្ធភាព ។

ក្នុងន័យនេះ មន្ត្រីរាជការជំនាញហិរញ្ញវត្ថុ ដែលទទួលមុខងារជា រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករចំណូល, គណនេយ្យករ, មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ, មន្ត្រីទទួលបន្ទុកកិច្ចលទ្ធកម្មសាធារណៈ, មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, សវនករផ្ទៃក្នុង, មន្ត្រីគម្រោងវិនិយោគសាធារណៈ និង មន្ត្រីគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ប្រកបដោយគុណភាព និង ប្រសិទ្ធភាព តាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ដើម្បីអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា និង យុទ្ធសាស្ត្រពាក់ព័ន្ធ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

## ១.៤. កត្តាកំណត់ជោគជ័យនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព

បទពិសោធន៍វិជ្ជមាន ដែលអាចដកស្រង់ជាកត្តាកំណត់ជោគជ័យ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ សម្រាប់ជាមេរៀន និង ជាធាតុចូល ដើម្បីរៀបចំ **«ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤»** គឺផ្អែកតាមលទ្ធផលនៃការវិភាគ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ការគំរាម (SWOT) ដូចមានក្នុងតារាងសង្ខេបខាងក្រោម÷

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| - ការយកចិត្តទុកដាក់ ការគាំទ្រ និង ការលើកទឹកចិត្តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,<br>- ស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាល និងវិក្រឹតការមានរចនាសម្ព័ន្ធគ្រប់គ្រងជាក់លាក់ គុណវុឌ្ឍិរឹងមាំ ឆន្ទៈប្តូរផ្តាច់ ជំនាញ និង មានពិសោធន៍ ក្នុងការងារបណ្តុះបណ្តាល និងវិក្រឹតការ,<br>- កិច្ចសហការល្អរវាងស្ថាប័នទទួលបន្ទុកបណ្តុះបណ្តាលជាមួយគ្រប់តួអង្គ និង ដៃគូពាក់ព័ន្ធ សម្រាប់ការងារបណ្តុះបណ្តាល និង វិក្រឹតការ,<br>- ប្រភពហិរញ្ញវត្ថុច្បាស់លាស់ (ថវិកាជាតិ, ថវិកាដៃគូ) គាំទ្រការអនុវត្តផែនការ និង គម្រោងកម្មវិធីពាក់ព័ន្ធ,<br>- ការរៀបចំ និង ការអនុវត្តបានទូវការបណ្តុះបណ្តាល និង វិក្រឹតការមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ជូនសិក្ខាកាម និង គ្រូបង្គោល,<br>- ការរៀបចំ និង ការអនុវត្តត្រឹមត្រូវ យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ការវាយតម្លៃតម្រូវការ និង ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការ, | - ធនធានគ្រូនៅមានកម្រិត ទាំងចំនួន និង ពេលវេលាចូលរួមអនុវត្តការបណ្តុះបណ្តាល ពិសេសចំពោះគ្រូមុខវិជ្ជាអនុវត្ត ដោយជាប់បំពេញភារកិច្ចស្នូល នាំឱ្យចង្អៀតពេលចូលរួមបណ្តុះបណ្តាលសិក្ខាកាមដែលធ្វើឱ្យការអនុវត្តកម្មវិធីបណ្តុះបណ្តាល ត្រូវប្រឈមនឹងការពន្យារពេល ជាយថាហេតុ,<br>- សម្ភារ និង បរិក្ខារឧបទេសគាំទ្រការបណ្តុះបណ្តាលពុំទាន់ឆ្លើយតបពេញលេញតាមតម្រូវការបច្ចេកទេស និងវិធីសាស្ត្របណ្តុះបណ្តាលជំនាញក្នុងបរិបទទំនើប,<br>- សមត្ថភាពស្ថាប័ន និង ធនធានមនុស្សរបស់ស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាល នៅមិនទាន់គ្រប់គ្រាន់ដែលទាមទារបន្តការគាំទ្រ និង ការអភិវឌ្ឍបន្ថែម,<br>- ត្រូវការជំនាញការ សម្រាប់អភិវឌ្ឍកម្មវិធីសិក្សាថ្មីៗ នវានុវត្តវិធីបង្រៀន ឱ្យទាន់សភាពការណ៍វិវឌ្ឍ នៃបច្ចេកវិទ្យា និង បរិការណ៍នៃការអភិវឌ្ឍជំនាញថ្មីៗ,<br>- យន្តការសម្របសម្រួលការអនុវត្ត និង គោលការណ៍ណែនាំប្រតិបត្តិ (Operational manual) ចាំបាច់ត្រូវកែលម្អឱ្យបានគត់មត់ និង ច្បាស់លាស់, |

| | |
|---|---|
| - ការរៀបចំបានបណ្តើរៗហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ការគ្រប់គ្រងសន្និធិចំណេះដឹង និង បណ្ណាល័យ សម្រាប់គាំទ្រសកម្មភាពកសាង និង អភិវឌ្ឍសមត្ថភាព,<br>- មានផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ជាផែនទីចង្អុលផ្លូវលើការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ | - ការបណ្តុះបណ្តាលផ្ទៃក្នុង ពិសេសជំនាញទន់ ដើម្បីលើកកម្ពស់សមត្ថភាពអនុវត្តការងារ ផលិតភាព និង គុណភាពការងារនៅមានកម្រិត,<br>- ការគាំទ្រថវិកា និង ស្មារតី មិនទាន់គ្រប់គ្រាន់ ហើយកិច្ចសហការពីតួអង្គពាក់ព័ន្ធ នៅមានកម្រិត ទាំងតួអង្គទទួលសេវា និង តួអង្គគាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការ ។ |
| **ការគំរាម** | **ឱកាស (ភាពលានុវត្ត)** |
| - ការគំរាមជាប្រធានសំក្តិដូចជំងឺកូវីដ-១៩ ធ្វើឱ្យការបណ្តុះបណ្តាលត្រូវអាក់ខាន និង ត្រូវពន្យារពេល,<br>- សមត្ថភាពស្ថាប័នខាងព័ត៌មានវិទ្យា រួមទាំង សម្ភារបរិក្ខារគាំទ្រ និង សមត្ថភាពអ៊ីនធើណិតមានកម្រិត ជះឥទ្ធិពលលើការបណ្តុះបណ្តាលតាមប្រព័ន្ធពីចម្ងាយ,<br>- ការប្រើឬតែងតាំងមន្ត្រីខ្វះគុណវុឌ្ឍិសមស្របលើមុខងារពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,<br>- ការចាត់សិក្ខាកាមចូលរួមវគ្គសិក្សា មិនទាន់ឆ្លើយតបសំណូមពរ និង លក្ខខណ្ឌនៃវគ្គសិក្សា,<br>- សិក្ខាកាមទទួលភារកិច្ចផ្សេង អំឡុងពេលវគ្គសិក្សា ធ្វើឱ្យអវត្តមានលើសកំណត់ (បោះបង់ឬព្យួរការសិក្សា),<br>- ការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ធ្វើឱ្យអតីតសិក្ខាកាមទទួលការបណ្តុះបណ្តាលរួចមិនអាចប្រើចំណេះបានចំទិសដៅ ពេញលេញ មានប្រសិទ្ធភាព,<br>- សំណើបណ្តុះបណ្តាលវគ្គពិសេស សម្រុកចុងឆ្នាំ និង ដោយឡែកៗ បង្កើតសម្ពាធដល់ការអនុវត្ត និង នាំឱ្យមានមន្ទិលលើគុណភាព និង ប្រសិទ្ធភាព,<br>- សិក្ខាកាមមួយចំនួន ខ្វះចំណេះដឹងមូលដ្ឋានពាក់ព័ន្ធជំនាញហិរញ្ញវត្ថុសាធារណៈ ធ្វើឱ្យពិបាកចាប់យកចំណេះជំនាញនៅក្នុងវគ្គសិក្សា,<br>- តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ របស់ក្រសួងស្ថាប័ន ស្នើឡើងប្រចាំឆ្នាំ លើសលទ្ធភាពថវិកាគាំទ្រ និង ធនធានស្ថាប័នមាន ធ្វើឱ្យការឆ្លើយតបមិនទាន់គ្រប់ជ្រុងជ្រោយ និង ទាន់ពេលតាមតម្រូវការ ។ | - មានការគាំទ្រលើការបណ្តុះបណ្តាលជាអាទិភាព ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** លើការរៀបចំការបណ្តុះបណ្តាល កម្រិតវិញ្ញាបនបត្រ (Certificate Programs),<br>- មានការគាំទ្រ និង ការជំរុញ ក្នុងការរៀបចំឯកសារគតិយុត្ត សម្រាប់កំណត់គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ និង លក្ខណសម្បត្តិសិក្ខាកាមសម្រាប់កម្មវិធីបណ្តុះបណ្តាលផ្សារភ្ជាប់វិញ្ញាបនបត្រ,<br>- មានការបញ្ចូលការកសាង និង ការអភិវឌ្ឍសមត្ថភាព និង គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មី,<br>- មានស្ថាប័នទទួលបន្ទុកផ្តល់សេវាបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួងស្ថាប័ន និង មន្ទីរអង្គភាព ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ,<br>- មានការគាំទ្រ និង ជំរុញការរៀបចំកម្មវិធីសិក្សាកម្រិតសញ្ញាបត្រ ដើម្បីលើកទឹកចិត្តមន្ត្រីរាជការដែលទទួលបានការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ,<br>- មានដៃគូសហប្រតិបត្តិការជាតិ-អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ លើការរៀបចំការបណ្តុះបណ្តាល និង ការស្រាវជ្រាវ ពិសេស សម្រាប់អភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្រ បច្ចេកទេស និង ឯកសារមេរៀន និង ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និង បរិក្ខារសម្រាប់គាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ។ |

ផ្អែកតាមការសិក្សា ការវិភាគ និង ការវាយតម្លៃលទ្ធផលអនុវត្តកន្លងមក ដូចមានសង្ខេបក្នុងតារាងខាងលើ បង្ហាញឱ្យឃើញនូវកត្តាកំណត់ជោគជ័យ នៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព សម្រាប់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ដូចខាងក្រោម ÷

- ការបន្តយកចិត្តទុកដាក់ខ្ពស់ ការគាំទ្រ និង ការលើកទឹកចិត្តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើគោលដៅ និង ទិសដៅអាទិភាពនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព សំដៅគាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព,
- ស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាល និង វិក្រឹតការ មានរចនាសម្ព័ន្ធគ្រប់គ្រងជាក់លាក់, មានគុណវុឌ្ឍិរឹងមាំ, មានឆន្ទៈមុតមាំ និង ប្តូរផ្តាច់, មានជំនាញ និង បទពិសោធន៍ពិតប្រាកដ ក្នុងការរៀបចំ និង ការអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការសម្រាប់មន្ត្រីរាជការ,
- ស្ថាប័នទទួលបន្ទុកការបណ្តុះបណ្តាល មានកិច្ចសហការល្អជាមួយ អង្គភាពជំនាញពាក់ព័ន្ធ ក្រោមឱវាទកសហវ, ក្រសួងស្ថាប័ន និង មានទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា និង ស្ថាប័នដៃគូជាតិ-អន្តរជាតិ លើការងារស្រាវជ្រាវ និង ការអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ សិក្ខាសាលា និង ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍,
- ប្រភពហិរញ្ញវត្ថុច្បាស់លាស់ គឺពី ថវិកាជាតិ, ថវិកាដៃគូអភិវឌ្ឍ និង ថវិកាដៃគូសហប្រតិបត្តិការ សម្រាប់គាំទ្រការអនុវត្តផែនការ និង គម្រោងកម្មវិធីពាក់ព័ន្ធ,
- ការរៀបចំ និង ការអនុវត្តបាននូវកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ជូនសិក្ខាកាម និង គ្រូបង្គោល,
- ការរៀបចំ និង ការអនុវត្តបានល្អនូវ យន្តការតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ, ការវាយតម្លៃតម្រូវការ, ការតាមដានត្រួតពិនិត្យវាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការ, និង
- ការរៀបចំបាននូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង និង បណ្ណាល័យ សម្រាប់គាំទ្រសកម្មភាពការងារកសាង និង អភិវឌ្ឍសមត្ថភាព ។

## ១.៥.បញ្ហាប្រឈម និង ដំណោះស្រាយនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ, ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ កន្លងមក បានជួបនឹងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម÷

- តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ ស្នើដោយក្រសួងស្ថាប័ន លើសលទ្ធភាពថវិកាគាំទ្រ និង ធនធានដែលមាន សម្រាប់ការឆ្លើយតបឱ្យបានគ្រប់គ្រាន់ និង ទាន់ពេល,
- ការចាត់បញ្ជូនសិក្ខាកាមចូលរួមការបណ្តុះបណ្តាល មិនទាន់ឆ្លើយតបតាមសំណូមពរ និង លក្ខខណ្ឌនៃវគ្គសិក្សា ។ សិក្ខាកាមខ្លះទទួលភារកិច្ចផ្សេងទៀតពីអង្គភាពសាមី ក្នុងអំឡុងពេលចូលរួមវគ្គសិក្សា,
- ការផ្លាស់ប្តូរតួនាទីភារកិច្ច មន្ត្រីរាជការតាមអង្គភាពសាមី ធ្វើឱ្យសិក្ខាកាមមិនអាចប្រើចំណេះជំនាញចំទិសដៅ មានប្រសិទ្ធភាព និង ចាំបាច់ត្រូវបណ្តុះបណ្តាលថែមទៀតសម្រាប់មន្ត្រីរាជការចូលថ្មី,
- សំណើសុំបណ្តុះបណ្តាលប្រភេទវគ្គពិសេសរបស់ក្រសួងស្ថាប័ន សម្រុកនៅចុងឆ្នាំ និង ធ្វើឡើងដោយឡែកៗ បង្កើតសម្ពាធដល់ការរៀបចំអនុវត្ត ដែលមានឥទ្ធិពលដល់គុណភាព និង ប្រសិទ្ធភាព,

- ធនធានគ្រូបង្គោលមានកម្រិត ទាំងចំនួន និង ពេលវេលា សម្រាប់ចូលរួមបណ្តុះបណ្តាល ពិសេសចំពោះគ្រូមុខវិជ្ជាអនុវត្ត ដោយគ្រូភាគច្រើនជាប់ភារកិច្ចស្នូល ចំពេលត្រូវចូលរួមបណ្តុះបណ្តាល ។ ការណ៍នេះធ្វើឱ្យកម្មវិធីបណ្តុះបណ្តាល ត្រូវប្រឈមនឹងការពន្យារពេល, និង
- សម្ភារគាំទ្រ និង បរិក្ខារឧបទេសសិក្សា ពុំទាន់គ្រប់គ្រាន់ ឆ្លើយតបពេញលេញទៅនឹងតម្រូវការបច្ចេកទេស និង វិធីសាស្ត្របណ្តុះបណ្តាលជំនាញ ក្នុងបរិបទទំនើបនៅឡើយ ។

ដើម្បីដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដូចខាងលើ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានការចាំបាច់ត្រូវ ÷

- រៀបចំវិធានកំណត់គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដែលជាសិក្ខាកាមគោលដៅសម្រាប់វគ្គបណ្តុះបណ្តាល ជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង,
- ជ្រើសរើស និង បណ្តុះបណ្តាលបំប៉នសមត្ថភាព ជាគ្រូបង្គោលអចិន្ត្រៃយ៍របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិសេស មន្ត្រីចូលនិវត្តដែលមានបទពិសោធន៍ និង សក្តានុពលសម្រាប់ការងារស្រាវជ្រាវ បណ្តុះបណ្តាល និង វិក្រឹតការ ដើម្បីឱ្យមានធនធានគ្រូបង្គោលគ្រប់គ្រាន់ តាមសេចក្តីត្រូវការ, និង
- បង្កើនវិនិយោគលើការអភិវឌ្ឍស្ថាប័នផ្តល់សេវាបណ្តុះបណ្តាល ដើម្បីឱ្យមានហេដ្ឋារចនាសម្ព័ន្ធ សម្ភារគាំទ្រ បរិក្ខារឧបទេស និង ធនធានហិរញ្ញវត្ថុ គ្រប់គ្រាន់ សម្រាប់គាំទ្រ និង អនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ជូនសិក្ខាកាម និង គ្រូបង្គោល ។

## ១.៦. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព

ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ គឺជាកិច្ចការសំខាន់មួយនៃការងារគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ និង មានតួនាទីជាស្នូល សម្រាប់តម្រង់ទិសការពង្រឹងប្រព័ន្ធបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ សំដៅលើកកម្ពស់ការយល់ដឹង ចំណេះដឹង សមត្ថភាព និង ជំនាញបច្ចេកទេស ជូនសិក្ខាកាមគោលដៅ ។

គោរពតាមការសម្រេចដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រោមការដឹកនាំ និង ណែនាំផ្ទាល់ពី **ឯកឧត្តមបណ្ឌិតសភាចារ្យ ម៉ារ៉ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាពនៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ ត្រូវបានរៀបចំឡើង ផ្អែកលើលទ្ធផលនៃការសិក្សា ស្រាវជ្រាវ វិភាគ ពិនិត្យវាយតម្លៃលើរបាយការណ៍ ព័ត៌មាន ទិន្នន័យពីការធ្វើសម្ភាស សិក្ខាសាលាពិគ្រោះយោបល់ និង កិច្ចប្រជុំត្រួតពិនិត្យកែលម្អជាច្រើនលើកជាមួយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងស្ថាប័ន មន្ទីរ អង្គភាព និង តួអង្គពាក់ព័ន្ធ រួមទាំងស្ថាប័នដៃគូជាតិ-អន្តរជាតិ ដែលមានជាអាទិ៍÷

- ការវិភាគលើលទ្ធផលនៃការវាយតម្លៃការអនុវត្តការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៣-២០២០ និង លទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ របស់ក្រសួងស្ថាប័ន និង មន្ទីរ អង្គភាពពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់រយៈពេលប្រាំឆ្នាំ ២០២១-២០២៥ ។
- ការសិក្សាវិភាគលើរបាយការណ៍បូកសរុបប្រចាំឆ្នាំ នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈ ពីឆ្នាំ ២០១៦ ដល់ ២០២០ និង របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម (CAP3) នៃកម្មវិធីកែទម្រង់ការគ្រងគ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ដោយមានជំនួយបច្ចេកទេសពីជំនាញការកសាងសមត្ថភាព (Capacity Building Technical Consultant) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- ការធ្វើសម្ភាសជាមួយថ្នាក់ដឹកនាំ និង មន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ ក្រសួងស្ថាប័ន និង មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធជុំវិញខេត្ត កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប និង ឧត្តរមានជ័យ លើតម្រូវការ និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និង វិក្រឹតការ ។
- ការប្រជុំពិភាក្សា និង ពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលដំបូង ជាមួយស្ថាប័ន ជាដៃគូអភិវឌ្ឍពាក់ព័ន្ធ ដូចជា EU, WB, ADB និង Unicef ។
- ការធ្វើសម្ភាសជាមួយថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃ កសហវ ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពពាក់ព័ន្ធ ដែលជាអតីតសិក្ខាកាមវគ្គសិក្សាចន្លោះឆ្នាំ ២០១៣-២០១៩ ដើម្បីសិក្សាពីប្រសិទ្ធភាពនៃការប្រើចំណេះដឹង និង បញ្ហាប្រឈមពាក់ព័ន្ធ ដែលជាធាតុចូល ក្នុងការតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ពេលខាងមុខ ។
- សិក្ខាសាលាពិគ្រោះយោបល់ជាមួយតំណាងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ ក្រសួងស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃរាជធានីខេត្តទាំង ២៥ រួមទាំង ដៃគូអភិវឌ្ឍ ដូចខាងលើ ដើម្បីពិគ្រោះ ពិភាក្សា ផ្តល់យោបល់ និង ប្រមូលធាតុចូលបន្ថែម សំដៅកែលម្អសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ ។
- កិច្ចប្រជុំពិគ្រោះ ពិភាក្សាជាមួយក្រុមគ្រូបង្គោល និង គ្រូឧទ្ទេសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីប្រមូលមតិយោបល់ជាធាតុចូល និង ពិនិត្យកែលម្អបន្ថែម ។
- ការប្រជុំចង្អៀតជាមួយ តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានពាក់ព័ន្ធសំខាន់ៗ នៃ កសហវ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញ នូវព័ត៌មាន និង ទិន្នន័យអំពីតម្រូវការបណ្តុះបណ្តាល និង ធ្វើសមកាលកម្មក្របខណ្ឌពេលវេលា និង មុខជំនាញ តម្រឹមនឹងដំណាក់កាលថ្មី នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ការប្រជុំពិគ្រោះយោបល់ជាលើកទីពីរជាមួយតំណាងដៃគូអភិវឌ្ឍ: EU, WB, ADB, Unicef, និង IMF/CDOT តាមវីដេអូ Zoom Conference ដើម្បីប្រមូលមតិយោបល់ និង ការគាំទ្របន្ថែមលើសេចក្តីព្រាងលើកទី ៣ ។
- ការសិក្សា វិភាគ និង សំយោគនូវមតិយោបល់ជាលាយលក្ខណ៍អក្សរពីដៃគូសហការជាតិ-អន្តរជាតិ ដូចជា សាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ វិទ្យាស្ថានហិរញ្ញវត្ថុ និង អភិវឌ្ឍអាស៊ី-ប៉ាស៊ីភិចទីក្រុងសៀងហៃ សាលារដ្ឋបាលសាធារណៈ និង សកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង ប្រទេសសិង្ហបុរី លើបទពិសោធន៍ និង ឧត្តមានុវត្តន៍ នៃការកសាង និង ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ក្នុងវិស័យសាធារណៈ ។
- ការពិនិត្យ ផ្ទៀងផ្ទាត់ និង សំយោគរាល់មតិយោបល់បន្ថែម របស់សមាជិកក្រុមការងារកសាងសមត្ថភាព លើសេចក្តីព្រាងលើកទី ៤ ដើម្បីកែលម្អ និង សម្រិតសម្រាំងសេចក្តីព្រាងចុងក្រោយ ។

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ កើតចេញពីការចូលរួមមតិយោបល់ជាធាតុចូលទូលំទូលាយពីតួអង្គ និង ដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ រួមនឹងការសិក្សា វិភាគ និង វាយតម្លៃលើគ្រប់ទិដ្ឋភាព

ដែលអាចមានបច្ច័យដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ផែនការយុទ្ធសាស្ត្រនេះ ផ្តោតអាទិភាពលើការអភិវឌ្ឍសមត្ថភាពជំនាញកោសល្យឯកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការពង្រឹងពង្រីកវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព សម្រាប់គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង គណនេយ្យភាពសមិទ្ធកម្ម តាមអភិក្រមជាយុទ្ធសាស្ត្រ ដូចខាងក្រោម ÷

(១). រៀបចំវិធានគាំទ្រការបណ្តុះឆន្ទៈ និង ការចូលរួមកសាង និង អភិវឌ្ឍសមត្ថភាព,

(២). បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស,

(៣). ពង្រឹងកិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គតែមួយ គាំទ្រការងារកសាង និង អភិវឌ្ឍសមត្ថភាព,

(៤). ពង្រឹងពង្រីកការស្រាវជ្រាវ និង ការអភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ, និង

(៥). ពង្រឹងការវាយតម្លៃតម្រូវការ និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង វិធីសាស្ត្របណ្តុះបណ្តាលស្របតាមតម្រូវការ និង ផ្អែកតាមស្មារតីនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា លទ្ធកម្មសាធារណៈ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គ្រប់គ្រងវិនិយោគសាធារណៈ និង យុទ្ធសាស្ត្រកៀរគរចំណូល ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ៕

# ជំពូក ២
# ក្របខណ្ឌយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព

## ២.១. ចក្ខុវិស័យ

មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ទទួលការបណ្តុះបណ្តាល និង ការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ចូលរួមអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ សំដៅបង្កើនប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ក្នុងការបម្រើសេវាសាធារណៈ ជូនប្រជាពលរដ្ឋ ។

## ២.២. បេសកកម្ម

ស្រាវជាវ អភិវឌ្ឍ និង អនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមដំណាក់កាល និង បរិការណ៍ ដោយផ្តោតលើសកម្មភាពគន្លឹះ ដូចខាងក្រោម ÷

- ផ្តល់សេវាបណ្តុះបណ្តាល និង វិក្រឹតការ កម្រិតវិញ្ញាបនបត្រ និង សញ្ញាបត្រ លើមុខជំនាញពាក់ព័ន្ធសេដ្ឋកិច្ច ហិរញ្ញវត្ថុ អភិបាលកិច្ច និង បច្ចេកវិទ្យាព័ត៌មាន,
- រៀបចំ និង អនុវត្តវិធានកំណត់គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ជាសិក្ខាកាមគោលដៅនៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង,
- អភិវឌ្ឍសមត្ថភាពស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង បណ្ណាល័យ និង ធនធានមនុស្ស សម្រាប់ការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ,
- រៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ រួមនឹង សិក្ខាសាលា ការបោះពុម្ព ការផ្សព្វផ្សាយ ទស្សនកិច្ចសិក្សា និង កម្មវិធីផ្លាស់ប្តូរបទពិសោធន៍,
- សិក្សាស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តការវាយតម្លៃតម្រូវការ ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃ និង វិធីសាស្ត្រ និង បច្ចេកទេសបណ្តុះបណ្តាល និង វិក្រឹតការ, និង
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ជូនមន្ត្រីរាជការដែលមានសក្តានុពលលូតលាស់ និង មានឆន្ទៈកែទម្រង់ខ្ពស់ ដោយសហការជាមួយគ្រឹះស្ថានសិក្សាអប់រំជាតិ-អន្តរជាតិ សម្រាប់ទិសដៅរយៈពេលវែង ។

## ២.៣. គោលបំណង

អភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញតួនាទីភារកិច្ច ប្រកបដោយសុឆន្ទៈ ការទទួលខុសត្រូវ និង ភាពម្ចាស់ការ ក្នុងការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង គណនេយ្យភាពសមិទ្ធកម្ម តាមរយៈការស្រាវជ្រាវ ការអភិវឌ្ឍ និង ការអនុវត្តការបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ។

## ២.៤. គោលដៅ

តម្រង់ទិសការអនុវត្តបេសកកម្ម សំដៅឈានទៅសម្រេចគោលបំណងនៃការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើសកម្មភាពគន្លឹះៗ ដូចខាងក្រោម ÷

**(១).** ផ្តល់សេវាបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ និង សញ្ញាបត្រ លើជំនាញពាក់ព័ន្ធសេដ្ឋកិច្ច ហិរញ្ញវត្ថុ

អភិបាលកិច្ច និង បច្ចេកវិទ្យាព័ត៌មាន,

(២). លើកកម្ពស់ស្មារតី និង ឆន្ទៈចូលរួម គាំទ្រការងារកសាង និង អភិវឌ្ឍសមត្ថភាព មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ,

(៣). ពង្រឹង និង អភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស,

(៤). រៀបចំ និង អនុវត្តការបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ រួមនឹង សិក្ខាសាលា ការបោះពុម្ព ការផ្សព្វផ្សាយ ទស្សនកិច្ចសិក្សា និង កម្មវិធីផ្លាស់ប្តូរបទពិសោធន៍, និង

(៥). ពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តការវាយតម្លៃតម្រូវការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង វិធីសាស្ត្រ និង បច្ចេកទេសបណ្តុះបណ្តាល និង វិក្រឹតការ, និង

(៦). អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ជូនមន្ត្រីរាជការដែលមានសក្តានុពលល្អលើសលប់ និង មានឆន្ទៈកែទម្រង់ខ្ពស់ ដោយសហការជាមួយគ្រឹះស្ថានសិក្សាអប់រំជាតិ-អន្តរជាតិ សម្រាប់ទិសដៅរយៈពេលវែង ។

## ២.៥. វិសាលភាព និង ក្របខណ្ឌពេលវេលា

ផែនការយុទ្ធសាស្ត្រនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ចូលរួមគាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ជាពិសេស ឆ្លើយតបតម្រូវការអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ ដូចជា យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ និង យុទ្ធសាស្ត្រគៀរគរចំណូល ជាដើម ។

ផែនការយុទ្ធសាស្ត្រនេះ គឺជាឯកសាររស់ អាចធ្វើបច្ចុប្បន្នកម្មបានតាមតម្រូវការ និង ជាត្រីវិស័យចង្អុលទិសការកសាង និង ការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង បម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ តាមស្មារតី «**យុទ្ធសាស្ត្រចតុកោណ**» ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។

## ២.៦. ក្របខណ្ឌយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព

តាមការសិក្សា វិភាគ និង វាយតម្លៃ ឈរលើបទពិសោធន៍ជាតិ-អន្តរជាតិ ការកសាង និង ការអភិវឌ្ឍសមត្ថភាពដែលជោគជ័យគឺត្រូវមានការចូលរួមគាំទ្រ និង កិច្ចសហការ ពីតួអង្គគន្លឹះសំខាន់ៗ រួមមាន តួអង្គដឹកនាំ និង ណែនាំ តួអង្គផ្តល់សេវាបណ្តុះបណ្តាល តួអង្គសិក្ខាកាមគោលដៅ និង ស្ថាប័នទទួលសេវាបណ្តុះបណ្តាល និង តួអង្គគាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការ ។ តួអង្គដឹកនាំ និង ណែនាំ ត្រូវផ្តល់ការសម្រេច ការគាំទ្រ និង ការណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រលើការរៀបចំ និង ការអនុវត្តផែនការ ។ តួអង្គផ្តល់សេវាបណ្តុះបណ្តាល ត្រូវមានការទទួលស្គាល់ និង មានជំនាញឯកទេស គុណវុឌ្ឍិ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង បណ្ណាល័យ ធនធានមនុស្ស កម្មវិធីសិក្សា វិធីសាស្ត្រ ធនធានហិរញ្ញវត្ថុ និង មានបទពិសោធន៍ គ្រប់គ្រាន់តាមបទដ្ឋានបច្ចេកទេស ។

សិក្ខាកាមគោលដៅ ត្រូវចូលរួមរៀនសូត្រ តាមលក្ខខណ្ឌ និង កម្មវិធីសិក្សា ។ ស្ថាប័នទទួលសេវាបណ្តុះបណ្តាលត្រូវសហការផ្តល់ព័ត៌មាន ទិន្នន័យអំពីតម្រូវការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល, ចាត់តាំងមន្ត្រីរាជការតាមលក្ខខណ្ឌ

និង ផ្តល់ពេលវេលាពេញលេញ ដើម្បីចូលរួមវគ្គសិក្សា និង ផ្តល់ឱកាសឱ្យសិក្ខាកាមប្រើចំណេះជំនាញពីការសិក្សានៅក្នុងអង្គភាពការងារ ។ ស្ថាប័នគាំទ្រការបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវផ្តល់កិច្ចសហការ និងចូលរួមគាំទ្រ ទាំងហិរញ្ញវត្ថុ បច្ចេកទេស និង ស្មារតី ។ ស្ថាប័នគាំទ្រអាចចូលរួមផ្តល់មតិយោបល់ លើកម្មវិធី វិធីសាស្ត្រ និង ចែករំលែកបទពិសោធន៍ ដោយផ្ទាល់ ឬ ប្រយោល ដល់ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាល ដើម្បីជួយឱ្យដំណើរការបណ្តុះបណ្តាល និង វិក្រឹតការ ប្រព្រឹត្តទៅបានរលូន គ្រប់ជ្រុងជ្រោយ និង មានប្រសិទ្ធភាព ។

ក្របខណ្ឌយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព សម្រាប់ដំណាក់កាល ៣ ប្លូក ២ និង ដំណាក់កាលទី ៤ ផ្តោតអាទិភាពលើការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ កោសល្យឯកទេស និង ការពង្រឹងពង្រីកវិធីសាស្ត្របណ្តុះបណ្តាល និងវិក្រឹតការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម តាមអភិក្រមយុទ្ធសាស្ត្រៈ(១). រៀបចំវិធានគាំទ្រការបណ្តុះឆន្ទៈ និង ការចូលរួមកសាង និង អភិវឌ្ឍសមត្ថភាព,(២). បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស, (៣). ពង្រឹងកិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គគាំទ្រការកសាង និង ការអភិវឌ្ឍសមត្ថភាព, (៤). ពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ, និង(៥). ពង្រឹងការវាយតម្លៃតម្រូវការ, ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង វិធីសាស្ត្របណ្តុះបណ្តាល និងវិក្រឹតការ ស្របតាមក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ។

ក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ចង្អុលបង្ហាញពី អត្ថន័យ លក្ខណវិនិច្ឆ័យ គំរូ និង កម្រិតនៃសមត្ថភាព ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ សមត្ថភាព សំដៅដល់ចំណេះដឹង ជំនាញ អាកប្បកិរិយា និង ឥរិយាបថបំពេញការងារ របស់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដោយរំពឹងទុកនូវសមិទ្ធកម្ម ប្រកបដោយផលិតភាព និង ប្រសិទ្ធភាពខ្ពស់ ។ លក្ខណវិនិច្ឆ័យសមត្ថភាព រួមមាន ÷

១. **ចំណេះដឹង (Knowledge-K):** សំដៅពុទ្ធិ ព័ត៌មាន និង បច្ចេកទេសគាំទ្រការអនុវត្តការងារ ដែលទទួលបានពីអន្តរកម្មនៃអព្ភន្តរញ្ញាណ ការត្រិះរិះ បទពិសោធន៍ និង ការសិក្សាស្រាវជ្រាវ ឬ ការសិក្សាអប់រំ,

២. **ជំនាញ (Skill-S):** សំដៅភាពស្ទាត់ ភាពវាងវៃ ភាពប៉ិនប្រសប់ ភាពចំណាន ពោលគឺ កោលស្យឯកទេសក្នុងវិជ្ជាជីវៈ ដែលទទួលបានពីការសិក្សា ការហ្វឹកហាត់ និង ការអនុវត្តដដែលដោយផ្ចិតផ្ចង់ និង ពេញចិត្ត,

៣. **អាកប្បកិរិយា (Behaviour-B):** សំដៅរបៀបនៃទង្វើ ការសម្របសម្រួល ភាពច្នៃប្រឌិត ឬ សកម្មភាពស្ទាត់ជំនាញជាក់លាក់មួយ ធ្វើឡើងក្នុងបំណងឆ្លើយតបទៅនឹងស្ថានការណ៍ ឬ ស្ថានភាព សំដៅសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុក,

៤. **ឥរិយាបថ (Attitude-A):** សំដៅផ្លូវឬគន្លងចរិយា ដំណើរការប្រព្រឹត្ត សភាពនៃឆន្ទៈឬរបៀបការគិត ការផ្តោតអារម្មណ៍ និង ការសម្តែងចេញនូវគំនិត ប្រកបដោយមនសិការ មានវិចារណញ្ញាណ ឬ បែបសភាវគតិ ចំពោះមនុស្ស ទីកន្លែង វត្ថុ ឬ ព្រឹត្តិការណ៍អ្វីមួយ ។

លក្ខណវិនិច្ឆ័យសមត្ថភាព (KSBA) ត្រូវបានទទួលស្គាល់ជាសកលថា គឺជាស្វ័យធាតុដែលមានឥទ្ធិពលលើលទ្ធផលនៃការអនុវត្តតួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ វាស់វែងធៀបទៅនឹងស្តង់ដារកំណត់ ហើយត្រូវបានអភិវឌ្ឍ និង កែលម្អជាបន្តបន្ទាប់ តាមរយៈការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ចំណេះដឹង និង ជំនាញវិជ្ជាជីវៈ ពេញមួយជីវិត ស្របតាមគំរូសមត្ថភាពជំនាញជាក់លាក់ណាមួយ ។

គំរូសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ គឺជាគុណវុឌ្ឍិសំខាន់ដែលត្រូវបំពាក់ជូនមន្ត្រីរាជការ សម្រាប់ចូលរួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។ គំរូសមត្ថភាពនេះបញ្ជាក់អំពីប្រភេទ កម្រិត កោសល្យឯកទេស និង មុខជំនាញគន្លឹះៗ សម្រាប់ការកសាង និង ការអភិវឌ្ឍសមត្ថភាព មានជាអាទិ៍ៈ ថវិកាកម្មវិធី និង អង្គភាពថវិកា, លទ្ធកម្មសាធារណៈ, គណនេយ្យសាធារណៈ, គ្រប់គ្រងសាច់ប្រាក់, គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, គ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន និង សវនកម្មផ្ទៃក្នុង ដូចមាននៅក្នុង **រូបបំព្រួញ** ខាងក្រោម ។

## ២.៦.១ កម្រិតសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ

កម្រិតសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ មាន ៥ កម្រិតគឺ សមត្ថភាពយល់ដឹងទូទៅ, សមត្ថភាពឯកទេសមូលដ្ឋាន, សមត្ថភាពឯកទេសជំនាញ, សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់ និង សមត្ថភាពឯកទេសកម្រិតជំនាញការ ។ ផ្អែកតាមការសិក្សា វិភាគ និង វាយតម្លៃបទពិសោធន៍ជាតិ-អន្តរជាតិ គំរូសមត្ថភាពទាំង ៥ កម្រិតនេះ ជាតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពជូនមន្ត្រីរាជការគោលដៅ ដើម្បីចូលរួមគាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង រួមចំណែកគាំទ្រដល់ការកែទម្រង់គន្លឹះដទៃទៀតរបស់រាជរដ្ឋាភិបាល សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ឆ្លើយតបនឹងតម្រូវការ និង សំណូមពររបស់ប្រជាពលរដ្ឋ ។




ការកសាង និង ការអភិវឌ្ឍសមត្ថភាព គឺជាកត្តាគន្លឹះសម្រាប់ជំរុញជវភាព និង សក្តានុពលភាពមន្ត្រីរាជការ សំដៅលើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពការងារ ព្រមទាំងត្រៀមខ្លួនចាប់យកឱកាសការងារ ស្របតាមបរិបទប្រែប្រួលក្នុងពេលអនាគត ។ អាស្រ័យហេតុនេះ ការកសាង និង ការអភិវឌ្ឍសមត្ថភាព ចាំបាច់ត្រូវរៀបចំ និង អនុវត្តឆ្លើយតបតម្រូវការអង្គភាពការងារ ស្របតាមគំរូសមត្ថភាពជំនាញជាក់លាក់ និង ផ្អែកតាមកម្រិតមុខងារ ភារកិច្ច និង ការទទួលខុសត្រូវរបស់មន្ត្រីរាជការ ។ ផ្អែកតាមគំរូសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ កម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ត្រូវរៀបចំតាមកម្រិត ដូចខាងក្រោម ÷

### ក. កម្មវិធីបណ្តុះបណ្តាលកម្រិតទី ១

ជាកម្មវិធីបណ្តុះបណ្តាលតម្រង់ទិស កម្រិតដំបូង នៃក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ មានរយៈពេលខ្លី (ក្រោម ៤៥ ម៉ោង) និង ជាប្រភេទ **វគ្គវិក្រឹតការ ឬ សុក្រឹតការ** ក្នុងគោលដៅលើកកម្ពស់ការយល់ដឹង និង ចំណេះដឹង សំដៅបំពាក់ "**សមត្ថភាពយល់ដឹងទូទៅ**" ពាក់ព័ន្ធនឹងបទប្បញ្ញត្តិ វិធានជាលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រ និង គោលការណ៍ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីនេះ ប្រព្រឹត្តទៅក្នុងទម្រង់ជា ថ្នាក់សហសិក្សា កម្មសិក្ខាសាលាបណ្តុះបណ្តាល សិក្ខាសាលាផ្សព្វផ្សាយ រួមនឹងទស្សនកិច្ចសិក្សា សម្រាប់សិក្ខាកាមជាមន្ត្រីរាជការ ឬ បុគ្គលិកកិច្ចសន្យាលើមុខងារពាក់ព័ន្ធ ។ ក្រោយបញ្ចប់វគ្គសិក្សា

សិក្ខាកាមនឹងទទួល **លិខិតបញ្ជាក់ការសិក្សា** ពីវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ខ. កម្មវិធីបណ្តុះបណ្តាលកម្រិតទី ២

ជាកម្មវិធីបណ្តុះបណ្តាលឯកទេសមូលដ្ឋាន មានរយៈពេលមធ្យម (៤៥-៩០ ម៉ោង) និង ជាប្រភេទ **វគ្គសិក្សាជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ** ដើម្បីលើកកម្ពស់ការយល់ដឹង និង ចំណេះដឹង សំដៅបំពាក់ "**សមត្ថភាពឯកទេសមូលដ្ឋាន**" ពាក់ព័ន្ធនឹង ការងាររដ្ឋទេយ្យ, ការងារបើកផ្តល់, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ កិច្ចបញ្ជិកាគណនេយ្យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង ឯកសារអនុវត្តកិច្ចលទ្ធកម្ម, និង ការងារពាក់ព័ន្ធ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីនេះ ប្រព្រឹត្តទៅក្នុងទម្រង់ជាវគ្គបច្ចេកទេសក្នុងថ្នាក់បែបប្រពលកម្ម សម្រាប់សិក្ខាកាមជា រដ្ឋទេយ្យករបុរេប្រទានរង, រដ្ឋទេយ្យករចំណូលរង, ភ្នាក់ងារបើកផ្តល់, ភ្នាក់ងារបើកផ្តល់ជំនួស, ជំនួយការគណនេយ្យ, ជំនួយការហិរញ្ញវត្ថុ, ជំនួយការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, ជំនួយការរៀបចំឯកសារកិច្ចលទ្ធកម្មសាធារណៈ, ជំនួយការសវនករផ្ទៃក្នុង, ជំនួយការគម្រោងវិនិយោគសាធារណៈ និង គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ។ ក្រោយបញ្ចប់វគ្គសិក្សាដោយជោគជ័យ សិក្ខាកាមនឹងទទួល **វិញ្ញាបនបត្រឯកទេសមូលដ្ឋាន** ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### គ. កម្មវិធីបណ្តុះបណ្តាលកម្រិតទី ៣

ជាកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញ មានរយៈពេលមធ្យម (៩០-១០៥ ម៉ោង) និង ជាប្រភេទ **វគ្គសិក្សាជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ** ដើម្បីពង្រឹងពង្រីកសមត្ថភាព និង ចំណេះដឹង សំដៅបំពាក់ "**សមត្ថភាពឯកទេសជំនាញ**" ពាក់ព័ន្ធការងាររដ្ឋទេយ្យ, ការរៀបចំរបាយការណ៍សមិទ្ធកម្ម, កិច្ចបញ្ជិកាគណនេយ្យ, ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង ឯកសារអនុវត្តកិច្ចលទ្ធកម្ម, ការងារសវនកម្មផ្ទៃក្នុង និង អធិការកិច្ចហិរញ្ញវត្ថុ និង ការងារពាក់ព័ន្ធ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីនេះ នឹងប្រព្រឹត្តទៅនៅក្នុងទម្រង់ជាវគ្គបច្ចេកទេសក្នុងថ្នាក់បែបប្រពលកម្ម សម្រាប់សិក្ខាកាមជា រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករចំណូល, គណនេយ្យករ, មន្ត្រីទទួលបន្ទុកកិច្ចលទ្ធកម្ម, មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ, មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, សវនករផ្ទៃក្នុង និង អធិការកិច្ចហិរញ្ញវត្ថុ, មន្ត្រីគម្រោងវិនិយោគសាធារណៈ និង គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និង អតីតសិក្ខាកាមបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ២ ។ ក្រោយបញ្ចប់វគ្គសិក្សានេះ ដោយជោគជ័យ សិក្ខាកាមនឹងទទួល **វិញ្ញាបនបត្រឯកទេសជំនាញ** ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ឃ. កម្មវិធីបណ្តុះបណ្តាលកម្រិតទី ៤

ជាកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញកម្រិតខ្ពស់ មានរយៈពេលមធ្យម (១០៥-១២០ ម៉ោង) និង ជាប្រភេទ **វគ្គសិក្សាជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រជាន់ខ្ពស់** ដើម្បីអភិវឌ្ឍសមត្ថភាពឯកទេស និង កោសល្យវិជ្ជាជីវៈ សំដៅបំពាក់ "**សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់**" ពាក់ព័ន្ធនឹង ការរៀបចំ និង ការអនុវត្តថវិកា, ការរៀបចំ និង ការអនុវត្តកិច្ចលទ្ធកម្ម, ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ, ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, ការរៀបចំ និង ការអនុវត្តគម្រោងវិនិយោគសាធារណៈ និង គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, ការងារសវនកម្មផ្ទៃក្នុង និង អធិការកិច្ចហិរញ្ញវត្ថុ និង ការងារពាក់ព័ន្ធ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីនេះ ប្រព្រឹត្តទៅក្នុងទម្រង់ជាវគ្គបច្ចេកទេសក្នុងថ្នាក់បែបប្រពលកម្ម សម្រាប់សិក្ខាកាម

ជាមន្ត្រីដឹកនាំកម្រិតបច្ចេកទេស និង អតីតសិក្ខាកាមបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ៣ ។ ក្រោយបញ្ចប់វគ្គសិក្សានេះ ដោយជោគជ័យ សិក្ខាកាមនឹងទទួល **វិញ្ញាបនបត្រឯកទេសជំនាញកម្រិតខ្ពស់** ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ង. កម្មវិធីបណ្តុះបណ្តាលកម្រិតទី ៥

ជាកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញការ មានរយៈពេលមធ្យម (១២០-១៣៥ ម៉ោង) និង ជាប្រភេទ **វគ្គសិក្សាជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រជាន់ខ្ពស់** ដើម្បីលើកទឹកចិត្ត និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការឱ្យក្លាយជាអ្នកជំនាញ ប្រកបដោយកោសល្យឯកទេស លើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងថវិកា, លទ្ធកម្ម, គណនេយ្យ, ទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, គម្រោងវិនិយោគសាធារណៈ និង គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, សវនកម្មផ្ទៃក្នុង និង អធិការកិច្ចហិរញ្ញវត្ថុ និង កិច្ចការពាក់ព័ន្ធ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីនេះ ប្រព្រឹត្តទៅក្នុងទម្រង់ជាវគ្គសិក្សាបច្ចេកទេសក្នុងថ្នាក់ រួមនឹងការស្រាវជ្រាវ ផ្សារភ្ជាប់ការអនុវត្ត សម្រាប់សិក្ខាកាមជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ មានឧបនិស្ស័យដឹកនាំលើកិច្ចការចាប់ពីថ្នាក់ការិយាល័យ ឬ ថ្នាក់ប្រហាក់ប្រហែល, មន្ត្រីទទួលបន្ទុកកិច្ចការវិភាគសេដ្ឋកិច្ច ហិរញ្ញវត្ថុ ថវិកា, គ្រូបង្គោល, និង អតីតសិក្ខាកាម ដែលបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ៤ ។ ក្រោយបញ្ចប់វគ្គសិក្សានេះដោយជោគជ័យ, សិក្ខាកាមនឹងទទួល **វិញ្ញាបនបត្រឯកទេសជំនាញការ** ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជារួម កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវរៀបចំស្របតាមកម្រិតសមត្ថភាព ផ្អែកតាមកម្រិតគុណវុឌ្ឍិនៃក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ដូចមានក្នុង **ឧបសម្ព័ន្ធ ៣** ។ សិក្ខាកាមគោលដៅ ត្រូវចូលរួមសិក្សា លើមុខជំនាញតាមតម្រូវការការងារ និង ទៅតាមកម្រិត និង ប្រភេទសមត្ថភាពជំនាញ ដោយត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលតាមលំដាប់ពីកម្រិតទី ១ ដល់ កម្រិតទី ៥ និង ត្រូវប្រឡងជាប់ដោយជោគជ័យ ដើម្បីបញ្ចប់វគ្គសិក្សាក្នុងកម្រិតនីមួយៗ មុននឹងអាចទទួលវិញ្ញាបនបត្រ ឬ អនុញ្ញាតឱ្យបន្តការសិក្សានៅកម្រិតបន្ទាប់ទៀត ។

## ២.៦.២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេសរយៈពេលមធ្យមកម្រិតវិញ្ញាបនបត្រ

ទន្ទឹមនឹងការអនុវត្តការបណ្តុះបណ្តាលជាតម្រូវការបន្ទាន់ របស់ក្រសួងស្ថាប័ន, ចំពោះមុខ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្តោតសំខាន់លើការរៀបចំវិធានកំណត់គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់លើកកម្ពស់ឆន្ទៈចូលរួម និង ស្មារតីទទួលខុសត្រូវ របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និង រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារកសាង និង អភិវឌ្ឍសមត្ថភាព សំដៅគាំទ្រកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង សម្រាប់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដោយរក្សាឱ្យបាននូវការបណ្តុះបណ្តាលប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ដើម្បីធានាគុណភាព និង ប្រសិទ្ធភាព ឆ្លើយតបនឹងតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ។

ដើម្បីសម្រេចជោគជ័យក្នុងការរៀបចំ និង ការអនុវត្តការបណ្តុះបណ្តាលជំនាញបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់វិធានការបន្ទាន់ចំពោះមុខ និង វិធានការរយៈពេលមធ្យម និង រយៈពេលវែង ដូចខាងក្រោម÷

### (១). វិធានការបន្ទាន់ចំពោះមុខ

**វិធានជាលិខិតបទដ្ឋានគតិយុត្ត៖** អាទិភាពមុនគេ លើការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ «**វិធាន**» ជាលិខិតបទដ្ឋានគតិយុត្ត ដូចបានកំណត់ក្នុងសកម្មភាព នៃយុទ្ធសាស្ត្រទី ១ (**ឧបសម្ព័ន្ធ ១**) នៃផែនការយុទ្ធសាស្ត្រនេះ ដែលត្រូវសម្រេចឱ្យបាននៅឆមាសទី ១ ឆ្នាំ ២០២២ ។ ការរៀបចំឯកសារ

នេះ ទាមទារការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ជាមួយក្រសួងស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាការចូលរួមគាំទ្រ និង ការអនុវត្តប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។ ជាមូលដ្ឋានក្នុងការរៀបចំវិធាននេះ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីកំណត់លក្ខណវិនិច្ឆ័យនៃសិក្ខាកាមគោលដៅ ដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ស្របតាមក្របខណ្ឌសមត្ថភាពជំនាញ និង ស្នើឡើងនូវទម្រង់ជាក់លាក់នៃវិធានខាងលើនេះ ដើម្បីគោរពស្នើសុំការពិនិត្យសម្រេច និង ការណែនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវសិក្សាស្រាវជ្រាវ និង រៀបចំឯកសារទស្សនាទានបច្ចេកទេស ដើម្បីកំណត់សិក្ខាកាមគោលដៅ និង លក្ខណវិនិច្ឆ័យនៃគុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដែលគ្របដណ្តប់ប្រភេទមុខជំនាញ កម្រិតគុណវុឌ្ឍិ និង កម្រិតសមត្ថភាព ចំណេះដឹង និង កោសល្យឯកទេស សម្រាប់កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ឆ្លើយតបតម្រូវការនៃអង្គភាពថវិកា របស់ក្រសួងស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ឯកសារទស្សនាទាននេះនឹងផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម÷

– **សិក្ខាកាមគោលដៅ:** ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្អែកតាមការសិក្សាការវិភាគ និង ការវាយតម្លៃ អនុលោមតាមបទប្បញ្ញត្តិ និង លិខិតបទដ្ឋានជាធរមាន មុខជំនាញដែលជាតម្រូវការសម្រាប់ការកសាង និង ការអភិវឌ្ឍសមត្ថភាព ជូនមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ មាន ៩ ប្រភេទ ដូចនៅក្នុងគំនូសបំព្រួញគំរូសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ នៅទំព័រ ២០-២១ ខាងលើ ។ សិក្ខាកាមគោលដៅជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបែងចែកទៅតាម ប្រភេទមុខជំនាញ កម្រិតគុណវុឌ្ឍិ និង កម្រិតសមត្ថភាពតាមមុខងារ ភារកិច្ច និង លក្ខខណ្ឌបច្ចេកទេស នៃកម្មវិធីបណ្តុះបណ្តាលតាមវគ្គសិក្សានីមួយៗ ។

– **គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ:** ដើម្បីទទួលគុណវុឌ្ឍិនេះ មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ចាំបាច់ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ រៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ផ្អែកតាមតម្រូវការក្នុងដំណាក់កាល និងបរិការណ៍ថ្មី នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មន្ត្រីរាជការដែលទទួលគុណវុឌ្ឍិមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈហើយ ចាំបាច់ត្រូវចូលរួមវគ្គរិក្រឹតការជាទៀងទាត់ លើជំនាញឯកទេសរបស់ខ្លួន តាមកម្មវិធីកំណត់របស់វិទ្យាស្ថាន ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង និង ជំនាញវិជ្ជាជីវៈរបស់ខ្លួន ។

– **គុណវុឌ្ឍិគ្រូបង្គោល:** ត្រូវបានទទួលស្គាល់គុណវុឌ្ឍិ ជាគ្រូបង្គោលដោយស្វ័យប្រវត្តិ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋានជំនាញ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបាន និង កំពុងបំពេញការងារពាក់ព័ន្ធ ឬ ចូលនិវត្តន៍ នៅមានសក្តានុពល, មានពិសោធន៍ក្នុងការបង្រៀន និង ទទួលការតែងតាំងប្រគល់ភារកិច្ចជាគ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បុគ្គលមិនស្ថិតក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏នឹងអាចជ្រើសរើសជាគ្រូបង្គោលផងដែរ ក្នុងករណី បុគ្គលនោះមានចំណេះដឹង, កម្រិតជំនាញតាមតម្រូវការ និង បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោល ដោយជោគជ័យ តាមកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូ

បង្គោល របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

– **ការលើកទឹកចិត្ត:** ក្នុងគោលដៅបណ្តុះឆន្ទៈចូលរួមអភិវឌ្ឍសមត្ថភាពឱ្យកាន់តែសកម្ម, គ្រូបង្គោលដែលមានសមត្ថភាព និង មានកោសល្យឯកទេស ក្នុងការបង្រៀន ហើយមានស្នាដៃល្អក្នុងការបំពេញតួនាទី ភារកិច្ច នឹងទទួលការលើកទឹកចិត្តជាលិខិតសរសើរ និង អត្ថប្រយោជន៍ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន ។ ចំណែកសិក្ខាកាមនឹងទទួលវិញ្ញាបនបត្របញ្ចប់ការសិក្សា, ទទួលសិទ្ធិក្នុងការតែងតាំង ឬ ប្រគល់ភារកិច្ច លើមុខងារជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ តាមជំនាញដែលបានទទួលការសិក្សា និង អាចស្នើសុំដំឡើងថ្នាក់ ឬ ឋានន្តរស័ក្តិ ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

– **ការដាក់ពិន័យឬវិន័យ:** វិធានការរដ្ឋបាល នឹងត្រូវអនុវត្តលើមន្ត្រីរាជការជាសិក្ខាកាមដែលត្រូវបានចាត់បញ្ជូនចូលរួមវគ្គបណ្តុះបណ្តាល តែមានចេតនាគេចវេសការសិក្សា, ចូលរួមមិនទៀងទាត់ ឬ មិនចូលរួមវគ្គបណ្តុះបណ្តាលផ្សារភ្ជាប់វិញ្ញាបនបត្រ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ វិធានការទាំងនោះ រួមមានៈ មិនអនុញ្ញាតឱ្យប្រឡងបញ្ចប់ការសិក្សា, មិនផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សា, មិនផ្តល់ការទទួលស្គាល់លើការតែងតាំង ឬ បញ្ចប់ការទទួលស្គាល់ការតែងតាំងឬប្រគល់មុខងារជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ, ឬ មិនអនុញ្ញាតឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលលើកក្រោយៗរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

– **ការផ្សព្វផ្សាយ:** ដោយកិច្ចការនេះ គឺជារបត់ថ្មី ការផ្សព្វផ្សាយនឹងត្រូវធ្វើទូលំទូលាយ ដើម្បីបញ្ជ្រាបនូវការយល់ដឹង និង លើកកម្ពស់ស្មារតីគាំទ្រ និង កិច្ចសហការពីក្រសួងស្ថាប័ន មន្ទីរអង្គភាពជំនាញ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូពាក់ព័ន្ធ សំដៅជំរុញសុឆន្ទៈ ការចូលរួម សង្គតិភាព និង ប្រសិទ្ធភាពក្នុងការអនុវត្ត ។

### (២). វិធានការរយៈពេលមធ្យម និង រយៈពេលវែង

– **ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តរៀបចំអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រនេះ ទៅជាកម្មវិធីមួយដ៏ពេញលេញ សម្រាប់រយៈពេលមធ្យម និង រយៈពេលវែង ដោយសិក្សាស្រាវជ្រាវ ដកពិសោធបន្ថែមពីឧត្តមានុវត្តន៍ជាតិ-អន្តរជាតិ និង ប្រមូលព័ត៌មាន ទិន្នន័យពាក់ព័ន្ធចាំបាច់ តាមរយៈការពិគ្រោះយោបល់ ទស្សនកិច្ចសិក្សា និង កិច្ចសហការជាមួយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និង ដៃគូពាក់ព័ន្ធ ។

– **ការអនុវត្តកម្មវិធីបណ្តុះបណ្តាល:** ផ្អែកតាមលទ្ធផលនៃការធ្វើអាទិភាវូបនីយកម្មតម្រូវការ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំផែនការលម្អិត សម្រាប់ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការប្រចាំឆ្នាំ លើជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ដើម្បីគោរពសុំការពិនិត្យសម្រេច និង ការគាំទ្រដ៏ខ្ពង់ខ្ពស់ ពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សហការ ជាមួយអង្គភាពជំនាញ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន, មន្ទីរអង្គភាពក្រោមឱវាទ និង រដ្ឋបាលថ្នាក់ក្រោមជាតិ រួមនឹងដៃគូពាក់ព័ន្ធ សម្រាប់ដំណើរការអនុវត្ត ។

– **ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តការបណ្តុះបណ្តាល:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសម្របសម្រួលជាមួយអង្គភាពជំនាញ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន និង តួអង្គពាក់ព័ន្ធ ក្នុងការអនុវត្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃតម្រូវការ និង ប្រសិទ្ធភាព នៃការបណ្តុះបណ្តាល ស្របតាមកម្មវិធី វិធីសាស្ត្រ និង គោលការណ៍បច្ចេកទេស សំដៅធានាគុណភាព និង ប្រសិទ្ធភាព នៃការបណ្តុះបណ្តាល ។

### ២.៦.៣ ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតសញ្ញាបត្រ

ទិសដៅរយៈពេលវែង ក្នុងការកសាង និង ការអភិវឌ្ឍសមត្ថភាព លើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបង្កើនការសិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលកម្រិតសញ្ញាបត្របន្ថែមទៀត ដោយសហការជាមួយគ្រឹះស្ថានសិក្សាអប់រំជាតិ-អន្តរជាតិ ដើម្បីជំរុញលើកទឹកចិត្ត និង ផ្ដល់កាលានុវត្តដល់មន្ត្រីរាជការវ័យក្មេង មានសក្ដានុពលល្អលាស់ និង មានឆន្ទៈកែទម្រង់ខ្ពស់ សំដៅថែរក្សាសមិទ្ធផលកែទម្រង់ និង ធានាចីរភាពអ្នកបន្តវេនដឹកនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយសមត្ថភាព និង មនសិការ សំដៅរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាព ជូនប្រជាពលរដ្ឋកម្ពុជា ៕

# ជំពូក ៣

# ផែនការសកម្មភាពនៃយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព

## ៣.១. ផែនការសកម្មភាព

ដើម្បីបង្កើន និង លើកស្ទួយប្រសិទ្ធភាព ការបំពេញតួនាទី ភារកិច្ច របស់មន្ត្រីរាជការ ប្រកបដោយ សុចន្ទៈ ស្មារតីទទួលខុសត្រូវ និង ភាពម្ចាស់ការ សម្រាប់បម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ស្របតាមបរិការណ៍កែទម្រង់របស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានកំណត់ទិសដៅយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព រយៈពេល ៥ ឆ្នាំ ក្នុងដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ គឺការអភិវឌ្ឍសមត្ថភាព, ជំនាញវិជ្ជាជីវៈ,កោសល្យឯកទេសប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការ, និង ការពង្រឹងពង្រីកវិសាលភាព និង វិធីសាស្ត្របណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញពាក់ព័ន្ធនឹងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និង អនុវត្តបេសកកម្មក្នុងការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំដៅសម្រេចគោលដៅពង្រឹងការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ និង គណនេយ្យភាពសមិទ្ធកម្ម នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាពជូនប្រជាជន ។

ក្នុងន័យនេះ ដើម្បីធានាប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការអនុវត្ត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានកំណត់យុទ្ធសាស្ត្រអាទិភាព និង ផែនការសកម្មភាពគាំទ្រជាគន្លឹះសំខាន់ៗ ដូចខាងក្រោម ÷

### ក. យុទ្ធសាស្ត្រទី ១ : ការបណ្តុះឆន្ទៈលើការកសាង និង ការអភិវឌ្ឍសមត្ថភាព

យុទ្ធសាស្ត្រទី១គ្របដណ្តប់លើការបណ្តុះសុចន្ទៈ លើកកម្ពស់សមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ឆ្លើយតបនឹងតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។ យុទ្ធសាស្ត្រទី ១ នេះផ្តោតលើទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ÷

#### *១.១. រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រ និង បណ្តុះសុចន្ទៈលើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- វិធានកំណត់គុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់សិក្ខាកាមនៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ត្រូវបានរៀបចំ,
- លិខិតបទដ្ឋានគតិយុត្តតែងតាំង និង លើកទឹកចិត្តគ្រូបង្គោលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំ,
- ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពជំនាញ ទាំងនៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ, និង
- ឯកសារទស្សនាទានស្តីពីការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្រិតសញ្ញាបត្រ ត្រូវបានរៀបចំ ។

#### *១.២. បណ្តុះសុចន្ទៈ និង ភាពជាម្ចាស់លើការកែទម្រង់ក្នុងស្មារតីទទួលខុសត្រូវ ផ្សារភ្ជាប់ការកសាង និង អភិវឌ្ឍសមត្ថភាព*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- កម្មវិធីសិក្ខាសាលាពង្រឹងសមត្ថភាព លើកកម្ពស់ការយល់ដឹង បណ្តុះសុចន្ទៈ ភាពជាម្ចាស់ និង ស្មារតី

ទទួលខុសត្រូវលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និង អនុវត្ត,
- មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈទទួលលទ្ធផលល្អក្នុងការពង្រឹងសមត្ថភាព ត្រូវបានលើកទឹកចិត្ត,
- ផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ត្រូវបានរៀបចំ និង អនុវត្តយ៉ាងតិច ៨០ ភាគរយ,
- មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ត្រូវបានបញ្ចប់ការសិក្សាដោយជោគជ័យយ៉ាងតិច ៨០ ភាគរយ ។

### ១.៣. អនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការដែលមានលក្ខណៈឆ្លើយតប

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷
- វគ្គវិក្រឹតការចំនួន ៣០ ត្រូវបានរៀបចំជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដែលទទួលវិញ្ញាបនបត្រជំនាញបច្ចេកទេស រយៈពេលមធ្យម លើជំនាញសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣,
- វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ លើជំនាញសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣០ វគ្គ ត្រូវបានរៀបចំជូនក្រសួងស្ថាប័ន,
- វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ លើជំនាញសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១៥ វគ្គ ត្រូវបានរៀបចំជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល,
- វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ លើជំនាញសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០ វគ្គ ត្រូវបានរៀបចំជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ១.៤. វាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្មនៃការបណ្តុះបណ្តាល និង វិក្រឹតការ

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷
- ឯកសារណែនាំសម្រាប់ប្រតិបត្តិការវាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្មនៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ត្រូវបានរៀបចំ,
- របាយការណ៍វាយតម្លៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ត្រូវបានរៀបចំ និង ពិនិត្យវិភាគ សម្រាប់ការកែលម្អនៅពេលខាងមុខ ។

## ២. យុទ្ធសាស្ត្រទី ២ : ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស

យុទ្ធសាស្ត្រទី ២ គ្របដណ្តប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់អនុវត្តមុខងារកសាង និង អភិវឌ្ឍសមត្ថភាព ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដោយធ្វើទំនើបកម្មកម្មវិធីសិក្សា ឯកសារ វិធីសាស្ត្រ និង បច្ចេកទេសបណ្តុះបណ្តាល និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង និង បណ្ណាល័យ សម្រាប់បណ្តុះបណ្តាល និង វិក្រឹតការ និង ជំរុញអនុវត្តប្រព័ន្ធគុណាធិបតេយ្យ ក្នុងការលើកទឹកចិត្តមន្ត្រីរាជការមានស្នាដៃល្អក្នុងការងារ ។

យុទ្ធសាស្ត្រនេះ ជំរុញ និង លើកកម្ពស់ការបង្កើតវប្បធម៌ថែរក្សាមន្ត្រីមានសមត្ថភាព សុជន្ទៈវិជ្ជាជីវៈ និង លើកទឹកចិត្តដោយយុត្តិធម៌ តាមប្រព័ន្ធលាភការមន្ត្រីរាជការសាធារណៈ និង ជ្រើសរើសមន្ត្រីថ្មីដែលមានសមត្ថភាព និង សុជន្ទៈវិជ្ជាជីវៈ ដោយតម្លាភាព ស្របតាមទំហំការងារ ។ យុទ្ធសាស្ត្រទី ២ ផ្តោតលើទិសដៅ និង សកម្មភាពយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ÷

## ២.១. លើកកម្ពស់សមត្ថភាព និង ជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះសំខាន់ៗដូចខាងក្រោម ÷

- កម្មវិធីពង្រឹងពង្រីកសមត្ថភាពជូនថ្នាក់ដឹកនាំវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំ និង អនុវត្ត,
- កម្មវិធីពង្រឹងពង្រីកសមត្ថភាពជូនមន្ត្រីជំនាញនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំ និង អនុវត្ត,
- កម្មវិធីពង្រឹងពង្រីកសមត្ថភាពជូនគ្រូបង្គោលនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំ និង អនុវត្ត,
- កម្មវិធីស្រាវជ្រាវ អភិវឌ្ឍ និង នវានុវត្ត សម្រាប់លើកកម្ពស់សមត្ថភាពស្ថាប័ន ដើម្បីអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវបានរៀបចំ អនុវត្ត និង លើកទឹកចិត្តចំពោះការសម្រេចបានសមិទ្ធកម្មល្អ ។

## ២.២. រៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល និង មូលដ្ឋានផ្ទុកឯកសារគាំទ្រការស្រាវជ្រាវ និង បណ្តុះបណ្តាល

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម ÷

- ការសិក្សាលទ្ធភាព និង ការដកស្រង់បទពិសោធជាតិ-អន្តរជាតិ លើការរៀបចំ និង ការបំពាក់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និង ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង ត្រូវបានរៀបចំ និង អនុវត្ត,
- ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភារបរិក្ខារទំនើបសម្រាប់គាំទ្រដំណើរការសិក្សាស្រាវជ្រាវ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវបានកែលម្អ,
- ឯកសារណែនាំសម្រាប់ប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល ត្រូវបានរៀបចំ,
- រចនាសម្ព័ន្ធ និង សមាសភាពគាំទ្រដំណើរការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល ត្រូវបានរៀបចំ និង អនុម័តដោយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- បណ្ណាល័យវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានកែលម្អ និង ធ្វើទំនើបកម្មជាបណ្ណាល័យអេឡិចត្រូនិច (E-Library),
- ប្រព័ន្ធទិន្នន័យគាំទ្រការអនុវត្តកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និង វិក្រឹតការ ត្រូវបានរៀបចំកែលម្អ អភិវឌ្ឍ និង គ្រប់គ្រង,
- ទិន្នន័យសិក្ខាកាមបណ្តុះបណ្តាល និង វិក្រឹតការនៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំ និង កត់ត្រាជាប្រចាំ, និង
- គេហទំព័រ និង ប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម ត្រូវបានរៀបចំកែលម្អ គ្រប់គ្រង និង អភិវឌ្ឍ ។

## ២.៣. ពង្រឹងអភិបាលកិច្ចស្ថាប័នរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម ÷

- លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំស្តីពីនីតិវិធី បច្ចេកទេស និង បទបញ្ជាផ្ទៃក្នុង សម្រាប់គាំទ្រដំណើរការអនុវត្តការកសាង និង ការអភិវឌ្ឍសមត្ថភាព របស់វិទ្យាស្ថាន ត្រូវបានរៀបចំ និង កែលម្អបន្ថែម,
- ផែនការសកម្មភាព និង ផែនការហិរញ្ញវត្ថុរួម សម្រាប់អនុវត្តយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពរបស់វិទ្យាស្ថាន ត្រូវបានរៀបចំ និង អនុវត្ត, និង
- របាយការណ៍លទ្ធផលអនុវត្តផែនការសកម្មភាព និង ផែនការហិរញ្ញវត្ថុរួម ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំ និង ដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## គ. យុទ្ធសាស្ត្រទី ៣ : ការពង្រឹងកិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គគាំទ្រការកសាង និង ការអភិវឌ្ឍសមត្ថភាព

យុទ្ធសាស្ត្រទី ៣ គ្របដណ្តប់ការពង្រឹងកិច្ចសហប្រតិបត្តិការពេញលេញប្រព័ន្ធតួអង្គអនុវត្តការកសាង និង ការអភិវឌ្ឍសមត្ថភាពលើជំនាញសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅជំរុញការចូលរួម និង ការគាំទ្រ ទាំងស្មារតីហិរញ្ញវត្ថុ និង បច្ចេកទេស ដើម្បីឱ្យការបណ្តុះបណ្តាល និង វិក្រឹតការ ប្រព្រឹត្តទៅបានរលូន ទាន់ពេល និង មានប្រសិទ្ធភាព ។ យុទ្ធសាស្ត្រទី ៣ ផ្តោតលើទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ÷

### ៣.១. បង្កើនកិច្ចសហការជាមួយ អគហ លេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ និង គ្រប់តួអង្គដៃគូ

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- តម្រូវការអាទិភាពក្នុងការកសាង និង ការអភិវឌ្ឍសមត្ថភាពលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុម័តគាំទ្រ ផ្អែកតាមផែនការសកម្មភាពលម្អិតនៃអង្គភាពក្រោមឱវាទ កសហវ (GDAP3+2, GDAP4) និង ផែនការសកម្មភាពរួម (CAP3+2, CAP4),
- ការអនុវត្ត GDAP3+2, GDAP4 និង CAP3+2, CAP4 មានការឆ្លើយតបទាន់ពេល ប្រកបដោយគុណភាព ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព,
- គម្រោងអាទិភាពលើការអភិវឌ្ឍសមត្ថភាពស្ថាប័ន របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍ និង ដៃគូសហប្រតិបត្តិការ,
- តម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ នៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានវាយតម្លៃ និង ពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ (PFM, D&D, PAR Plus Legal and Judicial Reform) ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ។

### ៣.២. បង្កើនកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទ កសហវ និង ក្រសួងស្ថាប័ន

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- មន្ត្រីជំនាញជាវាគ្មិន ឬ គ្រូឧទ្ទេស និង គ្រូបង្គោល ត្រូវបានរៀបចំធ្វើបច្ចុប្បន្នកម្ម,
- មន្ត្រីជំនាញជាវាគ្មិន ឬ គ្រូឧទ្ទេស និង គ្រូបង្គោល ទទួលបានការបណ្តុះបណ្តាល (TOT) បំប៉នសមត្ថភាព,
- ឯកសារគតិយុត្ត និង កម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការគាំទ្រដល់ការកសាងនិងអភិវឌ្ឍសមត្ថភាពសម្រាប់អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានសហការរៀបចំ,
- មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងស្ថាប័ន ទទួលបានការអភិវឌ្ឍសមត្ថភាពលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមលទ្ធផលវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ, និង
- មន្ត្រីរាជការចូលនិវត្តន៍របស់ កសហវ ដែលមានចំណេះដឹង និង ជំនាញប្រកបដោយសក្តានុពល ត្រូវបានលើកទឹកចិត្ត និង គាំទ្រពីថ្នាក់ដឹកនាំ ធ្វើជាគ្រូបង្គោលនៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ៣.៣. អនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព តាមការដឹកនាំណែនាំរបស់ក្រុមការងារកសាងសមត្ថភាព

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- ការតម្រង់ទិសជាយុទ្ធសាស្ត្រលើការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានណែនាំ និង ចង្អុលបង្ហាញ,
- កម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ត្រូវបាន

ទទួលការគាំទ្រ ដើម្បីអនុវត្ត,

- លទ្ធផលវាយតម្លៃតម្រូវការ និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវបានទទួលការគាំទ្រ និង ផ្តល់ការណែនាំបន្ថែម, និង
- ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានគាំទ្រ តម្រង់ទិស និង ចង្អុលបង្ហាញលើការរៀបចំបច្ចុប្បន្នកម្មបន្ថែមតាមតម្រូវការ ។

## ឃ. យុទ្ធសាស្ត្រទី ៤ : ការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ

យុទ្ធសាស្ត្រទី ៤ គ្របដណ្តប់ការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ ដោយមានកិច្ចសហប្រតិបត្តិការជាមួយតួអង្គ និង ដៃគូពាក់ព័ន្ធ សំដៅលើកកម្ពស់ការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព ។ យុទ្ធសាស្ត្រទី ៤ ផ្តោតលើទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម÷

### *៤.១. រៀបចំ និង អនុវត្តការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- មន្ត្រីជំនាញត្រូវបានពង្រឹងសមត្ថភាពបច្ចេកទេសបន្ថែម លើជំនាញវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ តាមរយៈការបណ្តុះបណ្តាលបំប៉នសមត្ថភាព និង កម្មវិធីទស្សនកិច្ចសិក្សា,
- ឯកសារណែនាំសម្រាប់ប្រតិបត្តិការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវបានរៀបចំ និង អនុវត្ត,
- មន្ត្រីរាជការជាសិក្ខាកាមគោលដៅនៅក្រសួងស្ថាប័ន ត្រូវបានវាយតម្លៃ និង ជ្រើសរើសសម្រាប់វគ្គបណ្តុះបណ្តាល និង វិក្រឹតការ, និង
- កម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួងស្ថាប័ន នៅថ្នាក់ជាតិ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសម្រាប់អនុវត្ត ។

### *៤.២. អនុវត្តការស្រាវជ្រាវ និង អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- ផែនការ និង ប្រធានបទនៃការសិក្សាស្រាវជ្រាវ ត្រូវបានទទួលការឯកភាព និង ការគាំទ្រជាគោលការណ៍ពីក្រុមការងារកសាងសមត្ថភាព និង ថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- លទ្ធផលសិក្សាស្រាវជ្រាវ និង អនុសាសន៍ ពាក់ព័ន្ធនឹងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ត្រូវបានរៀបចំ និង ផ្សព្វផ្សាយ,
- ឯកសារគតិយុត្ត និង ឯកសារតម្រង់ទិសការសិក្សាស្រាវជ្រាវ ដើម្បីប្រមូលធាតុចូលជាគោលនយោបាយយុទ្ធសាស្ត្រ និង កម្មវិធីពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវបានប្រមូល រៀបចំ និង ចងក្រង,
- កម្មវិធីវិក្រឹតការលើជំនាញថវិកាសមិទ្ធកម្មដល់អតីតសិក្ខាកាម ដែលបានទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេសកន្លងមក ត្រូវបានរៀបចំ, និង

- កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ សម្រាប់ក្រសួងស្ថាប័ន និង អង្គភាពជំនាញពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំ ។

### ខ. យុទ្ធសាស្ត្រទី ៥ : ការពង្រឹង TNA, M&E និង វិធីសាស្ត្របណ្តុះបណ្តាល

យុទ្ធសាស្ត្រទី ៥ គ្របដណ្តប់ការពង្រឹងសមត្ថភាព និង ការអនុវត្តក្របខណ្ឌតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយផ្តោតលើការរៀបចំយន្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃ តាមរយៈការបង្កើតក្រុមការងារ និង រៀបចំលក្ខខណ្ឌយោងប្រតិបត្តិ សំដៅជំរុញប្រសិទ្ធភាពអនុវត្ត ។ វិធីសាស្ត្រវាយតម្លៃ ត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ ដើម្បីជាមូលដ្ឋានសម្រាប់អនុវត្ត ។ ក្នុងនោះ ត្រូវពង្រឹងការរៀបចំរបាយការណ៍សមិទ្ធកម្មសម្រាប់គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ និង ជាព័ត៌មានដល់ស្ថាប័នពាក់ព័ន្ធ ។ យុទ្ធសាស្ត្រទី ៥ ផ្តោតលើទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ÷

#### *៥.១. ពង្រឹងយន្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- ក្រុមការងារ និង វិធីសាស្ត្រតាមដានត្រួតពិនិត្យ និង វាយតម្លៃត្រូវបានរៀបចំ ឬ ធ្វើបច្ចុប្បន្នកម្ម,
- លក្ខខណ្ឌប្រតិបត្តិរបស់ក្រុមការងារតាមដានត្រួតពិនិត្យ និង វាយតម្លៃ ត្រូវបានរៀបចំ និង អនុម័ត,
- សមត្ថភាពក្រុមការងារត្រូវបានពង្រឹង លើវិធីសាស្ត្រ និង នីតិវិធីបច្ចេកទេសតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាព,
- ផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តទិសដៅយុទ្ធសាស្ត្រ នៃផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំ និង អនុវត្ត, និង
- របាយការណ៍សមិទ្ធកម្មអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ នៃការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តទិសដៅយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានរៀបចំ និង អនុម័ត ។

#### *៥.២. ពង្រឹងយន្តការរៀបចំរបាយការណ៍សមិទ្ធកម្មលើការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព*

ផ្តោតលើសកម្មភាពយុទ្ធសាស្ត្រ និង សូចនាករសមិទ្ធកម្មគន្លឹះ ដូចខាងក្រោម÷

- របាយការណ៍វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិ និង ចុងអាណត្តិ ត្រូវបានរៀបចំ,
- បញ្ហាប្រឈមលើការអនុវត្តផែនការយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិ ត្រូវបានកែលម្អ និង ជំរុញការអនុវត្តនៅពាក់កណ្តាលអាណត្តិចុងក្រោយ, និង
- របាយការណ៍លទ្ធផលវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ត្រូវបានរៀបចំ អនុម័ត និង ផ្សព្វផ្សាយ ។

## ៣.២. ការវិភាគ និង ការគ្រប់គ្រងហានិភ័យ

ការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និង មនសិការជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ គឺជាគោលបំណង ស្របតាមចក្ខុវិស័យ នៃផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ។ ដើម្បីឱ្យផែនការយុទ្ធសាស្ត្រនេះ អនុវត្តបានរលូន និង សម្រេចគោលបំណងគ្រោងទុក, ហានិភ័យទាំងឡាយដែលអាចកើតឡើង ជាយថាហេតុ ចាំបាច់ត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយជាមុន ព្រមជាមួយ

នឹងការរៀបចំនូវមធ្យោបាយ និង វិធានការបង្ការគ្រប់គ្រាន់សមស្រប សម្រាប់ការពារ ទប់ទល់ និង ដោះស្រាយចំពោះផលវិបាក ឬ បច្ច័យអវិជ្ជមាននៃហានិភ័យទាំងនោះ ។

### ៣.២.១. ការវិភាគហានិភ័យ

ជាទូទៅ ហានិភ័យប្រតិបត្តិការ អាចនឹងកើតឡើងដោយសារកត្តាទាំងឡាយ ដូចជា ភាពខ្វះចន្លោះនៃប្រព័ន្ធគ្រប់គ្រងការងារ, ការធ្វេសប្រហែសលើការងារគ្រប់គ្រង, ភាពខ្វះចន្លោះនៃការអនុវត្តការងាររបស់មន្ត្រីទទួលបន្ទុក, ការប្រែប្រួលជាស្វ័យប្រវត្តិនៃប្រព័ន្ធបច្ចេកវិទ្យា ឬ កត្តាប្រធានស័ក្តិ ។

ក្នុងន័យនេះ ហានិភ័យចម្បងៗដែលនឹងអាចកើតមានឡើង នៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព រួមមាន÷

១. កង្វះការគាំទ្រពេញលេញពីថ្នាក់ដឹកនាំ និង មន្ត្រីបច្ចេកទេស ក្នុងការអនុវត្ត ឬ ភាពមិនស្របគ្នា នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ,

២. កង្វះការសម្របសម្រួលកិច្ចសហប្រតិបត្តិការ និង ការគាំទ្រពីស្ថាប័នទទួលសេវាបណ្តុះបណ្តាល, សមត្ថភាពចូលរួមរបស់តួអង្គពាក់ព័ន្ធនៅមានកម្រិត, សមត្ថភាពរបស់ស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលមានកម្រិត និង ការពន្យារពេលអនុវត្ត ដោយសារបច្ច័យអវិជ្ជមានណាមួយ,

៣. កង្វះធនធានគាំទ្រ ទាំងថវិកា និង ធនធានមនុស្ស សម្រាប់អនុវត្តដំណើរការកម្មវិធីបណ្តុះបណ្តាល,

៤. ការផ្លាស់ប្តូរច្បាប់ គោលនយោបាយ ការកើតវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ នយោបាយ និង សង្គម ឬ បញ្ហាប្រធានស័ក្តិ ដូចករណី គ្រោះធម្មជាតិ និង ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាដើម ។

ហានិភ័យខាងលើ អាចនឹងរារាំងដល់ការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ មិនឱ្យប្រព្រឹត្តទៅបានដោយរលូន ឬ ទទួលបានជោគជ័យ តាមគោលបំណងគ្រោងទុក ។ ដូច្នេះ ចាំបាច់ត្រូវមានការគិតគូរទុកជាមុន អំពីវិធានការ និង វិធីបង្ការហានិភ័យដែលអាចកើតឡើង ជាយថាហេតុ ។

### ៣.២.២. ការគ្រប់គ្រងហានិភ័យ

ដោយប្រកាន់ខ្ជាប់នូវស្មារតី បង្ការ ទប់ស្កាត់ និង ដោះស្រាយនូវហានិភ័យ ដែលអាចកើតឡើងជាយថាហេតុក្នុងការឈានទៅអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាំបាច់ត្រូវមានវិធានការ ដូចតទៅ÷

- រៀបចំផ្សព្វផ្សាយ និង បញ្ជ្រាបការយល់ដឹងទូលំទូលាយពីអត្ថប្រយោជន៍រួម កើតចេញពីកម្មវិធីកែទម្រង់សំដៅជំរុញការចូលរួម និង ការគាំទ្រ ចំពោះការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព,
- បណ្តុះស្មុគន្ទះលើការកសាង និង ការអភិវឌ្ឍសមត្ថភាព ទាំងតួអង្គផ្តល់សេវាបណ្តុះបណ្តាល តួអង្គទទួលសេវាបណ្តុះបណ្តាល និង តួអង្គគាំទ្រការងារបណ្តុះបណ្តាល និង រឹត្បឹតការសមត្ថភាព,
- កំណត់ផែនការសកម្មភាពច្បាស់លាស់ និង បុរេសកម្មក្នុងការតាមដាន និង ត្រួតពិនិត្យលើការអនុវត្ត ជាទៀងទាត់នូវផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព,
- បង្កើតយន្តការសម្របសម្រួលកិច្ចសហការ និង ទំនាក់ទំនងល្អ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ,
- សម្របសម្រួល និង បំពាក់បំប៉នសមត្ថភាពអំពីវិធីសាស្ត្រ និង បច្ចេកទេសបណ្តុះបណ្តាល និង រឹត្បឹតការជូនគ្រូបង្គោល និង ក្រុមការងារសម្របសម្រួល ដើម្បីគាំទ្រការអនុវត្តផែនការឱ្យបានគ្រប់ជ្រុងជ្រោយ,

- បង្កើតប្រព័ន្ធដាក់ពិន័យអ្នកមិនអនុវត្ត ឬ ប្រព្រឹត្តខុស និង លើកទឹកចិត្តអ្នកអនុវត្តការងារបានត្រឹមត្រូវ,
- អនុវត្តការកសាង និង ការអភិវឌ្ឍសមត្ថភាព ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺ: *(១). អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និង គោរពក្រមសីលធម៌វិជ្ជាជីវៈ; (២). អនុវត្តការងារជាក្រុម, (៣). អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង គោលការណ៍ប្រសិទ្ធភាពថវិកា និង (៤). មិនត្រូវមើលរំលងកំហុសខ្លួនឯង* ព្រមទាំងទទួលស្គាល់ និង កែកំហុស ដោយអនុលោមតាមអភិក្រមការងារ ៥ ប្រការ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺ «***ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់***» ៕

# ជំពូក ៤

# តួអង្គអនុវត្ត យន្តការ និង ប្រភពធនធានហិរញ្ញវត្ថុ

## ៤.១. តួអង្គអនុវត្ត

ស្ថាប័នតួអង្គ និង យន្តការអនុវត្ត ដើរតួនាទីគន្លឹះសម្រាប់ជំរុញការចូលរួម និង កិច្ចសហការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ ប្ញូក ២ និង ដំណាក់កាលទី ៤ ឱ្យសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាព ឆ្លើយតបនឹងចក្ខុវិស័យ បេសកកម្ម គោលបំណង និង គោលដៅកំណត់ ។ ចំណែកការគាំទ្រផ្នែកស្មារតី ធនធាន ហិរញ្ញវត្ថុ និង បច្ចេកទេស គឺជាមធ្យោបាយមិនអាចខ្វះបាន សម្រាប់ជំរុញជវភាពក្នុងការឆ្លើយតបនឹងតម្រូវការកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ។

ការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ស្ថិតក្រោមការដឹកនាំ និង ការសម្រេច ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រោមការដឹកនាំ និង ការណែនាំអនុវត្តផ្ទាល់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានការចូលរួមគាំទ្រ និង កិច្ចសហការពីគ្រប់ក្រសួងស្ថាប័ន និង តួអង្គជាដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ។ សមាជិកក្រុមការងារកសាងសមត្ថភាព គឺជាថ្នាក់ដឹកនាំតំណាងមកពីអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, និង អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជារួម តួអង្គអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព រួមមាន ក្រុមការងារកសាងសមត្ថភាព អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ, លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ដៃគូអភិវឌ្ឍ, ដៃគូសហប្រតិបត្តិការ និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

លើទិដ្ឋភាពបច្ចេកទេស តួអង្គអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ចែកជា ៤ ប្រភេទគឺៈ (១). តួអង្គដឹកនាំ និង ណែនាំអនុវត្តផែនការយុទ្ធសាស្ត្រ, (២). តួអង្គផ្តល់សេវាបណ្តុះបណ្តាល, (៣). តួអង្គទទួលសេវាបណ្តុះបណ្តាល, និង(៤). តួអង្គគាំទ្រការបណ្តុះបណ្តាល ។ ប្រភេទតួអង្គនីមួយៗ មានភារកិច្ច ដូចខាងក្រោម÷

### ៤.១.១. ក្រុមការងារកសាងសមត្ថភាព

- ដឹកនាំ និង ណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រលើការអនុវត្ត និង ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព,
- ដឹកនាំ និង ណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រ លើការរៀបចំផែនការ និង ការអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់តួអង្គអនុវត្តដែលទទួលបានសមិទ្ធផលល្អ,
- ជំរុញ និង គាំទ្រដំណើរការបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ឱ្យប្រព្រឹត្តទៅដោយរលូន និង មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ,

- ដឹកនាំ និង ណែនាំតម្រង់ទិសការវាយតម្លៃតម្រូវការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល និង ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃដំណើរការបណ្តុះបណ្តាល និង វិក្រឹតការ, និង
- ដឹកនាំ និង ណែនាំទម្រង់ទិសការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ។

### ៤.១.២. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍសម្រាប់ការគាំទ្រថវិកា និង សម្ភារឧបទេសចាំបាច់ ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- សម្របសម្រួល និង បញ្ជូនសំណើសុំអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ និង ក្រសួងស្ថាប័ន ទៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- សហការផ្តល់អ្នកជំនាញដើម្បីចូលរួមជាគ្រូឧទ្ទេស ឬ វាគ្មិន សម្រាប់ការបណ្តុះបណ្តាល និង វិក្រឹតការ នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- សម្របសម្រួលជាមួយលេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ, លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, លេខាធិការដ្ឋានកែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ, និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកំណត់ចំណុចប្រទាក់ក្រឡាបំពេញឱ្យគ្នា និង ត្រួតគ្នា លើតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ,
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍ ក្នុងការកៀរគរថវិកា ជំនាញការ និង ជ្រើសរើសទីប្រឹក្សា សម្រាប់គាំទ្រការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- សម្របសម្រួលការប្រមូលផែនការបណ្តុះបណ្តាលបន្ថែមប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ន និង បញ្ជូនទៅកាន់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់រៀបចំសម្របសម្រួលការអនុវត្ត ។

### ៤.១.៣. អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង មន្ទីរអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- សហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការ,
- ចាត់បញ្ជូនមន្ត្រីគោលដៅតាមលក្ខខណ្ឌកំណត់ សម្រាប់ជាសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល,
- សហការផ្តល់អ្នកជំនាញចូលរួមជាគ្រូបង្គោល គ្រូឧទ្ទេស ឬ វាគ្មិន សម្រាប់កម្មវិធីបណ្តុះបណ្តាល និង ចូលរួមវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្គោល (TOT) នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- ចូលរួមសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង តួអង្គពាក់ព័ន្ធ ក្នុងការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃដំណើរការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល និង វិក្រឹតការ, និង
- លើកសំណើមកកាន់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីស្នើសុំរៀបចំ និង សម្របសម្រួលការអនុវត្តកម្មវិធីបណ្តុះបណ្តាល វគ្គពិសេស ឬ ទស្សនកិច្ចសិក្សា ជូនមន្ត្រីរាជការនៅក្នុងអង្គភាពរបស់ខ្លួន ។

### ៤.១.៤. ក្រសួងស្ថាប័ន មន្ទីរអង្គភាពក្រោមឱវាទ រដ្ឋបាលថ្នាក់ក្រោមជាតិ និង គ្រឹះស្ថានសាធារណៈរដ្ឋបាល

- សហការផ្តល់ព័ត៌មាន និង ទិន្នន័យដល់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់វិភាគវាយតម្លៃប្រសិទ្ធភាពបណ្តុះបណ្តាល និង កំណត់តម្រូវការបណ្តុះបណ្តាលនិងវិក្រឹតការ ពាក់ព័ន្ធការលើកកម្ពស់សមត្ថភាពលើជំនាញហិរញ្ញវត្ថុសាធារណៈ,
- ចាត់បញ្ជូនមន្ត្រីរាជការគោលដៅតាមលក្ខខណ្ឌកំណត់ សម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាព

លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមតម្រូវការរបស់អង្គភាព,

- ចាត់បញ្ជូនអ្នកជំនាញ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជាគ្រូបង្គោល រៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
- ចូលរួមសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃដំណើរការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល និង វិក្រឹតការ, និង
- លើកសំណើបណ្តុះបណ្តាល និង វិក្រឹតការ ឬ ទស្សនកិច្ចសិក្សាប្រចាំឆ្នាំ លើជំនាញហិរញ្ញវត្ថុសាធារណៈ មកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសម្របសម្រួល និង រៀបចំការអនុវត្តជូនមន្ត្រីរាជការរបស់ខ្លួន ។

### ៤.១.៥. លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និង លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- ចូលរួមជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកំណត់តម្រូវការ និង ចំណុចត្រួតគ្នានៃការបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញហិរញ្ញវត្ថុសាធារណៈ សំដៅឆ្លើយតបឱ្យបានគ្រប់គ្រាន់ ទាន់ពេល និង សន្សំសំចៃថវិកាជាតិ,
- សហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គូអង្គផ្តល់សេវាបណ្តុះបណ្តាលពាក់ព័ន្ធ លើដំណើរការអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការលើជំនាញហិរញ្ញវត្ថុសាធារណៈ,
- សហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដៃគូពាក់ព័ន្ធ លើការវាយតម្លៃដំណើរការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួងស្ថាប័ន មន្ទីរអង្គភាពពាក់ព័ន្ធក្រោមឱវាទ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ៤.១.៦. ដៃគូអភិវឌ្ឍ

- សហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ, លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ក្រសួងស្ថាប័ន និង មន្ទីរអង្គភាព, រដ្ឋបាលថ្នាក់ក្រោមជាតិ, និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីកំណត់តម្រូវការ និង អនុវត្តការបណ្តុះបណ្តាលគ្រូបង្គោល និង មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ,
- ផ្តល់អ្នកជំនាញចូលរួមជាគ្រូឧទ្ទេស ឬ វាគ្មិន ក្នុងសិក្ខាសាលាពិគ្រោះយោបល់ និង ចូលរួមតាមដានត្រួតពិនិត្យ និង វាយតម្លៃដំណើរការ និង ប្រសិទ្ធភាពបណ្តុះបណ្តាល និង វិក្រឹតការ,
- សហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសិក្សាស្រាវជ្រាវ និង អភិវឌ្ឍគម្រោងបណ្តុះបណ្តាល ឬ ផ្តល់អ្នកជំនាញចូលរួមជាគ្រូឧទ្ទេស ឬ វាគ្មិន សម្រាប់វគ្គបណ្តុះបណ្តាល និង វិក្រឹតការ ឬ ផ្តល់ជំនួយបច្ចេកទេសលើការកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ។

### ៤.១.៧. ដៃគូសហប្រតិបត្តិការ

- សហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីស្រាវជ្រាវ វាយតម្លៃតម្រូវការ រៀបចំ និង អនុវត្តគម្រោងបណ្តុះបណ្តាល និង វិក្រឹតការ ជូនមន្ត្រីរាជការកម្ពុជា តាមការព្រមព្រៀងនៃគូភាគី,

- សហការគាំទ្រថវិកា សម្ភារឧបទេស បច្ចេកទេស គ្រូឧទ្ទេស និង អ្នកជំនាញ ដល់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការស្រាវជ្រាវ ការបណ្តុះបណ្តាល និង វិក្រឹតការ និង ការចូលរួមតាមដានត្រួតពិនិត្យ និង វាយតម្លៃកម្មវិធីសហការស្រាវជ្រាវ បណ្តុះបណ្តាល និង វិក្រឹតការ,
- ផ្តល់ការប្រឹក្សាយោបល់ដល់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តួអង្គផ្តល់សេវាបណ្តុះបណ្តាលផ្សេងទៀត សំដៅធ្វើទំនើបកម្មកម្មវិធី វិធីសាស្ត្រ និង បច្ចេកទេស ក្នុងការបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្គោល និង គ្រូឧទ្ទេស ស្របតាមបរិបទអន្តរជាតិ និង សេចក្តីត្រូវការរបស់កម្ពុជា ។

### ៤.១.៨. វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ជាតួអង្គផ្តល់សេវាបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- សម្របសម្រួលជាមួយគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ឱ្យប្រព្រឹត្តទៅដោយរលូន និង មានប្រសិទ្ធភាព សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- សម្របសម្រួល និង អនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ ជាធាតុចូលពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំកែលម្អកម្មវិធីបណ្តុះបណ្តាល ព្រមទាំងបោះពុម្ព ផ្សព្វផ្សាយលទ្ធផលឯកសារស្រាវជ្រាវ,
- សម្របសម្រួល និង អនុវត្តការវាយតម្លៃតម្រូវការ, ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការ, និង វាយតម្លៃកម្រិតចំណេះដឹងមូលដ្ឋានរបស់សិក្ខាកាមពាក់ព័ន្ធនឹងមុខជំនាញសិក្សា,
- ផ្តួចផ្តើម និង សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ-អន្តរជាតិ លើការស្រាវជ្រាវ ការអភិវឌ្ឍ និង ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ,
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល និង សម្របសម្រួលការចែករំលែកចំណេះដឹង និង ឧត្តមានុវត្តពីទីប្រឹក្សា និង អ្នកជំនាញ ជូនមន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និង សាស្ត្រាចារ្យ,
- ជ្រើសរើស រៀបចំបណ្តុះបណ្តាលបំប៉នសមត្ថភាពជូនគ្រូបង្គោល និង អ្នកសម្របសម្រួល និង បែងចែកគ្រូបង្គោល គ្រូឧទ្ទេស និង សាស្ត្រាចារ្យ សម្រាប់អនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ,
- សហការជាមួយតួអង្គផ្តល់សេវាបណ្តុះបណ្តាលផ្សេងទៀត តាមរយៈអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង លេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ ក្នុងការកំណត់ចំណុចត្រួតគ្នាអំពីតម្រូវការបណ្តុះបណ្តាល លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ ទាន់ពេល ចំគោលដៅ និង សន្សំសំចៃថវិកាជាតិ,
- ធ្វើបច្ចុប្បន្នកម្មគ្រូបង្គោល និង គ្រូឧទ្ទេស ឱ្យស្របទៅនឹងតម្រូវការ និង បរិការណ៍វិវឌ្ឍថ្មីៗ នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ ឱ្យបានគ្រប់ជ្រុងជ្រោយ និង ទាន់ពេល តាមសំណើរបស់ស្ថាប័នទទួលសេវាបណ្តុះបណ្តាល,
- រៀបចំ និង អនុវត្តការសិក្សាស្រាវជ្រាវ និង ការអភិវឌ្ឍគម្រោងកម្មវិធី និង វិធីសាស្ត្របណ្តុះបណ្តាល និង វិក្រឹតការប្រកបដោយនវានុវត្តន៍ ឆ្លើយតបទៅនឹងតម្រូវការកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ។

## ៤.២. យន្តការអនុវត្ត

ចរន្តលំហូរនៃប្រព័ន្ធតួអង្គ និង យន្តការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ គឺត្រូវប្រព្រឹត្តទៅតាមអភិក្រម ដូចមាននៅក្នុងគំនូសបំព្រួញនៃចលនការប្រព័ន្ធតួអង្គតែមួយ (**ឧបសម្ព័ន្ធ ៦**) ។

រៀងរាល់ឆ្នាំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំការសិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ និង ប្រមូលព័ត៌មាន និង ទិន្នន័យចាំបាច់សម្រាប់វិភាគ វាយតម្លៃ និង កំណត់តម្រូវការជាក់ស្តែង សម្រាប់ការរៀបចំផែនការតម្រូវការរួម និង រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ លើមុខជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កិច្ចការនេះ នឹងត្រូវរៀបចំសម្របសម្រួល និង អនុវត្តដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោមការដឹកនាំ និង ណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រពីក្រុមការងារកសាងសមត្ថភាព និង សហការជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ, ព្រមទាំងដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ។ ផ្អែកតាមផែនការតម្រូវការប្រចាំឆ្នាំ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសិក្សា វិភាគ និង វាយតម្លៃ ដើម្បីរៀបចំផែនការ និង កម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ហើយសម្របសម្រួលពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ សំដៅធ្វើអាទិភាវូបនីយកម្ម និង គ្រោងកញ្ចប់ថវិកាគាំទ្រ សម្រាប់គោរពស្នើសុំការពិនិត្យសម្រេច និង ការណែនាំដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្នុងករណីចាំបាច់ វិទ្យាស្ថាននឹងគោរពស្នើសុំការសម្រេចជាគោលការណ៍ និង ការណែនាំពីថ្នាក់ដឹកនាំក្រសួង ដើម្បីបង្កើត ឬបន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូជាតិ-អន្តរជាតិ លើគំនិតផ្តួចផ្តើមថ្មីៗ សម្រាប់រៀបចំ និង អនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ តាមការចង្អុលបង្ហាញពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តាមតម្រូវការស្នើឡើងដោយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងស្ថាប័ន និង មន្ទីរអង្គភាពក្រោមឱវាទ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនេះ ករណីមានតម្រូវការបណ្តុះបណ្តាលចាំបាច់បន្ទាន់ ពីអគ្គនាយកដ្ឋាន ឬ អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ក្រសួងស្ថាប័នពាក់ព័ន្ធ បន្ថែមលើគម្រោងផែនការតម្រូវការរួម ដែលទទួលការអនុម័តគាំទ្រពីថ្នាក់ដឹកនាំក្រសួងរួចហើយ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងពិនិត្យលទ្ធភាព រៀបចំគម្រោងកម្មវិធីពិសេស ដើម្បីគោរពស្នើសុំការពិនិត្យសម្រេច និង ការណែនាំពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ៤.៣. ប្រភពធនធានហិរញ្ញវត្ថុ

ជារួម ប្រភពធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺបានពីថវិការដ្ឋក្នុងក្របខណ្ឌថវិកាកម្មវិធី និង អង្គភាពថវិកា, ថវិកាដៃគូអភិវឌ្ឍក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាដៃគូសហប្រតិបត្តិការក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី អនុលោមតាមការសម្រេច និង ការណែនាំជាគោលការណ៍ពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង តាមកិច្ចព្រមព្រៀងនៃគម្រោងកម្មវិធីកិច្ចសហប្រតិបត្តិការនីមួយៗ និង ថវិកាបដិភាគពីស្ថាប័នទទួលសេវាកម្មបណ្តុះបណ្តាល ។

ចំពោះនីតិវិធីសម្រាប់ការគ្រប់គ្រង ការចាត់ចែង និង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ គឺត្រូវអនុវត្តតាមគោលការណ៍ច្បាប់ នីតិវិធី និង បទប្បញ្ញត្តិជាធរមាន របស់រាជរដ្ឋាភិបាល និង តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និង ដៃគូកិច្ចសហប្រតិបត្តិការ ។

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងស្នើសុំការណែនាំ និង ការគាំទ្រពីក្រុមការងារកសាងសមត្ថភាព ដើម្បីគោរពសុំគោលការណ៍ និង ការចង្អុលបង្ហាញ ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** សម្រាប់សិក្សាលទ្ធភាពបង្កើនវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ និង លទ្ធភាពផ្តល់សេវាដោយទទួលប្រាក់កម្រៃ ក្នុងគោលដៅពង្រីកវិសាលភាព និង សក្តានុពលភាព ឆ្លើយតបតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការរបស់ក្រសួងស្ថាប័ន ឱ្យបានគ្រប់គ្រាន់ ទាន់ពេលវេលា និង មានប្រសិទ្ធភាព ។

### ៤.៣.១. ប្រភពធនធានហិរញ្ញវត្ថុពីថវិការដ្ឋ

ថវិការដ្ឋសម្រាប់គាំទ្រការអនុវត្តការងារបណ្តុះបណ្តាល និង វិក្រឹតការ និង កិច្ចការពាក់ព័ន្ធ នឹងត្រូវរៀបចំបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ និង ផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ដែលត្រូវសម្រេច និង គាំទ្រពីថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្របតាមគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកា និង ផ្អែកតាមផែនការសកម្មភាពប្រចាំឆ្នាំ និង ស្របតាមស្មារតីផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដោយអនុលោមតាមវិធាន បទប្បញ្ញត្តិ និង លិខិតបទដ្ឋានគតិយុត្ត ជាធរមាន ។

ក្នុងមុខងារជាសេនាធិការរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងអនុវត្តមុខងារ តួនាទី និង ភារកិច្ចរបស់ខ្លួន ក្រោមការដឹកនាំ និង ណែនាំតម្រង់ទិសផ្ទាល់ កម្រិតយុទ្ធសាស្ត្រពីក្រុមការងារកសាងសមត្ថភាពនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដោយមានកិច្ចសហការ និង ការចូលរួមគាំទ្រ ពីគ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ៤.៣.២. ធនធានហិរញ្ញវត្ថុពីថវិកាដៃគូក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ទន្ទឹមនឹងប្រភពថវិការដ្ឋ ការកសាង និង ការអភិវឌ្ឍសមត្ថភាព អាចទទួលថវិកាគាំទ្រពីដៃគូអភិវឌ្ឍ តាមរយៈអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គាំទ្រការអនុវត្តផែនការសកម្មភាពរួម ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចរៀបចំសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន ដើម្បីវាយតម្លៃតម្រូវការ សម្រាប់រៀបចំផែនការបណ្តុះបណ្តាល និង វិក្រឹតការប្រចាំឆ្នាំ និង រៀបចំគ្រោងថវិកាតាមការចាំបាច់ សម្រាប់សុំការគាំទ្រពីដៃគូអភិវឌ្ឍ តាមរយៈផែនការសកម្មភាពរួម សំដៅចូលរួមចំណែកក្នុងការគាំទ្រ និង ការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព ។

### ៤.៣.៣. ធនធានហិរញ្ញវត្ថុពីថវិកាដៃគូសហប្រតិបត្តិការក្នុងក្របខណ្ឌសហប្រតិបត្តិការទ្វេភាគីឬពហុភាគី

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតួអង្គទទួលបន្ទុកការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាព លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាការងារមានវិសាលគមទូលាយ និង តម្រូវការអនុវត្តបន្តជាប្រចាំ ។ ដូច្នេះចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការទូលាយជាមួយស្ថាប័នដៃគូពាក់ព័ន្ធ ដើម្បីអាចឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងវិសាលភាពតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការជូនមន្ត្រីរាជការ ។ ក្នុងន័យនេះ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចទទួលការផ្តល់ថវិកាគាំទ្រជាបដិភាគពីដៃគូសហប្រតិបត្តិការ សម្រាប់អនុវត្តគម្រោងបណ្តុះបណ្តាល និង វិក្រឹតការ

ក្នុងក្របខណ្ឌគម្រោងកិច្ចសហប្រតិបត្តិការ ។ វិទ្យាស្ថាននឹងបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នដៃគូ ដើម្បីបង្កើនវិសាលភាពបណ្តុះបណ្តាល និង លទ្ធភាពស្វែងយល់ពីឧត្តមានុវត្តអន្តរជាតិ ជូនមន្ត្រីរាជការ សំដៅគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

សម្រាប់ទិសដៅអនាគត ដើម្បីឱ្យផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ ត្រូវបានអនុវត្តពេញលេញ និង មានប្រសិទ្ធភាព, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសិក្សាពីលទ្ធភាពបង្កើនថវិកាគាំទ្រដល់ វិនិយោគលើហេដ្ឋាចនាសម្ព័ន្ធ សម្ភារឧបទេស និង បរិក្ខារគាំទ្រ សម្រាប់អនុវត្តគម្រោងសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល និង វិក្រឹតការ លើជំនាញពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។

ក្រសួង ស្ថាប័ន និង មន្ទីរ អង្គភាពពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នឹងត្រូវរៀបចំផែនការតម្រូវការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការរបស់ខ្លួន នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និង គ្រោងថវិកាសម្រាប់គាំទ្រការអនុវត្ត ដោយស្នើសុំកិច្ចសហការពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការផ្តល់សេវាបណ្តុះបណ្តាលទាំងនោះ ក្រោមកិច្ចសហការខាងបច្ចេកទេសបណ្តុះបណ្តាលពីវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ៤.៣.៤. គម្រោងចំណាយលើការអនុវត្តផែនការយុទ្ធសាស្ត្រ

ការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ត្រូវការការចូលរួមចំណែកយ៉ាងសកម្មពីក្រសួង ស្ថាប័ន និង គ្រប់ដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ទាំងផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និង ស្មារតី ។ យោងតាមការប៉ាន់ស្មាន ចំណាយសរុបរយៈពេល ៥ ឆ្នាំ ប្រមាណជា ៧០០.០០០ ដុល្លារសហរដ្ឋអាមេរិក **(តារាងឧបសម្ព័ន្ធទី ១)** ។ ថវិកានេះគឺសម្រាប់អភិវឌ្ឍសមត្ថភាពស្ថាប័ន និង ការបណ្តុះបណ្តាលសមត្ថភាពជូនមន្ត្រីរាជការ ដើម្បីគាំទ្រ និង អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ ឱ្យទទួលបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។ កង្វះថវិកាគាំទ្រ នឹងធ្វើឱ្យផែនការសកម្មភាពដែលបានគ្រោង មិនអាចអនុវត្តបានពេញលេញ ឬ ធ្វើឱ្យលទ្ធផលមិនគ្រប់ជ្រុងជ្រោយ ដែលនឹងប៉ះពាល់ដល់គុណភាពបណ្តុះបណ្តាល និង ប្រសិទ្ធភាពនៃការអនុវត្តមុខងារ តួនាទីរបស់មន្ត្រីរាជការដែលជាសិក្ខាកាមគោលដៅ ។ ព្រោះហេតុថា ក្នុងករណី មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ មិនទទួលបានការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពពេញលេញ តាមគំរូសមត្ថភាពជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេ នោះនឹងធ្វើឱ្យពួកគាត់ជួបបញ្ហាប្រឈមលើផ្នែកចំណេះដឹង ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេសក្នុងការអនុវត្ត ដែលជាលទ្ធផល នាំឱ្យប៉ះពាល់ដល់ផលិតភាព ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការបំពេញតួនាទី ភារកិច្ចជូនអង្គភាពទាំងមូល ៕

# ជំពូក ៥
# ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

## ៥.១. យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ដើរតួយ៉ាងសំខាន់ ក្នុងការធានាឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រទទួលជោគជ័យ និង សម្រេចសមិទ្ធកម្មតាមការគ្រោងទុក ។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនឹងត្រូវតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ តាមយន្តការ និង ក្របខណ្ឌកំណត់ដោយក្រុមការងារកសាងសមត្ថភាពដែលជាតួអង្គដឹកនាំ និង ណែនាំកម្រិតយុទ្ធសាស្ត្ររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ត្រូវសម្របសម្រួលបច្ចេកទេសដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និង ដៃគូពាក់ព័ន្ធ ក្នុងការអនុវត្ត ដើម្បីធានាសង្គតិភាព និង ប្រសិទ្ធភាព នៃការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួងស្ថាប័ន សម្រាប់គាំទ្រ និង អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។

ក្នុងទិដ្ឋភាពបច្ចេកទេស ដើម្បីអនុវត្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងប្រើឧបករណ៍សំខាន់ ៣ ដូចខាងក្រោម ÷

- **របាយការណ៍តាមដានត្រួតពិនិត្យ និង វាយតម្លៃប្រចាំឆ្នាំ៖** វិទ្យាស្ថាននឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ នៅដើមត្រីមាសទី ១ ជារៀងរាល់ឆ្នាំ ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ នឹងត្រូវធ្វើឡើងតាមរយៈការពិនិត្យ និង ការវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និង របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដែលនឹងត្រូវរៀបចំ និង រាយការណ៍ជូនក្រុមការងារកសាងសមត្ថភាព ដើម្បីផ្តល់មតិដឹកនាំ និង ការណែនាំ,
- **របាយការណ៍តាមដានត្រួតពិនិត្យ និង វាយតម្លៃពាក់កណ្តាលអាណត្តិ៖** ការពិនិត្យ និង ការវាយតម្លៃផែនការពាក់កណ្តាលអាណត្តិ នឹងធ្វើឡើងនៅឆ្នាំ ២០២៣ ដើម្បីពិនិត្យវឌ្ឍនភាព និង បញ្ហាប្រឈមដែលជួបប្រទះក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ ។ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំទី ១ ឆ្នាំទី ២ និង ឆមាសទី ១ ឆ្នាំទី ៣ នឹងត្រូវប្រើដើម្បីសិក្សា វិភាគ ពិនិត្យ និង វាយតម្លៃ សំដៅស្វែងរកគន្លឹះជោគជ័យ និង ចំណុចខ្វះចន្លោះ ជាមូលដ្ឋានសម្រាប់កែលម្អ និង ជំរុញការអនុវត្តបន្ថែមទៀត នៅពាក់កណ្តាលអាណត្តិចុងក្រោយឱ្យសម្រេចបានជោគជ័យ ឆ្លើយតបទៅនឹងគោលបំណង និង គោលដៅដែលបានកំណត់, និង
- **របាយការណ៍តាមដានត្រួតពិនិត្យ និង វាយតម្លៃចុងអាណត្តិ៖** ការពិនិត្យ និង ការវាយតម្លៃផែនការយុទ្ធសាស្ត្រទាំងមូលនឹងធ្វើឡើងនៅឆ្នាំ ២០២៥ ។ ឯកសាររបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ និង លទ្ធផល នៃការតាមដានត្រួតពិនិត្យ និង វាយតម្លៃពាក់កណ្តាលអាណត្តិ រួមនឹងការធ្វើសម្ភាស កិច្ចប្រជុំពិភាក្សា និង សិក្ខាសាលាពិគ្រោះយោបល់ នឹងត្រូវប្រើជាមូលដ្ឋានសម្រាប់ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រទាំងមូល ។

## ៥.២. វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការ នឹងត្រូវធ្វើឡើងដើម្បីវាស់វែងលទ្ធផល

នៃការអនុវត្ត និង ស្វែងរកចំណុចខ្វះចន្លោះ និង ឧបសគ្គ នៃដំណើរការកសាង និង អភិវឌ្ឍសមត្ថភាព សំដៅលើក កម្ពស់ភាពគ្រប់ជ្រុងជ្រោយ និង គុណភាពបណ្តុះបណ្តាល និង វិក្រឹតការ ឆ្លើយតបនឹងតម្រូវការអង្គភាពការងារ ។ ដោយអនុលោមតាមការវិវឌ្ឍនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤, វិធីសាស្ត្រនៃការគ្រប់គ្រងផ្អែកលើលទ្ធផល បានក្លាយជាអភិក្រមថ្មីមួយសម្រាប់កំណត់លទ្ធផល អាទិភាពក្នុងការអនុវត្តការងារ ដែលចាប់ផ្តើមពីការរៀបចំផែនការ, ការតាមដាន, និង ការវាយតម្លៃការឆ្លើយតប ឆ្លុះបញ្ចាំងនូវសមិទ្ធកម្មអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ពិសេស មន្ត្រីរាជការអតីតសិក្ខាកាមទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ និង កម្រិត សញ្ញាបត្រ ។ អភិក្រមនេះ នឹងត្រូវគោរពតាមគោលការណ៍គន្លឹះ ៣ គឺ: *(១). ការប្រកាន់ខ្ជាប់នូវគណនេយ្យភាព ចំពោះភាគីពាក់ព័ន្ធ ដោយចែករំលែកនូវលទ្ធផលរួម, (២). ការអនុវត្តការងារប្រកបដោយភាពម្ចាស់ការលើសូចនាករ គន្លឹះដែលបានដាក់ចេញ, និង (៣). ការធ្វើបរិយាប័ន្នភាពពីគ្រប់ភាគីពាក់ព័ន្ធ* ដើម្បីប្រមូលធាតុចូល ជាគំនិត មតិ យោបល់ បច្ចេកទេស និង ហិរញ្ញវត្ថុ សម្រាប់គាំទ្រការងារកសាង និង អភិវឌ្ឍសមត្ថភាព ។

ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ នឹងត្រូវរៀបចំទៅតាមទម្រង់បទដ្ឋានកំណត់ គ្រប់ជ្រុងជ្រោយ និង កំណត់ជាក់លាក់អំពីសូចនាករគន្លឹះ កម្រិតលទ្ធផលចុងក្រោយ (Outcome) និង លទ្ធផលក្នុងឆ្នាំ (Output) ព្រមទាំងកំណត់អំពីទម្ងន់នៃសកម្មភាពការងារ ដើម្បីឆ្លុះពីសមិទ្ធកម្ម ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។ ការរៀបចំ និង ការធ្វើបច្ចុប្បន្នកម្មឧបករណ៍ត្រួតពិនិត្យ តាមដាន និង វាយតម្លៃការបណ្តុះបណ្តាល និង វិក្រឹតការ ដូចជាទម្រង់បែបបទវាយតម្លៃវគ្គបណ្តុះបណ្តាល ទម្រង់បែបបទស្ទង់មតិសិក្ខាកាម បុគ្គលិក និង ថ្នាក់ដឹកនាំ ទម្រង់ បែបបទប្រៀបធៀប និង ទម្រង់បែបបទវាយតម្លៃតម្រូវការបណ្តុះបណ្តាល រួមទាំងវិធីសាស្ត្រនៃការវាយតម្លៃ ជាដើម នឹងត្រូវសម្រួច យោងតាមបទដ្ឋានថ្មីៗ និង បទពិសោធន៍អនុវត្តកន្លងមក ។ ការរៀបចំទម្រង់របាយការណ៍សមិទ្ធកម្ម ក៏ត្រូវរៀបចំ ដោយអនុលោមតាមការណែនាំពីក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសម្រួច និង សម្រិតសម្រាំង ដោយផ្សារភ្ជាប់លទ្ធផលនៃការអនុវត្តជាក់ស្តែង និង មានសង្គតិភាពនឹងគោលបំណង និង គោលដៅនៃផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ។ វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ការបណ្តុះបណ្តាល និង វិក្រឹតការ រួមមានដូចខាងក្រោម ÷

### ៥.២.១. ការត្រួតពិនិត្យចំណេះដឹងមូលដ្ឋានរបស់សិក្ខាកាមមុនវគ្គបណ្តុះបណ្តាលចាប់ផ្តើម

ការត្រួតពិនិត្យចំណេះដឹង ជំនាញមូលដ្ឋាន គឺការធ្វើតេស្តវាស់កម្រិតចំណេះដឹងទូទៅ និង ជំនាញមូលដ្ឋាន របស់សិក្ខាកាម ដើម្បីស្វែងយល់ និង កំណត់វិធីសាស្ត្រ និង បច្ចេកទេសបង្រៀន ទៅតាមប្រធានបទ និង ចំណុច សំខាន់ៗ នៃកម្មវិធីបណ្តុះបណ្តាល ។ ម្យ៉ាងទៀតលទ្ធផលនោះ នឹងប្រើជាចំណុចមូលដ្ឋាន សម្រាប់វាស់វែងប្រៀប ធៀបកម្រិតនៃចំណេះដឹង និង ជំនាញរបស់សិក្ខាកាម នៅក្រោយពេលបញ្ចប់វគ្គសិក្សា ។ ការវាស់ស្ទង់នេះ អាច ប្រព្រឹត្តទៅតាមរយៈការប្រឡងសំណេរ ឬ ការរៀបចំឱ្យសិក្ខាកាមបំពេញកម្រងសំណួរបច្ចេកទេស ទៅតាមការចាំបាច់ នៃប្រធានបទរបស់វគ្គសិក្សានីមួយៗ ។ ការធ្វើតេស្តវាស់ស្ទង់សមត្ថភាពចំណេះដឹង និង ជំនាញមូលដ្ឋាននេះ គឺជា វិធីសាស្ត្រវាយតម្លៃដែលមានលក្ខណៈជាជម្រើស ពោលគឺ ការអនុវត្តអាស្រ័យទៅនឹងលក្ខណសម្បត្តិ របស់សិក្ខាកាម គោលដៅ និង លក្ខខណ្ឌចាំបាច់នៃវគ្គសិក្សានីមួយៗ ។

### ៥.២.២. ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការវគ្គបណ្តុះបណ្តាល

ការត្រួតពិនិត្យប្រសិទ្ធភាពនេះ គឺជាការវាយតម្លៃអំពីភាពពេញចិត្តរបស់សិក្ខាកាម ចំពោះមាតិកានៃមុខវិជ្ជា ខ្លឹមសារប្រធានបទ គ្រូឧទ្ទេស វិធីសាស្ត្រ ឯកសារបង្រៀន កម្មវិធី ថ្នាក់រៀន សម្ភារឧបទេស និង ការសម្របសម្រួល ទូទៅដែលធ្វើឱ្យដំណើរការសិក្សាប្រព្រឹត្តទៅបានរលូន និង ជួយឱ្យសិក្ខាកាមទទួលបានចំណេះដឹង និង ជំនាញ តាមការរំពឹងទុក ។ វិធីសាស្ត្រត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការបណ្តុះបណ្តាល ប្រព្រឹត្តទៅដោយប្រើកម្រងសំណួរ ដែលលក្ខណៈជារចនាសម្ព័ន្ធត្រឹមត្រូវ សម្រាប់ឱ្យសិក្ខាកាមបំពេញ ឬ ចូលក្នុងតំណភ្ជាប់ប្រព័ន្ធវាយតម្លៃកម្មវិធី របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅចុងបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ ។ កម្មវិធីនេះនឹងជួយឱ្យ វិទ្យាស្ថាន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការវាយតម្លៃសេចក្តីពេញចិត្តរបស់សិក្ខាកាម ចំពោះវគ្គសិក្សា និង ចំណុចខ្វះចន្លោះនៃ ការផ្តល់សេវាបណ្តុះបណ្តាល ដែលត្រូវកែលម្អសម្រាប់ការរៀបចំនៅលើកក្រោយៗ ។

### ៥.២.៣. ការត្រួតពិនិត្យកម្រិតចំណេះដឹង និង ជំនាញបច្ចេកទេសទទួលបាន

ការត្រួតពិនិត្យកម្រិតចំណេះដឹង និង ជំនាញបច្ចេកទេសសិក្ខាកាមទទួលបាន គឺវាយតម្លៃអំពីកម្រិតយល់ដឹង របស់សិក្ខាកាមក្រោយពេលបញ្ចប់វគ្គសិក្សា ។ ការវាស់ស្ទង់នេះនឹងត្រូវធ្វើឡើងតាមរយៈការប្រឡងបញ្ចប់ ឬ ការធ្វើ សម្ភាសផ្ទាល់ជាមួយសិក្ខាកាមដែលបានចូលរួមការបណ្តុះបណ្តាល ឬ អ្នកទទួលខុសត្រូវនៃអង្គភាពការងាររបស់ សិក្ខាកាម ឬ សហសេវិករបស់សិក្ខាកាម ដើម្បីបញ្ជាក់ពីកម្រិតអភិវឌ្ឍការងាររបស់សិក្ខាកាម និង ការពេញចិត្ត ឬ អត្ថប្រយោជន៍ដែលអង្គភាព ឬ សហសេវិកទទួលបានពីសិក្ខាកាម សំដៅរួមចំណែកសម្រេចគោលដៅ និង បេសកកម្ម របស់អង្គភាព ។ ការវាយតម្លៃនេះ គឺជាយន្តការសម្រាប់ឆ្លុះបញ្ចាំងពីសមត្ថភាព និង ចំណេះដឹងដែលសិក្ខាកាម ទទួលបានពីវគ្គសិក្សា, គុណភាពនៃការបណ្តុះបណ្តាល និង សក្ខីកម្មនៃការប្រគល់ជូននូវវិញ្ញាបនបត្រ ឬ សញ្ញាបត្រ បញ្ចប់ការសិក្សា ។

### ៥.២.៤. ការវាយតម្លៃប្រសិទ្ធភាពក្រោយវគ្គបណ្តុះបណ្តាល

វិធីសាស្ត្រនេះ គឺជាការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រើចំណេះដឹង និង ជំនាញឯកទេស ដែលសិក្ខាកាម ទទួលបាននៅក្នុងការដ្ឋានការងារ ក្រោយការបណ្តុះបណ្តាល ។ ការវាយតម្លៃការប្រើចំណេះដឹង និង ជំនាញនេះ អាច ប្រព្រឹត្តទៅក្នុងរយៈពេលមួយឆ្នាំ ក្រោយការបណ្តុះបណ្តាល និង តាមរយៈការធ្វើសម្ភាសជាមួយថ្នាក់ដឹកនាំអង្គភាព ឬ ថ្នាក់ដឹកនាំតំណាង ក្រសួងស្ថាប័ន ឬ ជាមួយសិក្ខាកាមផ្ទាល់ ឬ ជាមួយសហសេវិករបស់សិក្ខាកាម ។ ការវាយតម្លៃ ការប្រើជំនាញបច្ចេកទេសត្រូវអនុវត្តតាមរយៈការវាស់វែងលទ្ធផល នៃការអនុវត្តការងាររបស់អតីតសិក្ខាកាម ។ ការវាយតម្លៃអាចផ្តោតទៅលើចំណុចសំខាន់ពីរគឺ *ផលប៉ះពាល់ទៅលើលក្ខខណ្ឌ និង បរិយាកាសការងារ សម្រាប់ ការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការប្រៀបធៀបសមិទ្ធកម្មការងាររបស់សិក្ខាកាម នៅមុន និង ក្រោយការបណ្តុះបណ្តាល* ។ ការទទួលបាននូវការដំឡើងឋានៈ មុខងារ តួនាទី និង ការលើកទឹកចិត្តផ្សេងៗ ទាំងខាងហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ ដែលសិក្ខាកាមទទួលបាន ដោយគុណបំណាច់ក្នុងការអនុវត្តការងារជូនអង្គភាព ក្រោយពេលបញ្ចប់វគ្គសិក្សា គឺជាសក្ខីកម្មដ៏សំខាន់ ដែលបង្ហាញពីប្រសិទ្ធភាពនៃការប្រើចំណេះដឹង ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេសទទួលពីវគ្គសិក្សា ។

ការវាយតម្លៃនេះគ្របដណ្តប់ដល់វិសាលភាពនៃអត្ថប្រយោជន៍ទទួលពីការបណ្តុះបណ្តាល ដែលមិនបញ្ចប់ត្រឹម សិក្ខាកាម និង ការងារគាត់ក្នុងអង្គភាពទេ ។ ចំណេះដឹងអាចត្រូវបានចែករំលែកពីសិក្ខាកាមទៅសហសេវិករួមការងារ ឬ មិត្តភក្តិរួមអាជីព ដែលអាចប្រព្រឹត្តទៅជាការពិភាក្សា ផ្លាស់ប្តូរគំនិតយោបល់ និង សិក្ខាសាលាផ្សព្វផ្សាយ ជាដើម ។

## ៥.៣. ប្រព័ន្ធរបាយការណ៍សមិទ្ធកម្ម

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និង ចុងអាណត្តិស្តីពីវឌ្ឍនភាព និង បញ្ហាប្រឈម នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ កសាង និង អភិវឌ្ឍសមត្ថភាពនេះ ដោយសហការជាមួយតួអង្គពាក់ព័ន្ធ ផ្អែកលើលទ្ធផលសម្រេចបាន ធៀបនឹង គោលបំណង គោលដៅយុទ្ធសាស្ត្រ និង ផែនការសកម្មភាពដែលបានកំណត់ និង គោរពរាយការណ៍ ជូនប្រធាន ក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ អនុម័ត និង ផ្តល់ការណែនាំ និង រៀបចំជារបាយការណ៍ គោរពស្នើសុំការពិនិត្យសម្រេច និង ការណែនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៕

# ជំពូក ៦
# សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍធនធានមនុស្ស គឺជាតម្រូវការអាទិភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការ និង ការទទួលខុសត្រូវ សម្រាប់រួមចំណែកលើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានយកចិត្តទុកដាក់ជានិច្ច លើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ តាមបទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ដំណាក់កាលទី ៣ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តបង្កើនការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ សំដៅអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេសជូនមន្ត្រីរាជការហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តតួនាទី ភារកិច្ច ប្រកបដោយ ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។ ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ អាចត្រូវបានធ្វើបច្ចុប្បន្នកម្មឡើងវិញ តាមការចាំបាច់ ស្របទៅនឹងបរិការណ៍ជាក់ស្តែងនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ។

ក្នុងទិដ្ឋភាពបច្ចេកទេស ស្ថាប័នតួអង្គចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព មាន ៤ ប្រភេទគឺ: តួអង្គដឹកនាំ និង ណែនាំអនុវត្ត, តួអង្គផ្តល់សេវាបណ្តុះបណ្តាល, តួអង្គទទួលសេវាបណ្តុះបណ្តាល, និង តួអង្គគាំទ្រការបណ្តុះបណ្តាល ។ តួអង្គដឹកនាំ និង ណែនាំ គឺក្រុមការងារកសាងសមត្ថភាព នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ តួអង្គផ្តល់សេវាបណ្តុះបណ្តាលគឺវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ តួអង្គទទួលសេវាបណ្តុះបណ្តាល គឺអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងស្ថាប័ន មន្ទីរអង្គភាពក្រោមឱវាទ គ្រឹះស្ថានសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។ តួអង្គគាំទ្រការបណ្តុះបណ្តាលសំដៅអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ និង ដៃគូពាក់ព័ន្ធ ។

ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម គោលបំណង និង គោលដៅនៃការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានកំណត់យុទ្ធសាស្ត្រសំខាន់ៗ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម ÷

- **យុទ្ធសាស្ត្រទី ១** គ្របដណ្តប់ការបណ្តុះសុជន្មៈមន្ត្រីរាជការ ក្នុងការលើកកម្ពស់សមត្ថភាព ឆ្លើយតបតម្រូវការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- **យុទ្ធសាស្ត្រទី ២** គ្របដណ្តប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដែលជាតួអង្គផ្តល់សេវាបណ្តុះបណ្តាល ដោយធ្វើទំនើបកម្ម និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងសន្និធិចំណេះដឹង បណ្ណាល័យ និង អភិវឌ្ឍធនធានមនុស្ស ពិសេស គ្រូបង្គោល គ្រូជំនួយ និង មន្ត្រីសម្របសម្រួលការបណ្តុះបណ្តាលរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការងារកសាង និង អភិវឌ្ឍសមត្ថភាព ។
- **យុទ្ធសាស្ត្រទី ៣** គ្របដណ្តប់ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការពេញលេញនៃប្រព័ន្ធតួអង្គពាក់ព័ន្ធ លើ

ការគាំទ្រទាំងស្មារតី បច្ចេកទេស និង ធនធានហិរញ្ញវត្ថុ ដើម្បីឱ្យការកសាង និង ការអភិវឌ្ឍសមត្ថភាពលើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព្រឹត្តទៅបានរលូន គ្រប់គ្រាន់ និង ទាន់ពេល ។

- **យុទ្ធសាស្ត្រទី ៤** គ្របដណ្តប់ការពង្រឹងពង្រីកការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់តួអង្គ និង ដៃគូពាក់ព័ន្ធ សំដៅជំរុញ លើកកម្ពស់ការផ្តល់សេវាបណ្តុះបណ្តាល ប្រកបដោយគុណភាព ប្រសិទ្ធភាព និង មានលក្ខណវិជ្ជាជីវៈស៊ីជម្រៅ ។
- **យុទ្ធសាស្ត្រទី ៥** គ្របដណ្តប់ការពង្រឹងការតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និង ផ្តោតលើការរៀបចំយន្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ការបង្កើតក្រុមការងារ និង រៀបចំលក្ខខណ្ឌយោងសម្រាប់អនុវត្ត ។

ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការ គឺៈ *(១). អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និង គោរពក្រមសីលធម៌វិជ្ជាជីវៈ; (២). អនុវត្តការងារជាក្រុម, (៣). អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង គោលការណ៍ប្រសិទ្ធភាពថវិកា និង (៤). មិនត្រូវមើលរំលងកំហុសខ្លួនឯង* ព្រមទាំង ទទួលស្គាល់កែកំហុស ដោយអនុលោមនឹងអភិក្រមការងារ ៥ ប្រការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺ «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល** និង **វះកាត់**» ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ សំដៅអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និង កោសល្យឯកទេសប្រកបដោយ គុណភាព នវានុវត្តន៍ និង មនសិការ ជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តតួនាទីភារកិច្ច ជូនអង្គភាពការងារឱ្យសម្រេចជោគជ័យប្រកបដោយផលិតភាព ប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់ ។

ក្នុងស្មារតីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹមថា ផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពនេះ នឹងក្លាយជាត្រីវិស័យតម្រង់ទិស ដ៏ពិតប្រាកដ សម្រាប់ការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និង ទទួលបានការចូលរួមអនុវត្ត និង កិច្ចសហការ ប្រកបដោយបុរេសកម្ម និង សកម្ម ពីគ្រប់ក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ រួមនឹងកិច្ចសហការ និង ការចូលរួមគាំទ្រទូលំទូលាយ ទាំងខាងស្មារតី ហិរញ្ញវត្ថុ និង បច្ចេកទេស ពីដៃគូអភិវឌ្ឍ សំដៅចូលរួមចំណែកក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ៕

# ឧបសម្ព័ន្ធ

# នៃ

# ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤

# បញ្ជីឧបសម្ព័ន្ធ


**ឧបសម្ព័ន្ធ ១ :** ផែនការសកម្មភាពស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ឆ្នាំ ២០២១-២០២៥ សម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន *(ទំព័រទី ៤៧)*

**ឧបសម្ព័ន្ធ ២ :** តារាងកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព ឆ្នាំ ២០២១-២០២៥ សម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន *(ទំព័រទី ៥៦)*

**ឧបសម្ព័ន្ធ ៣ :** ក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ *(ទំព័រទី ៥៨)*

**ឧបសម្ព័ន្ធ ៤ :** មុខជំនាញឯកទេស និង មុខជំនាញគាំទ្រការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ *(ទំព័រទី ៥៩)*

**ឧបសម្ព័ន្ធ ៥ :** គោលដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង តម្រូវការមុខជំនាញសម្រាប់កសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ *(ទំព័រទី ៦៣)*

**ឧបសម្ព័ន្ធ ៦ :** ចលនការប្រព័ន្ធតួអង្គ និង យន្តការអនុវត្តការកសាង និង ការអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌ PFMRP ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤ *(ទំព័រទី ៦៤)*

**ឧបសម្ព័ន្ធ ៧ :** សមិទ្ធកម្មសំខាន់ៗនៃការបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០១៣-២០២០ *(ទំព័រទី ៦៥)*

**ឧបសម្ព័ន្ធ ៨ :** ក្រសួង ស្ថាប័ន មន្ទីរអង្គភាព និង អង្គភាពថវិកាទូទាំងប្រទេស *(ទំព័រទី ៦៨)*

**ឧបសម្ព័ន្ធ ៩ :** តារាងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅព្រះរាជាណាចក្រកម្ពុជា *(ទំព័រទី ៨១)*

## ឧបសម្ព័ន្ធ ១: ផែនការសកម្មភាពស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព ឆ្នាំ ២០២១-២០២៥
## សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន

### ក. យុទ្ធសាស្ត្រទី ១: ការបណ្តុះឆន្ទៈលើការកសាង និង ការអភិវឌ្ឍសមត្ថភាព

*១.១. រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រ និងបណ្តុះសុឆន្ទៈលើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** រៀបចំវិធានជាលិខិតបទដ្ឋានគតិយុត្ត និង គោលការណ៍ លើកទឹកចិត្តគ្រូបង្គោល សម្រាប់កសាង និង អភិវឌ្ឍសមត្ថភាព មន្ត្រីរាជការនៅគ្រប់កម្រិត | វិធានកំណត់គុណវុឌ្ឍិសិក្ខាកាមគោលដៅលើ ជំនាញពាក់ព័ន្ធ PFM ត្រូវបានរៀបចំ | x | x | | | | វសហ | 10.000USD (2 workshops) |
| | លិខិតបទដ្ឋានគតិយុត្តតែងតាំង និង លើកទឹកចិត្ត គ្រូបង្គោលរបស់ កសហវ ត្រូវបានរៀបចំ | x | x | | | | វសហ | 00USD |
| **២.** រៀបចំឯកសារទស្សនាទានស្តីពីការកំណត់គុណវុឌ្ឍិមន្ត្រី គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្រប់កម្រិត | ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីរាជការ ជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ | x | x | | | | វសហ | 00USD |
| **៣.** រៀបចំឯកសារទស្សនាទានអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតសញ្ញាបត្រ | ឯកសារទស្សនាទានអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ជំនាញបច្ចេកទេស កម្រិតសញ្ញាបត្រ ត្រូវបានរៀបចំ | | | | x | x | វសហ | 00USD |

*១.២. បណ្តុះសុឆន្ទៈ និង ភាពជាម្ចាស់លើការងារកែទម្រង់ក្នុងស្មារតីទទួលខុសត្រូវ ផ្សារភ្ជាប់នឹងការងារកសាង និង អភិវឌ្ឍសមត្ថភាព*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១. រៀបចំផ្សព្វផ្សាយចំណេះដឹង បទពិសោធន៍ និង ឧត្តមានុវត្តន៍ បង្កើនការយល់ដឹង សមត្ថភាព បណ្ដុះឆន្ទៈ ភាពជាម្ចាស់ និង ការទទួលខុសត្រូវលើ PFM ដល់សិក្ខាកាម | សិក្ខាសាលាលើកកម្ពស់សមត្ថភាព ការយល់ដឹង បណ្ដុះសុឆន្ទៈ ភាពជាម្ចាស់ ការទទួលខុសត្រូវ លើ PFM ត្រូវបានអនុវត្ត | | x | x | x | x | វសហ, អគហ អង្គភាពពាក់ព័ន្ធ | 30.000 USD |
| ២. បង្កើនឱកាស និង លើកទឹកចិត្តមន្ត្រីរាជការទទួលបានលទ្ធផលល្អក្នុងការចូលរួមការបណ្ដុះបណ្ដាល | មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈដែលទទួលលទ្ធផលល្អក្នុងការសិក្សា ត្រូវបានលើកទឹកចិត្ត | | x | x | x | x | វសហ | 00 USD |
| ៣. រៀបចំ និង អនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីអនុវត្ត SCDP3+2 and 4 | ផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្ត SCDP3+2 and 4 ត្រូវបានអនុវត្ត ៨០% | x | x | x | x | x | វសហ | 00 USD |
| ៤. ជំរុញលទ្ធផលនៃការសិក្សារបស់សិក្ខាកាមទទួលការបណ្ដុះបណ្ដាល TCPFM | សិក្ខាកាមវគ្គ TCPFM បានបញ្ចប់ការសិក្សាដោយជោគជ័យ យ៉ាងតិច ៨០% | x | x | x | x | x | វសហ | 00 USD |

### *១.៣. អនុវត្តកម្មវិធីបណ្ដុះបណ្ដាល និង វិក្រឹតការដែលមានលក្ខណៈឆ្លើយតប*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| ១. រៀបចំអនុវត្តវគ្គវិក្រឹតការ PFM ជំ. ទី៤ លើថវិកាសមិទ្ធកម្ម ដល់អតីតសិក្ខាកាមវគ្គ TCPFM ជំ. ទី៣ | វគ្គវិក្រឹតការ ១៥វគ្គ ត្រូវបានរៀបចំជូនអតីតសិក្ខាកាមវគ្គ TCPFM ទី៣ | | | x | x | x | វសហ | 45.000 USD |
| ២.អនុវត្តវគ្គ TCPFM ជូនមន្ត្រីរាជការ LMGA រដ្ឋបាលថ្នាក់ក្រោមជាតិ និង គ្រឹះស្ថានសាធារណៈរដ្ឋបាល | វគ្គ TCPFM ៣០ វគ្គ ត្រូវបានរៀបចំជូន LMGA | x | x | x | x | x | វសហ | 79.500 USD |
| | TCPFM ១៥វគ្គជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល | | | x | x | x | វសហ | 39.750 USD |
| | TCPFM ២០វគ្គ បានរៀបចំជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | | | x | x | x | វសហ | 66.250 USD |

### *១.៤ វាយតម្លៃគុណភាព ប្រសិទ្ធភាព និង សមិទ្ធកម្មនៃការបណ្ដុះបណ្ដាល និង វិក្រឹតការ*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១. រៀបចំយន្តការ និងវិធីសាស្ត្រវាយតម្លៃគុណភាព ប្រសិទ្ធភាព សមិទ្ធកម្មវគ្គបណ្តុះបណ្តាល TCPFM | ឯកសារណែនាំប្រតិបត្តិការវាយតម្លៃគុណភាព ប្រសិទ្ធភាព សមិទ្ធកម្ម TCPFM ត្រូវបានរៀបចំ | | | x | x | | វសហ | 00 USD |
| ២. អនុវត្តការវាយតម្លៃប្រសិទ្ធភាពបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រ | របាយការណ៍វាយតម្លៃប្រសិទ្ធភាពវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រ ត្រូវបានរៀបចំ | x | | x | | x | វសហ | 15.000 USD |

## ខ. យុទ្ធសាស្ត្រទី ២: ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស

### *២.១. លើកកម្ពស់សមត្ថភាព និង ជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| ១. ពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ វសហ តាមរយៈកម្មវិធីសិក្ខាសាលា និង ទស្សនកិច្ចសិក្សា | កម្មវិធីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ វសហ ត្រូវបានរៀបចំ និង អនុវត្ត | | | x | x | x | វសហ | 17.500 USD |
| ២. ពង្រឹងសមត្ថភាពមន្ត្រី វសហ តាមរយៈ កម្មវិធីបណ្តុះបណ្តាលបំប៉នសមត្ថភាព | កម្មវិធីពង្រឹងសមត្ថភាពមន្ត្រី វសហ ត្រូវបានរៀបចំ និង អនុវត្ត | | | x | x | x | វសហ | 17.500 USD |
| ៣. ពង្រឹងសមត្ថភាពជូនគ្រូបង្គោល វសហ តាមរយៈទស្សនកិច្ចសិក្សា និង សិក្ខាសាលាពាក់ព័ន្ធ | កម្មវិធីពង្រឹងសមត្ថភាពជូនគ្រូបង្គោល វសហ ត្រូវបានរៀបចំ និង អនុវត្ត | | | x | x | x | វសហ | 17.500 USD |
| ៤. លើកទឹកចិត្តថ្នាក់ដឹកនាំ និង មន្ត្រី វសហ ឱ្យទទួលបានការសិក្សាកម្រិតសញ្ញាបត្រ | ថ្នាក់ដឹកនាំ និង មន្ត្រី វសហ ត្រូវបានលើកទឹកចិត្តទទួលការសិក្សាកម្រិតសញ្ញាបត្រ | | | x | x | x | វសហ | 00 USD |
| ៥. លើកទឹកចិត្តមន្ត្រី គ្រូបង្គោល និង គ្រូឧទ្ទេសមានស្នាដៃល្អ | មន្ត្រី គ្រូបង្គោលនិងគ្រូឧទ្ទេសល្អត្រូវបានលើកទឹកចិត្ត | | | x | x | x | វសហ | 00 USD |

## ២.២. រៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល និង មូលដ្ឋានផ្ទុកឯកសារគាំទ្រការស្រាវជ្រាវ និង បណ្តុះបណ្តាល

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | រយៈពេលវែង | | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| ១. កែលម្អហេដ្ឋារចនាសម្ព័ន្ធ បំពាក់សម្ភាររូបវ័ន្ត គាំទ្រការអនុវត្ត កបប និង ការងារស្រាវជ្រាវ | ការសិក្សាលទ្ធភាព លើការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភាររូបវ័ន្ត ត្រូវបានរៀបចំ | | x | x | | | វសហ | 12.000 USD |
| | ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភាររូបវ័ន្តគាំទ្រ ត្រូវបានរៀបចំ និង កែលម្អ | | | x | x | | វសហ | 100.000 USD |
| ២. រៀបចំ OM នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល | ឯកសារណែនាំប្រតិបត្តិការ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល ត្រូវបានរៀបចំ | | | x | x | | វសហ | 10.000 USD |
| ៣. រៀបចំរចនាសម្ព័ន្ធគាំទ្រដំណើរការរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល | រចនាសម្ព័ន្ធគាំទ្រ ត្រូវបានរៀបចំ និង អនុម័តដោយថ្នាក់ដឹកនាំ កសហវ | | x | | | | វសហ | 00 USD |
| ៤. ធ្វើទំនើបកម្មបណ្ណាល័យ ប្រព័ន្ធទិន្នន័យ និង គេហទំព័រ វសហ ដើម្បីគាំទ្រការបណ្តុះបណ្តាល និង ស្រាវជ្រាវ | បណ្ណាល័យ នៃ វសហ ត្រូវបានធ្វើទំនើបកម្មជាបណ្ណាល័យអេឡិចត្រូនិច (E-Library) | | | x | x | x | វសហ | 10.000 USD |
| | ប្រព័ន្ធទិន្នន័យ (Database) ត្រូវបានរៀបចំកែលម្អ គ្រប់គ្រង និង អភិវឌ្ឍ | | | x | x | x | វសហ | 3.000 USD |
| | ប្រព័ន្ធទិន្នន័យ (Database) ត្រូវបានរៀបចំ និង កត់ត្រាជាប្រចាំ | | | x | x | x | វសហ | 3.000 USD |
| | គេហទំព័រ និង ប្រព័ន្ធផ្សព្វផ្សាយ នៃ វសហ ត្រូវបានរៀបចំកែលម្អ គ្រប់គ្រង និង អភិវឌ្ឍ | | | x | x | x | វសហ | 00 USD |

### ២.៣. បង្កើនការពង្រឹងអភិបាលកិច្ចស្ថាប័នរបស់វិទ្យាស្ថាន

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** ពង្រឹងអភិបាលកិច្ច នៃ វសហ ក្នុងការអនុវត្តការងារកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ | នីតិវិធីអនុវត្តតួនាទី ភារកិច្ច អង្គភាពក្រោមឱវាទ វសហ ត្រូវបានរៀបចំ កែលម្អ និង អនុវត្ត | | x | x | | | វសហ | 00 USD |
| **២.** អនុវត្តផែនការសកម្មភាពរួម និង ផែនការថវិកា សម្រាប់ SCDP របស់ កសហវ | ផែនការសកម្មភាពរួម និង ផែនការថវិកា SCDP របស់ កសហវ ត្រូវបានរៀបចំ និង អនុវត្ត | | x | x | x | x | វសហ | 00 USD |
| **៣.** ត្រួតពិនិត្យវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរួម និង ផែនការថវិកា សម្រាប់អនុវត្ត SCDP របស់ កសហវ | របាយការណ៍លទ្ធផលនៃការអនុវត្តផែនការ ត្រូវបានរៀបចំ និង ដាក់ជូនថ្នាក់ដឹកនាំ កសហវ | | x | x | x | x | វសហ | 00 USD |

## គ. យុទ្ធសាស្ត្រទី ៣: ការពង្រឹងកិច្ចសហប្រតិបត្តិការប្រព័ន្ធតួអង្គគាំទ្រការកសាង និង ការអភិវឌ្ឍសមត្ថភាព

### ៣.១. បង្កើនកិច្ចសហការជាមួយ អគហ លេខាធិការដ្ឋាននៃការកែទម្រង់៣ ប្លុក ១ និង គ្រប់តួអង្គដៃគូ

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** សហការជាមួយ អគហ លើការគាំទ្រថវិកា និង ជំនាញក្នុងការកសាង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងក្របខណ្ឌ PFM ដំណាក់កាល ៣ ប្លុក ២ និង ដំណាក់កាល ទី ៤ | តម្រូវការកសាង និង អភិវឌ្ឍសមត្ថភាព ត្រូវបានគាំទ្រពីថ្នាក់ដឹកនាំ អគហ ផ្អែកតាម GDAP3+2 GDAP4 CAP3+2 និង CAP4 | x | x | x | x | x | វសហ<br>និង អគហ | 00 USD |
| **២.** បង្កើនកិច្ចសហការជាមួយ អគហ អនុវត្ត GDAP3+2 GDAP4 CAP3+2 និង CAP4 ឱ្យកាន់តែល្អប្រសើរ | អនុវត្ត GDAP3+2 GDAP4 CAP3+2 និង CAP4 ដោយមានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ | x | x | x | x | x | វសហ<br>និង អគហ | 00 USD |
| **៣.** សហការជាមួយដៃគូអភិវឌ្ឍ និង ដៃគូសហប្រតិបត្តិការលើការកសាង និង ការអភិវឌ្ឍសមត្ថភាពស្ថាប័ន | គម្រោងលើការកសាង និង ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ត្រូវបានគាំទ្រ | x | x | x | x | x | វសហ និងដៃគូអភិវឌ្ឍ និង ដៃគូសហប្រតិបត្តិការ | 00 USD |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **៤.** សហការជាមួយលេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ ដើម្បីកំណត់តម្រូវការបណ្តុះបណ្តាលជូនមន្ត្រីរាជការគ្រប់កម្រិត | តម្រូវការបណ្តុះបណ្តាលត្រូវបានប្រមូលនិងពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋានកែទម្រង់៣ បូក ១ | | | x | x | x | វសហ, អគ្គ. កសហវ, និង LMGA | 00 USD |

## *៣.២. បង្កើនកិច្ចសហការជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ និង ក្រសួងស្ថាប័ន*

| **សកម្មភាពយុទ្ធសាស្ត្រ** | **សូចនាករសមិទ្ធកម្មគន្លឹះ** | **ពេលវេលាអនុវត្ត (២០២១-២០២៥)** | | | | | **តួអង្គអនុវត្ត** | **គម្រោងចំណាយ** |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** សហការជាមួយ អគហ អគ្គ. កសហវ ក្នុងការផ្តល់គ្រូឧទ្ទេស និង គ្រូបង្គោល ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ | ចំនួនវាគ្មិន ឬ គ្រូឧទ្ទេស និង គ្រូបង្គោល ត្រូវបានរៀបចំ និង ធ្វើបច្ចុប្បន្នកម្ម | x | x | x | x | x | វសហ និងអគ្គ. កសហវ | 00 USD |
| | វាគ្មិន ឬ គ្រូឧទ្ទេស និង គ្រូបង្គោលទទួលបានការបំពាក់បំប៉នសមត្ថភាពបន្ថែម (TOT) | x | | x | | x | វសហ និងអគ្គ. កសហវ | 25.000 USD (5 Workshops) |
| | មន្ត្រីចូលនិវត្តន៍ត្រូវបានលើកទឹកចិត្តធ្វើជាគ្រូបង្គោល | x | x | x | x | x | វសហ និងអគ្គ. កសហវ | 00 USD |
| **២.** បង្កើនកិច្ចសហការជាមួយLMGA លើការកសាង និង ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការគ្រប់កម្រិតលើជំនាញ PFM | មន្ត្រីរាជការទទួលបានការបណ្តុះបណ្តាលលើជំនាញPFM ស្របតាមតម្រូវការបណ្តុះបណ្តាល | x | x | x | x | x | វសហ, អគ្គ. កសហវ, និង LMGA | 00 USD |

## *៣.៣. អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាព តាមការដឹកនាំ ណែនាំ និង តម្រង់ទិសជាយុទ្ធសាស្ត្រ របស់ក្រុមការងារកសាងសមត្ថភាព នៃ កសហវ*

| **សកម្មភាពយុទ្ធសាស្ត្រ** | **សូចនាករសមិទ្ធកម្មគន្លឹះ** | **ពេលវេលាអនុវត្ត (២០២១-២០២៥)** | | | | | **តួអង្គអនុវត្ត** | **គម្រោងចំណាយ** |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** រៀបចំ និង អនុវត្ត SCDP ដោយប្រតិបត្តិតាមការតម្រង់ទិសរបស់ កសហវ | ការតម្រង់ទិសជាយុទ្ធសាស្ត្រលើការអនុវត្ត SCDP ត្រូវបានណែនាំ និង ចង្អុលបង្ហាញ | | x | x | x | x | វសហ និង ក.កសហវ | 00 USD |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **២.** អនុវត្តការបណ្តុះបណ្តាល មានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ | កម្មវិធីបណ្តុះបណ្តាល ទទួលបានការអនុម័ត និង គាំទ្រពី កសហវ | x | x | x | x | x | វសហ និង ក.កសហវ | 00 USD |
| **៣.** អនុវត្តវាយតម្លៃប្រសិទ្ធភាពបណ្តុះបណ្តាលស្របតាមការណែនាំរបស់ កសហវ | លទ្ធផលវាយតម្លៃ ទទួលបានការគាំទ្រ និង ណែនាំបន្ថែមពី កសហវ | x | | x | | x | វសហ និង ក.កសហវ | 00 USD |
| **៤.** អនុវត្តការធ្វើបច្ចុប្បន្នកម្មឯកសារ SCDP តាមការណែនាំ កសហវ អនុលោមតាមតម្រូវការនៃ PFM | SCDP ត្រូវបានគាំទ្រ តម្រង់ទិស និង ចង្អុលបង្ហាញលើការធ្វើបច្ចុប្បន្នកម្ម | | | x | | x | វសហ និង ក.កសហវ | 00 USD |

**ឃ. យុទ្ធសាស្ត្រទី ៤: ការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ**

*៤.១. រៀបចំ និង អនុវត្តការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និង វិក្រឹតការសមត្ថភាពមន្ត្រីរាជការ*

| **សកម្មភាពយុទ្ធសាស្ត្រ** | **សូចនាករសមិទ្ធកម្មគន្លឹះ** | **ពេលវេលាអនុវត្ត (២០២១-២០២៥)** | | | | | **តួអង្គអនុវត្ត** | **គម្រោងចំណាយ** |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** សិក្សា និង ដកស្រង់បទពិសោធន៍ និង ឧត្តមានុវត្តជាតិ-អន្តរជាតិ លើការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ | មន្ត្រីជំនាញត្រូវបានពង្រឹងសមត្ថភាពបន្ថែមលើជំនាញវាយតម្លៃតម្រូវការបណ្តុះបណ្តាល | | | x | x | x | វសហ | 50.000 USD |
| | ឯកសារណែនាំប្រតិបត្តិស្តីពីការវាយតម្លៃតម្រូវការបណ្តុះបណ្តាល ត្រូវបានដាក់ឱ្យអនុវត្ត | | | x | x | | វសហ | 10.000 USD |
| **២.** អនុវត្តការវាយតម្លៃតម្រូវការបណ្តុះបណ្តាលប្រចាំឆ្នាំ របស់ LMGA និង អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ គ្រប់កម្រិត ដើម្បីរៀបចំផែនការបណ្តុះបណ្តាល ជំនាញបច្ចេកទេសប្រចាំឆ្នាំ | ចំនួនសិក្ខាកាម LMGA ត្រូវបានកំណត់ជាក់លាក់ | x | x | x | x | x | វសហ | 00 USD |
| | ចំនួនមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុសាធារណៈ ទូទាំងប្រទេសត្រូវបានសិក្សាស្រាវជ្រាវ និង ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ | | x | x | x | x | វសហ | 00 USD |
| | កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស ត្រូវបានកំណត់ជាក់លាក់ | x | x | x | x | x | វសហ | 00 USD |

*៤.២. រៀបចំ និង អនុវត្តការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយ*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| **១.** រៀបចំផែនការ និង ឯកសារទស្សនាទានសម្រាប់ការសិក្សាស្រាវជ្រាវលើកប្រធានបទពាក់ព័ន្ធនឹង PFM | ផែនការ និង ប្រធានបទស្រាវជ្រាវត្រូវបានឯកភាព និង គាំទ្រជាគោលការណ៍ពី កសហវ និង ថ្នាក់ដឹកនាំ កសហវ | | | x | x | x | វសហ និង ក.កសហវ | 00 USD |
| | លទ្ធផល និង អនុសាសន៍នៃការស្រាវជ្រាវ ត្រូវបានគាំទ្រ និង រៀបចំផ្សព្វផ្សាយ | | | x | x | x | វសហ និង ក.កសហវ | 00 USD |
| **២.** អនុវត្តការស្រាវជ្រាវ និង ប្រមូលធាតុចូលពាក់ព័ន្ធនឹង PFM សម្រាប់ជាមូលដ្ឋានធ្វើបច្ចុប្បន្នកម្ម កបប | ឯកសារ និង ធាតុចូល ដើម្បីធ្វើបច្ចុប្បន្នកម្មកម្មវិធីបណ្តុះបណ្តាល ត្រូវបានរៀបចំ និង ចងក្រង | x | x | x | x | x | វសហ | 00 USD |
| **៣.** រៀបចំកម្មវិធីវិក្រឹតការលើជំនាញថវិកាសមិទ្ធកម្មជូនសិក្ខាកាម TCPFM ដំណាក់កាលទី ៣ | កម្មវិធីវិក្រឹតការលើជំនាញថវិកាសមិទ្ធកម្មជូនសិក្ខាកាមTCPFM ដំណាក់កាលទី ៣ ត្រូវបានរៀបចំ | | | x | | | វសហ | 5.000 USD |
| **៤.** បន្តរៀបចំកម្មវិធីបណ្តុះបណ្តាល TCPFM | កម្មវិធីបណ្តុះបណ្តាល TCPFM ជូន LMGA និង អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ត្រូវបានរៀបចំ | x | x | x | x | x | វសហ | 25.000 USD |
| | កម្មវិធីបណ្តុះបណ្តាល TCPFM ជូនសិក្ខាកាមមកពីគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ | | | x | x | x | វសហ | 25.000 USD |

**ង. យុទ្ធសាស្ត្រទី ៥: ការពង្រឹងការវាយតម្លៃតម្រូវការ ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ និង វិធីសាស្ត្របណ្តុះបណ្តាល**

*៥.១. ពង្រឹងយន្តការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាព*

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១. រៀបចំយន្តការក្រុមការងារលើការត្រួតពិនិត្យ តាមដាន និង វាយតម្លៃ | ក្រុមការងារតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ត្រូវបានរៀបចំធ្វើបច្ចុប្បន្នកម្ម | | | x | x | | វសហ និង អគ្គ. កសហវ | 00 USD |
| | TOR របស់ក្រុមការងារតាមដានត្រួតពិនិត្យនិង វាយតម្លៃ ត្រូវបានរៀបចំ និង អនុម័ត | | | x | x | | វសហ និង អគ្គ. កសហវ | 00 USD |
| ២. ពង្រឹងសមត្ថភាពក្រុមការងារ លើជំនាញបច្ចេកទេស នៃការត្រួតពិនិត្យ តាមដាន និង វាយតម្លៃ | ក្រុមការងារត្រូវបានពង្រឹងសមត្ថភាពបន្ថែម | | | x | x | x | វសហ និង អគ្គ. កសហវ | 15.000 USD |
| ៣. រៀបចំផែនការសកម្មភាព ត្រួតពិនិត្យ តាមដាន និង វាយតម្លៃ ការអនុវត្តទិសដៅយុទ្ធសាស្ត្រផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ | ផែនការសកម្មភាព នៃការត្រួតពិនិត្យ តាមដាន និង វាយតម្លៃ ត្រូវបានរៀបចំ | | x | x | x | x | វសហ និង អគ្គ. កសហវ | 00 USD |
| | របាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពត្រូវបានរៀបចំ | | x | x | x | x | វសហ និង អគ្គ. កសហវ | 00 USD |

## ៥.២.ពង្រឹងយន្តការរៀបចំរបាយការណ៍សមិទ្ធកម្មលើការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការកសាង និង ការអភិវឌ្ឍសមត្ថភាពរបស់ កសហវ

| សកម្មភាពយុទ្ធសាស្ត្រ | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | | តួអង្គអនុវត្ត | គម្រោងចំណាយ |
|---|---|---|---|---|---|---|---|---|
| | | រយៈពេលមធ្យម | | | រយៈពេលវែង | | | |
| | | ២១ | ២២ | ២៣ | ២៤ | ២៥ | | |
| ១. រៀបចំផែនការ និង អនុវត្តការវាយតម្លៃសមិទ្ធកម្មលើការអនុវត្ត SCDP របស់ កសហវ | របាយការណ៍សមិទ្ធកម្ម ពាក់កណ្តាលអាណត្តិ និង ចុងអាណត្តិ ត្រូវបានរៀបចំ | | | x | | x | វសហ, អគ្គ. កសហវ, និង LMGA | 00 USD |
| ២. កែលម្អការអនុវត្ត SCDP របស់ កសហវ ពាក់កណ្តាលអាណត្តិ | បញ្ហាប្រឈមលើការអនុវត្ត SCDP កណ្តាលអាណត្តិ ត្រូវបានកែលម្អ និង ជំរុញការអនុវត្តនៅពាក់កណ្តាលអាណត្តិចុងក្រោយ | | | | x | x | វសហ, អគ្គ. កសហវ, និង LMGA | 00 USD |
| ៣. ផ្សព្វផ្សាយរបាយការណ៍លទ្ធផលវាយតម្លៃការអនុវត្ត SCDP របស់ កសហវ | កម្មវិធីវិបស្សនាលើលទ្ធផលវាយតម្លៃការអនុវត្ត SCDP ត្រូវបានរៀបចំ | | | x | | x | វសហ, អគ្គ. កសហវ, និង LMGA | 15.000 USD |
| | របាយការណ៍នៃកម្មវិធីវិបស្សនាលើលទ្ធផលវាយតម្លៃការអនុវត្ត SCDP ត្រូវបានរៀបចំ | | | x | | x | វសហ និង អគ្គ. កសហវ | 00 USD |

# ឧបសម្ព័ន្ធ ២: តារាងកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការ ឆ្នាំ ២០២១-២០២៥
## សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន

| ល.រ | កម្មវិធីបណ្តុះបណ្តាល | តួអង្គអនុវត្ត | ចំនួនសិក្ខាកាម និង ពេលវេលាអនុវត្ត (២០២១-២០២៥) | | | | |
|---|---|---|---|---|---|---|---|
| | | | ២១ | ២២ | ២៣ | ២៤ | ២៥ |
| ១ | **ផ្តល់ការបណ្តុះបណ្តាលស្តីពីគោលការណ៍រៀបចំថវិកាសមិទ្ធកម្ម** | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| | ១.១. រៀបចំឯកសារបណ្តុះបណ្តាល (Training Manual) ស្តីពីគោលការណ៍រៀបចំថវិកាសមិទ្ធកម្ម | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| | ១.២. បណ្តុះបណ្តាលស្តីពីការរៀបចំថវិកាសមិទ្ធកម្ម | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| ២ | **ផ្តល់ការបណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីអនុវត្តថវិកាសមិទ្ធកម្ម** | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| | ២.១. រៀបចំឯកសារបណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីអនុវត្តថវិកាសមិទ្ធកម្ម | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| | ២.២. បណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីអនុវត្តថវិកាសមិទ្ធកម្ម | អ.ថ., វសហ | n/a | n/a | n/a | n/a | n/a |
| ៣ | **លើកកម្ពស់ជំនាញរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាកម្មវិធីដល់រដ្ឋបាលរាជធានី ខេត្ត** | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| | ៣.១. រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាកម្មវិធីជូនរដ្ឋបាលរាជធានី ខេត្ត | អហក, វសហ | x | | | | |
| | ៣.២. រៀបចំបណ្តុះបណ្តាលការកសាងផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាកម្មវិធីជូនរដ្ឋបាលរាជធានី ខេត្ត | អហក, វសហ | x | x | x | x | |
| ៤ | **លើកកម្ពស់ជំនាញរៀបចំថវិកា និង ការគ្រប់គ្រងការអនុវត្តថវិកាជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ** | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| | ៤.១. រៀបចំកម្មវិធីបណ្តុះបណ្តាលជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ខណ្ឌ | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| | ៤.២. ផ្តល់ការបណ្តុះបណ្តាលជូនមន្ត្រីរាជការជំនាញហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ខណ្ឌ | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| ៥ | **លើកកម្ពស់ជំនាញរៀបចំថវិកា និង ការគ្រប់គ្រងការអនុវត្តថវិកាជូនរដ្ឋបាលឃុំ សង្កាត់** | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| | ៥.១. រៀបចំ កបបជូនមន្ត្រីជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាលឃុំ សង្កាត់ | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| | ៥.២. ផ្តល់ការបណ្តុះបណ្តាលជូនមន្ត្រីជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាលឃុំ សង្កាត់ | អហក, វសហ | n/a | n/a | n/a | n/a | n/a |
| ៦ | **ផ្តល់ការបណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីពាក់ព័ន្ធការរៀបចំផែនការលទ្ធកម្ម** | អលស,វសហ | n/a | n/a | n/a | n/a | n/a |
| | ៦.១. បណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីពាក់ព័ន្ធការរៀបចំផែនការលទ្ធកម្ម | អលស,វសហ | n/a | n/a | n/a | n/a | n/a |
| | ៦.២. បណ្តុះបណ្តាលស្តីពីគោលការណ៍ និង នីតិវិធីពាក់ព័ន្ធការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ | អលស,វសហ | n/a | n/a | n/a | n/a | n/a |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន | អ.វ.ត.,វសហ | ៦០ | ៦០ | ៦០ | ៦០ | ៦០ |
| ៨ | នីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូល | អ.វ.ត.,វសហ | n/a | n/a | n/a | n/a | n/a |
| ៩ | កិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទាន និង រជ្ជទេយ្យចំណូល | អ.វ.ត.,វសហ | ស១ | ស២ | | | |
| ១០ | ការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) | អ.វ.ត.,វសហ | ៩៧០ | ១៧១១ | | | |
| ១១ | ការបញ្ចូលទិន្នន័យគ្រប់គ្រងសាច់ប្រាក់ក្នុងប្រព័ន្ធ Web based Application គ្រប់ក្រសួងស្ថាប័ន | អ.វ.ត.,វសហ | ១២៣ | | | | |
| ១២ | នីតិវិធីសវនកម្មផ្ទៃក្នុង | អ.ស.ក.,វសហ | ៨៥ | | | | |
| ១៣ | រៀបចំផែនការសវនកម្មផ្ទៃក្នុង | អ.ស.ក.,វសហ | ៨៥ | | | | |
| ១៤ | ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង | អ.ស.ក.,វសហ | ៨៥ | | | | |
| ១៥ | សវនកម្មសមិទ្ធកម្ម | អ.ស.ក.,វសហ | ៨៥ | | | | |
| ១៦ | សវនកម្មបច្ចេកវិទ្យាព័ត៌មាន (IT Audit) | អ.ស.ក.,វសហ | ៨៥ | | | | |
| ១៧ | គ្រប់គ្រង និង ភាពជាអ្នកដឹកនាំ (Management and Leadership) | អគ្គ. កសហវ, LMGA, វសហ | ១៥០ | ១៥០ | | | |
| ១៨ | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | អគ្គ. កសហវ, LMGA, វសហ | n/a | n/a | n/a | n/a | n/a |
| ១៩ | លទ្ធកម្មសាធារណៈ (Public Procurement) | អគ្គ. កសហវ, LMGA, វសហ | ១៥៦ | ១៥៦ | ១៥៦ | | |
| ២០ | ហិរញ្ញវត្ថុសាធារណៈ (Public Finance) | អគ្គ. កសហវ, LMGA, វសហ | ១៥៦ | ១៥៦ | ១៥៦ | | |
| ២១ | គណនេយ្យសាធារណៈ (Public Accounting) | អគ្គ. កសហវ, LMGA, វសហ | ១៥៦ | ១៥៦ | ១៥៦ | | |
| ២២ | ការវិភាគ និង ការព្យាករស្ថូចនាករម៉ាក្រូសេដ្ឋកិច្ច | អគ្គ. កសហវ, LMGA, វសហ | ២០ | ២០ | ២០ | | |
| ២៣ | គ្រប់គ្រងរដ្ឋបាលសាធារណៈ  (Public Administration Management) | អគ្គ. កសហវ, LMGA, វសហ | ៥០ | ៥០ | ៥០ | | |
| ២៤ | គ្រប់គ្រងវិនិយោគសាធារណៈ (Public Investment Management) | អគ្គ. កសហវ, LMGA, វសហ | ស៣ | ស៤ | | | |
| ២៥ | បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុជូនដល់ស្ថាប័ននីតិប្បញ្ញត្តិ | អគ្គ. កសហវ, LMGA, វសហ | ១៥០ | ១៥០ | | | |
| ២៦ | ការអភិវឌ្ឍវិជ្ជាជីវៈ (Professional Development) | អគ្គ. កសហវ, LMGA, វសហ | ១៥០ | ១៥០ | | | |

**សម្គាល់**:

- *ស១ : ថ្នាក់ជាតិ ២៣២២ និង ថ្នាក់ក្រោមជាតិ ២៣៨៦*    - *ស២ : ថ្នាក់ជាតិ ២៣២២ និង ថ្នាក់ក្រោមជាតិ ២៣៨៦*
- *ស៣ : ថ្នាក់ជាតិ ២៥១២ និង ថ្នាក់ក្រោមជាតិ ២៥៧៦*    - *ស៤ : ថ្នាក់ជាតិ ២៥១២ និង ថ្នាក់ក្រោមជាតិ ២២៥៧៦*

## ឧបសម្ព័ន្ធ ៣: ក្របខណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ

| កម្រិតសមត្ថភាពជំនាញ | កម្រិត ១ | កម្រិត ២ | កម្រិត ៣ | កម្រិត ៤ | កម្រិត ៥ |
|---|---|---|---|---|---|
| ប្រភេទសមត្ថភាពជំនាញ | សមត្ថភាពយល់ដឹងទូទៅ | សមត្ថភាពឯកទេសមូលដ្ឋាន | សមត្ថភាពឯកទេសជំនាញ | សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់ | សមត្ថភាពឯកទេសកម្រិតជំនាញការ |
| កម្មវិធីបណ្តុះបណ្តាល | ឯកទេសតម្រង់ទិស | ឯកទេសមូលដ្ឋាន | ឯកទេសជំនាញ | ឯកទេសជំនាញកម្រិតខ្ពស់ | ឯកទេសកម្រិតជំនាញការ |
| រយៈពេលសិក្សា | ក្រោម ៤៥ ម៉ោង | ៤៥ - ៩០ ម៉ោង | ៩០ - ១០៥ ម៉ោង | ១០៥ - ១២០ ម៉ោង | ១២០ - ១៣៥ ម៉ោង |
| កម្រិតគុណវុឌ្ឍិ | កម្រិតមិនមែនវិញ្ញាបនបត្រ (Non-Certificate Program) | កម្រិតវិញ្ញាបនបត្រ (Certificate Program) | | កម្រិតវិញ្ញាបនបត្រជាន់ខ្ពស់ (Advanced Certificate Program) | |
| សិក្ខាកាមគោលដៅ | ជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ, បុគ្គលិកកិច្ចសន្យា នៃក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈរដ្ឋបាល, រដ្ឋបាលថ្នាក់ក្រោមជាតិ និង សាធារណជន | រដ្ឋទេយ្យករបុរេប្រទានរង, រដ្ឋទេយ្យករចំណូលរង, ភ្នាក់ងារបើកផ្តល់ភ្នាក់ងារបើកផ្តល់ជំនួស, ជំនួយការគណនេយ្យ ក្រុមជំនួយការហិរញ្ញវត្ថុ, ជំនួយការខាងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, ក្រុមជំនួយការទទួលបន្ទុកកិច្ចលទ្ធកម្មសាធារណៈ, ក្រុមជំនួយការសវនករផ្ទៃក្នុង, ជំនួយការគម្រោងវិនិយោគសាធារណៈ, ក្រុមជំនួយការគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន | រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករចំណូល, គណនេយ្យករ, ក្រុមមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ, ក្រុមមន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, ក្រុមមន្ត្រីទទួលបន្ទុកកិច្ចការលទ្ធកម្មសាធារណៈ, សវនករផ្ទៃក្នុង, ក្រុមមន្ត្រីគម្រោងវិនិយោគសាធារណៈ និង ក្រុមមន្ត្រីគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន និង អតីតសិក្ខាកាម បានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ២ | អ្នកគ្រប់គ្រងហិរញ្ញវត្ថុ, អ្នកគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អ្នកគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈ; អ្នកគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង អ្នកគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន, ប្រធានក្រុមសវនករផ្ទៃក្នុង និងអធិការកិច្ច និង អតីតសិក្ខាកាម ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ៣ | មន្ត្រីរាជការ របស់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីចាប់ពីប្រធាននាយកដ្ឋាន (ថ្នាក់កណ្តាល) និង ចាប់ពីនាយករដ្ឋបាលសាលារាជធានីខេត្ត (រដ្ឋបាលថ្នាក់ក្រោមជាតិ) ឬ ថ្នាក់ប្រហាក់ប្រហែល និង មន្ត្រីវិភាគថវិកា ហិរញ្ញវត្ថុ សេដ្ឋកិច្ច និង គ្រូបង្គោលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី ៤ |
| គំរូសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ | បទប្បញ្ញត្តិ, លិខិតបទដ្ឋានគតិយុត្ត, គោលនយោបាយ, យុទ្ធសាស្ត្រ និង គោលការណ៍ណែនាំពាក់ព័ន្ធ ។ល។ | **មុខជំនាញឯកទេស:** *១. ថវិកា, ២. ហិរញ្ញវត្ថុ, ៣.គណនេយ្យ, ៤. សាច់ប្រាក់, ៥. រដ្ឋទេយ្យបុរេប្រទាន, ៦. រដ្ឋទេយ្យចំណូល, ៧. លទ្ធកម្ម, ៨. ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, ៩. គម្រោងវិនិយោគសាធារណៈ, ១០. គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, ១១. សវនកម្មផ្ទៃក្នុង, ១២. អធិការកិច្ចហិរញ្ញវត្ថុ, ១៣. គ្រប់គ្រងការផ្លាស់ប្តូរ, និង ១៤. ភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ ។ល។* | | | |

## ឧបសម្ព័ន្ធ ៤: មុខជំនាញឯកទេស និង មុខជំនាញគាំទ្រ
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤

| ល.រ | មុខជំនាញ | មុខវិជ្ជាគន្លឹះៗ |
|---|---|---|
| **១** | **មុខជំនាញឯកទេសគន្លឹះៗ** | |
| ១.១ | **ថវិកាសមិទ្ធកម្ម** | (១). គោលការណ៍ និង នីតិវិធីពាក់ព័ន្ធការរៀបចំ និង អនុវត្តចំណាយថវិកាសមិទ្ធកម្ម<br>(២). ការវិភាគ និង ការគ្រប់គ្រងថវិកា ក្នុងបរិបទថវិកាសមិទ្ធកម្ម<br>(៣). ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត<br>(៤). ការរៀបចំថវិកា និង ការគ្រប់គ្រងការអនុវត្តថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ឃុំសង្កាត់<br>(៥). ការអនុវត្តពេញលេញនូវការគ្រប់គ្រងថវិកាផ្អែកលើសមិទ្ធកម្ម |
| ១.២ | **លទ្ធកម្មសាធារណៈ** | (១). គោលការណ៍ និង នីតិវិធីពាក់ព័ន្ធការរៀបចំផែនការ និង ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ<br>(២). ការធ្វើប្រតិភូកម្មកិច្ចលទ្ធកម្មសាធារណៈដល់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និង អង្គភាពសាធារណៈប្រហាក់ប្រហែល<br>(៣). ទស្សនាទាន និង ឧត្តមានុវត្តន៍នៃបុច្ឆាសវនកម្មលទ្ធកម្ម<br>(៤). គោលការណ៍ និង នីតិវិធីពាក់ព័ន្ធការអនុវត្តបុច្ឆាសវនកម្មលទ្ធកម្ម<br>(៥). ការរៀបចំ និង ការអនុវត្តបុច្ឆាសវនកម្មលទ្ធកម្ម |
| ១.៣ | **គណនេយ្យសាធារណៈ** | (១). ការផ្ទៀងផ្ទាត់ និង ការជម្រះគណនី<br>(២). គណនេយ្យទ្រព្យសកម្មចរន្ត និង បំណុលចរន្ត<br>(៣). គណនេយ្យទ្រព្យសកម្មរយៈពេលវែង<br>(៤). គណនេយ្យបំណុលផ្សេងទៀត<br>(៥). ការរៀបចំ និង ការបកស្រាយរបាយការណ៍ហិរញ្ញវត្ថុ |
| ១.៤ | **ការគ្រប់គ្រងសាច់ប្រាក់** | (១). ការរៀបចំ និង ការអនុវត្តកម្មវិធីចំណូល, នីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូល និង ការគ្រប់គ្រងគណនីត្រូវទទួលឬទារ |

| | | |
|---|---|---|
| | | (២). ការរៀបចំ និង ការអនុវត្តកម្មវិធីចំណាយ និង នីតិវិធីគ្រប់គ្រងរជ្ជទេយ្យបុរេប្រទាន<br>(៣). ការគ្រប់គ្រងគណនីត្រូវទូទាត់សង និង ការគ្រប់គ្រងលទ្ធភាពទូទាត់បំណុល និង វិនិយោគ<br>(៤). ការរៀបចំកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទាន និង រជ្ជទេយ្យចំណូល<br>(៥). ការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) |
